ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលជលផល

ឯកសារស្រាវជ្រាវ :

# ការកំណត់ព្រំប្រទល់ដែននេសាទ


រៀបរៀងដោយ :

ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ណៅ ធួក "ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល"

លោក ភឿន ភាន "ប្រធាននាយកដ្ឋានកិច្ចការជលផល"

លោក សំ សត្យា "អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលនិងនីតិកម្ម"



ឧសភា គ.ស ២០១៤ / ព.ស ២៥៥៨

# អារម្ភកថា

សង្គ្រាមរាំរ៉ៃផ្ទៃក្នុងត្រូវបានបញ្ចប់ ការកសាងនិងការអភិវឌ្ឍន៍ប្រទេសជាតិបាននិងកំពុងឈានទៅមុខជាលំដាប់លើគ្រប់វិស័យគួរឱ្យមានមោទនភាពក្នុងនោះរួមទាំងវិស័យជលផលផងដែរ។

រចនាសម្ព័ន្ធគ្រប់គ្រងវិស័យជលផល ត្រូវបានបង្កើតឡើងវិញជាថ្មីនៅចុងឆ្នាំ១៩៧៩ ដើម្បីគ្រប់គ្រងជលផលនិងធនធានជលផលប្រកបដោយនិរន្តរភាព និងរួមចំណែកជួយសម្រួលជីវភាពប្រជាពលរដ្ឋ អ្នកនេសាទ រៀបចំកន្លែងធ្វើនេសាទស្របតាមប្រភេទឧបករណ៍នេសាទ ដើម្បីចៀសវាងទំនាស់ផ្សេងៗ ដែលអាចកើតឡើងជាយថាហេតុ កាត់បន្ថយការធ្វើនេសាទហួសកម្រិត ការថែរក្សាការពារព្រៃលិចទឹកនិងព្រៃកោងកាង ការកែលម្អដែននេសាទ ការពារជីវចម្រុះបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ីជលផល ការរៀបចំនិងបង្កើតសហគមន៍នេសាទ ដើម្បីផ្តល់ឱកាសឱ្យមានការចូល-រួមគ្រប់គ្រងនិងការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព ការអភិរក្សនិងអភិវឌ្ឍវារីវប្បកម្ម ការចែកចាយផលនេសាទទៅតាមតម្រូវការជាក់ស្តែងជូនប្រជាពលរដ្ឋ ការនាំចេញនិងការប្រមូលថ្លៃឈ្នួលដែននេសាទលើឧបករណ៍នេសាទស្របតាមផលស្តុកធម្មជាតិ។

ដោយសារសារៈសំខាន់និងផលប្រយោជន៍នៃវិស័យជលផលខាងលើនេះហើយ ទើបត្រូវមានការការពារនិងថែរក្សាដែននេសាទឱ្យបានគង់វង់ដាច់ខាត ជាពិសេសព្រៃលិចទឹកនិងព្រៃកោងកាងដែលជាប្រភពផ្តល់ចំណី កន្លែងជ្រកពួននិងពងកូនសំខាន់របស់មច្ឆជាតិក៏ដូចជាការរួចផុតពីការចូលទន្ទ្រានកាន់កាប់ដែននេសាទដែលជាទ្រព្យសម្បត្តិរបស់រដ្ឋដោយខុសច្បាប់។ ដូចនេះ ដែននេសាទចាំបាច់ត្រូវមានការកំណត់ព្រំប្រទល់ឱ្យបានច្បាប់លាស់ ដើម្បីចុះបញ្ជីដីរដ្ឋក្នុងសៀវភៅគោលបញ្ជីដីធ្លី។ ប៉ុន្តែការអនុវត្តនិងដោះស្រាយបញ្ហានេះបាន ទាមទារឱ្យមានការសម្របសម្រួលនិងតម្លាភាពដោយធ្វើកិច្ចសហការរវាងក្រសួង ស្ថាប័ន អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋសហគមន៍មូលដ្ឋានឱ្យបានល្អដាច់ខាត ព្រមទាំងអនុវត្តផ្ទាល់ដោយក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ក្រោមការដឹកនាំរបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត និងតម្រូវធ្វើវិសោធនកម្មបញ្ចូលសមាសភាពមន្ត្រីរដ្ឋបាលជលផលនៅក្នុងក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ និងក្នុងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្តផងដែរ។

នេះជាឯកសារស្រាវជ្រាវលើកទី២ ដែលស្មេរនិពន្ធបានកែសម្រួលឲ្យកាន់តែសុក្រឹត្យថែមទៀតនូវប្រវត្តិឡូត៍នេសាទនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីចងក្រងជាឯកសារស្រាវជ្រាវនេះឡើង។ ស្មេរនិពន្ធសូមអភ័យទោសទុកជាមុនចំពោះការធ្វើអធិប្បាយ ការប្រើពាក្យពេចន៍ ឃ្លាឃ្លោង និងអក្ខរាវារុទ្ធជាដើម។ល។ ដោយហេតុថា ការស្រាវជ្រាវនេះពុំមានពេលវេលាគ្រប់គ្រាន់ ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយក៏ស្មេរនិពន្ធសង្ឃឹមទុកជាមុនថា ឯកសារការស្រាវជ្រាវនេះនឹងផ្តល់អត្ថប្រយោជន៍ដល់អ្នកដែលមានបំណងស្វែងយល់អំពីបញ្ហានិងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការធ្វើអត្តសញ្ញាណកម្មនិងផែនទីដីរដ្ឋ ជាពិសេសការធ្វើអត្តសញ្ញាណកម្មដែននេសាទនិងផែនទីជាក់ជាមិនខានឡើយ។

ម.ឯ.ក AIDOC
Code: 147-030
Date:
Donated by:

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០១៤

# មាតិកា

ឈ្មោះ ទំព័រ

**សេចក្តីផ្តើម**............................................................................................................១

**ជំពូកទី១: សញ្ញាណដែនទេសានិងតំបន់គ្រប់គ្រងជលផល** ..............................៣
១-សញ្ញាណដែននេសាទ..........................................................................................៣
២-តំបន់គ្រប់គ្រងជលផល ......................................................................................៣
ក-តំបន់គ្រប់គ្រងជលផលទឹកសាប.............................................................................៣
ខ-ប្រវត្តិសង្ខេបនៃឡូត៍នេសាទនៅកម្ពុជា....................................................................៥

**ជំពូកទី២: នីតិវិធីធ្វើអត្តសញ្ញាណកម្មដែននេសាទ** ........................................២០
១-គោលការណ៍គ្រឹះ .............................................................................................២០
ក-អាជ្ញាធរកាន់កាប់ដីរដ្ឋ(ដែននេសាទ) ....................................................................២៣
ខ-ការធ្វើអត្តសញ្ញាណកម្មដែននេសាទ ......................................................................២៤
២-នីតិវិធីធ្វើផែនទីដីរដ្ឋឬដែននេសាទ ........................................................................ ៣០
ក-ការឯកភាពមតិគ្នារបស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ........................................ ៣០
ខ-របាយការណ៍របស់ក្រុមការងារដីរដ្ឋថ្នាក់រាជធានី ខេត្ត.............................................៣២
គ-ការបញ្ចូលលទ្ធផលក្នុងប្រព័ន្ធទិន្នន័យ តាមដាន និងរបាយការណ៍ ........................ ៣៥
៣-ការធ្វើចំណាត់ថ្នាក់ដែននេសាទ(ដីរដ្ឋ)និងឯកសារ ................................................ ៣៥
ក-នីតិវិធីធ្វើចំណាត់ថ្នាក់ដែននេសាទ(ដីរដ្ឋ) និងឯកសារ.............................................. ៣៥
ខ-អំពីឯកសារ........................................................................................................ ៣៩
**សន្និដ្ឋាន:** ......................................................................................................... .៤០
**ឯកសារយោង:**.......................................................................................................៤៤

## សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជាមានផ្ទៃដីសរុបចំនួន១៨១.០៣៥ គម² និងមានប្រជាពលរដ្ឋរស់នៅសរុបចំនួន ១៤.០៨០.៦៥៣ នាក់ (ទិន្នន័យលេខឆ្នាំ២០១២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)។ ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រដែលមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញនិងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត្យ អចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ។ បូរណភាពដែនដីរបស់ព្រះរាជាណាចក្រកម្ពុជា មិនអាចរំលោភបានដាច់ខាតក្នុងព្រំដែនរបស់ខ្លួនដែលមានកំណត់ក្នុងផែនទីខ្នាត១/១០០.០០០ ធ្វើនៅចន្លោះឆ្នាំ១៩៣៣-១៩៥៣ ហើយដែលទទួលស្គាល់ជាអន្តរជាតិនៅចន្លោះឆ្នាំ១៩៦៣-១៩៦៩ (មាត្រា១ និងមាត្រា២ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣)។

ចំពោះកម្មសិទ្ធិលើដីធ្លី គឺមានតែប្រជាពលរដ្ឋដែលមានសញ្ជាតិខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លីនៃព្រះរាជាណាចក្រកម្ពុជា ហើយកម្មសិទ្ធិឯកជនស្របច្បាប់នេះត្រូវស្ថិតនៅក្រោមការគាំពារនៃច្បាប់។ ការដកហូតកម្មសិទ្ធិដីធ្លីអំពីជនណាមួយបាន លុះត្រាតែការដកហូតនោះធ្វើឡើង ដើម្បីផលប្រយោជន៍សាធារណៈដែលបានតម្រូវ និងក្នុងករណីច្បាប់បានបញ្ញត្តិទុកជាមុនប៉ុន្តែត្រូវផ្តល់សំណងជាមុនដោយសមរម្យនិងយុត្តិធម៌ (មាត្រា៤៤នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងមាត្រា៧ នៃនីតិភូមិបាលឆ្នាំ២០០១ )។ ក្រៅពីដីធ្លីដែលរដ្ឋបានផ្តល់ជូនប្រជាពលរដ្ឋខាងលើរដ្ឋក៏ជាម្ចាស់កម្មសិទ្ធិនៃដីធ្លីនិងទ្រព្យសម្បត្តិមួយចំនួនទៀតដែរជាអាទិ៍ ភ្នំ សមុទ្រ បាតសមុទ្រ ក្រោមបាតសមុទ្រ ខ្យល់ អាកាស ប្រេងកាត ឧស្ម័ន ថ្ម ខ្សាច់ ត្បូងថ្ម ព្រៃឈើ អនុផលព្រៃឈើ សត្វព្រៃ កោះ ទន្លេ ព្រែក ស្ទឹង បឹង មច្ឆជាតិ និងធនធានជលផលផងដែរ។

រដ្ឋមានកាតព្វកិច្ចថែរក្សា ការពារបរិស្ថាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិ ព្រមទាំងប្រព័ន្ធអេកូឡូស៊ីទាំងនោះដោយមានផែនការគ្រប់គ្រងនិងការចាត់ចែងដោយច្បាស់លាស់ (មាត្រា៥៨ និងមាត្រា៥៩ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣)។

ដោយឡែក ការគ្រប់គ្រងជលផលនិងធនធានជលផលគឺ ស្ថិតនៅក្រោមវិធាននៃច្បាប់ស្តីពីជលផលដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដើម្បីធានានូវការគ្រប់គ្រងជលផលនិងធនធានជលផលរួមមាន ការជំរុញកិច្ចអភិវឌ្ឍន៍វារីវប្បកម្ម ផលិតកម្ម និងការកែច្នៃក្នុងគោលដៅលើកស្ទួយជីវភាពប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍មូលដ្ឋានក៏ដូចជាផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន ព្រមទាំងការអភិរក្សជីវចម្រុះនិងការរក្សាលំនឹងប្រព័ន្ធអេកូឡូស៊ីជលផលដែលស្ថិតនៅក្នុងដែននេសាទក្រោមទម្រង់ជាដីលិចទឹកដែលគ្របដណ្តប់ទៅដោយទឹកអចិន្ត្រៃយ៍ឬជំនន់ឡើង ឬទឹកជោរ នាចនៃសមុទ្រ។

តាមបញ្ញត្តិមាត្រា១០ និងមាត្រា១១ នៃនីតិជលផលឆ្នាំ២០០៦ ដែននេសាទមានវិសាលភាពគ្រប់ដណ្ដប់ទៅលើតំបន់គ្រប់គ្រងជលផលជាអាទិ៍ ឡូត៍នេសាទ កន្លែងអភិរក្សជលផល កន្លែងនេសាទសហគមន៍ កន្លែងនេសាទបម្រុង ទំនាបលិចទឹកក្នុងរដូវជំនោរឡើងនិងផ្ទៃទឹកសមុទ្រ ឬទឹកភ្លាវដែលលាតសន្ធឹងពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតនៃតំបន់ឆ្នេររហូតដល់ព្រំប្រទល់ខាងក្រៅនៃដែនសមុទ្រតំបន់សេដ្ឋកិច្ចផ្ដាច់មុខរបស់ព្រះរាជាណាចក្រកម្ពុជា។

តំបន់គ្រប់គ្រងជលផលមួយចំនួននាបច្ចុប្បន្ន ត្រូវបានកំណត់ព្រំប្រទល់និងផែនទីច្បាស់លាស់មានជាអាទិ៍ ឡូត៍នេសាទ កន្លែងនេសាទសហគមន៍ កន្លែងអភិរក្សជលផល នាទីព្រៃលិចទឹកជុំវិញបឹងទន្លេសាប។ល។ ប៉ុន្តែមានតំបន់គ្រប់គ្រងជលផលមួយចំនួនទៀតគឺ នៅពុំទាន់មានការកំណត់ព្រំប្រទល់និងផែនទីច្បាស់លាស់នៅឡើយទេ ជាអាទិ៍ ទំនាបលិចទឹកក្នុងរដូវជំនោរឡើង កន្លែងនេសាទសម្រាប់អភិវឌ្ឍន៍វារីវប្បកម្ម និងនាទីព្រៃកោងកាងជាដើម។ល។

ដូចនេះ ដើម្បីកំណត់ព្រំប្រទល់ដែននេសាបាន ទាមទារឱ្យអាជ្ញាធរកាន់កាប់ដីរដ្ឋដែលជាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋបាលជលផលជាអង្គភាពទទួលបន្ទុកផ្ទាល់នោះ ត្រូវធ្វើការសិក្សាស្រាវជ្រាវនិងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេសអាជ្ញាធរដែនដីដោយបង្ហាញឯកសារឬការអះអាងផ្សេងៗ បញ្ជាក់ថាដីធ្លីឬដែននេសាទនេះ គឺជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយស្ថិតនៅក្រោមអាណត្តិកាន់កាប់របស់ខ្លួននាបច្ចុប្បន្ន ដើម្បីឈានទៅធ្វើអត្តសញ្ញាណកម្មនិងផែនទីដីរដ្ឋឱ្យបានច្បាស់លាស់ និងស្របតាមខ្លឹមសារនៃនីតិជលផលឆ្នាំ២០០៦។ មាត្រា៩ នៃនីតិជលផលឆ្នាំ២០០៦ បានបញ្ញត្តិថាៈ"*ដែននេសាទ ជាទ្រព្យសម្បត្តិរបស់រដ្ឋ។ ព្រំប្រទល់នៃដែននេសាទ ត្រូវកំណត់ដោយអនុក្រឹត្យ*"។

ចំពោះការកំណត់ព្រំប្រទល់ដែននេសាទ ស្នេរនិពន្ធនឹងលើកយកមកពិភាក្សាដោយផ្អែកទៅតាមបណ្ដាឯកសារគតិយុត្តពាក់ព័ន្ធក្នុងនោះ សញ្ញាណនៃដែននេសាទនិងការបែងចែកតំបន់គ្រប់គ្រងជលផលត្រូវបានលើកយកមកពិភាក្សាជាអាទិភាពក្នុងជំពូកទី១។ រីឯនីតិវិធីធ្វើអត្តសញ្ញាណកម្មដែននេសាទនិងផែនទីនឹងត្រូវបានពិភាក្សានៅក្នុងជំពូកទី២ បន្ទាប់។

## ជំពូកទី១: សញ្ញាណដែននេសាទនិងតំបន់គ្រប់គ្រងជលផល

### ១- សញ្ញាណដែននេសាទ

សញ្ញាណនៃដែននេសាទរួមមាន ដែនដីលិចទឹកអចិន្ត្រៃយ៍ ដែនដីដែលទទួលរបបទឹកទន្លេមេគង្គ និងដែនដីដែលទទួលរបបទឹកជោរនាចនៃសមុទ្រដែលមានតួនាទីសំខាន់បម្រើឱ្យការនេសាទគ្រប់ប្រភេទនិងការការពារប្រព័ន្ធអេកូឡូស៊ីជលផលក្នុងនោះរួមមាន៖

-ដែនដីលិចទឹកអចិន្ត្រៃយ៍មានជាអាទិ៍ សមុទ្រ ទន្លេ ដៃទន្លេ បឹង ព្រែក ស្ទឹង អូរ អាងទឹក និងប្រឡាយ

-ដែនដីដែលទទួលរបបទឹកទន្លេមេគង្គមានជាអាទិ៍ ត្រពាំង រណ្ដៅ វាលភក់ល្បាប់ វាលទំនាបដែលលិចទឹកក្នុងរដូវទឹកជំនើងនិងនាទីព្រៃលិចទឹក

-ដែនដីដែលទទួលរបបទឹកជោរ នាចនៃសមុទ្រមានជាអាទិ៍ នាទីព្រៃកោងកាង (មាត្រា៨ នៃនីតិជលផល)។

មានន័យថា ដែនដីដែលលិចទឹកអចិន្ត្រៃយ៍ឬដែនដីដែលទទួលរបបទឹកទន្លេមេគង្គ និងដែនដីដែលទទួលរបបទឹកជោរ នាចនៃសមុទ្រទាំងនោះ ត្រូវមានតួនាទីសំខាន់បម្រើឱ្យការនេសាទគ្រប់ប្រភេទនិងការការពារនូវប្រព័ន្ធអេកូឡូស៊ីជលផល។ ប៉ុន្តែខ្លឹមសារខាងលើ គឺជាសញ្ញាណនៃដែននេសាទតែប៉ុណ្ណោះ។ ឯចំណុចសំខាន់ គឺការកំណត់ព្រំ-ប្រទល់ដែននេសាទ។ បានសេចក្ដីថា ដែននេសាទត្រូវតែមានការកំណត់ព្រំប្រទល់ច្បាស់លាស់ដោយលិខិតបទដ្ឋានគតិយុត្ត។ មាត្រា៩ នៃនីតិជលផលឆ្នាំ២០០៦ បានបញ្ញត្តិថា:"*ព្រំប្រទល់ដែននេសាទត្រូវកំណត់ដោយអនុក្រឹត្យ*"។

### ២- តំបន់គ្រប់គ្រងជលផល

តំបន់គ្រប់គ្រងជលផលរួមមាន តំបន់គ្រប់គ្រងជលផលទឹកសាបនិងតំបន់គ្រប់គ្រងជលផលសមុទ្រ។

### ក- តំបន់គ្រប់គ្រងជលផលទឹកសាប

តំបន់គ្រប់គ្រងជលផលទឹកសាបរួមមាន៖

-ឡូត៍នេសាទដែលទុកសម្រាប់សម្បទានដល់ការវិនិយោគឬជួលឱ្យធ្វើអាជីវកម្ម។ ឡូត៍នេសាទ សំដៅដល់ចំណាត់ថ្នាក់នៃដែននេសាទទឹកសាប ហើយត្រូវបានកំណត់ភូមិសាស្ត្រជាក់លាក់ដែលមានប្រព័ន្ធបឹង ព្រែក ព្រៃលិចទឹក ធនធានជលផលនិងជីវចម្រុះដែលកំណត់នូវការកកើត និងការរីកធំធាត់របស់មច្ឆជាតិ វារីសត្វ និងវារីរុក្ខជាតិ ព្រមទាំងកំណត់ទីតាំងនិងពេលវេលាធ្វើអាជីវកម្មជាក់លាក់ដោយមិនជះឥទ្ធិពលដល់ទីតាំងផ្សេងទៀត។

-កន្លែងអភិរក្សជលផលដែលជាជម្រករក្សាពូជវារីសត្វនិងវារីរុក្ខជាតិ។ កន្លែងអភិរក្សជលផល សំដៅដល់ចំណាត់ថ្នាក់នៃដែននេសាទទឹកសាបឬសមុទ្រ ហើយត្រូវបានកំណត់ភូមិសាស្ត្រជាក់លាក់សម្រាប់វារីសត្វឬរុក្ខជាតិជ្រកពួន ពង កូនរីកធំធាត់ឬរីកលូតលាស់។ កន្លែងអភិរក្សជលផល ជាថ្នាលពូជនិងជាតំបន់ការពារធនធានជលផល

ហើយពុំអនុញ្ញាតឱ្យប្រព្រឹត្តសកម្មភាពណាមួយដែលអាចនាំឱ្យមានផលប៉ះពាល់ដល់ធនធានជលផល ក្រៅពីការសិក្សាស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផលស្របតាមគោលការណ៍ត្រឹមត្រូវ (ឧបសម្ព័ន្ធនៃនីតិជលផលឆ្នាំ២០០៦)។

-នាទីព្រៃលិចទឹករួមមានៈ តំបន់ព្រៃលិចទឹកដែលជាជម្រកចាំបាច់របស់វារីសត្វក្នុងការស្វែងរកចំណីឬកន្លែងពងកូននិងតំបន់លិចទឹកដែលត្រូវការពារ។ នាទីព្រៃលិចទឹក សំដៅដល់ផ្ទៃដីលិចទឹកដោយរបបទឹកទន្លេមេគង្គឬដីលិចទឹកដោយរបបទឹកជោរ នាចនៃសមុទ្រដែលគ្របដណ្តប់ដោយព្រៃលិចទឹកនិងព្រៃកោងកាង។ នាទីព្រៃលិចទឹកនិងព្រៃកោងកាងរាប់បញ្ចូលទាំងតំបន់លិចទឹកដែលត្រូវការពារ (ឧបសម្ព័ន្ធនៃនីតិជលផលឆ្នាំ២០០៦)។

ចំពោះតំបន់លិចទឹកដែលត្រូវការពាររួមមានៈ ដីលិចទឹកដែលស្ថិតនៅក្នុងនាទីឡូត៍នេសាទនិងស្ថិតនៅក្នុងនាទីព្រៃលិចទឹកនិងព្រៃកោងកាងដែលត្រូវការពារសម្រាប់ដាំឬរក្សាទុកឱ្យដុះព្រៃឡើងវិញ ដើម្បីរក្សាលំនឹងប្រព័ន្ធអេកូឡូស៊ីជលផល (មាត្រា២៧ នៃនីតិជលផលឆ្នាំ២០០៦)។

-កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណីឬសហគមន៍ធ្វើនេសាទ

-កន្លែងនេសាទបម្រុង ជាកន្លែងនេសាទទាំងឡាយដែលពុំបានធ្វើការចាត់ថ្នាក់។ កន្លែងនេសាទបម្រុងសំដៅដល់ផ្នែកមួយនៃដែននេសាទទឹកសាបដែលមិនមែនជាឡូត៍នេសាទ កន្លែងអភិរក្សជលផល នាទីព្រៃលិចទឹកកន្លែងនេសាទគ្រួសារ ឬទំនាបលិចទឹកក្នុងរដូវទឹកដំឡើង។ កន្លែងនេសាទបម្រុងមិនត្រូវបានធ្វើការចាត់ថ្នាក់ជាតំបន់គ្រប់-គ្រងជលផលជាក់លាក់ឡើយ ហើយត្រូវបានអនុញ្ញាតឱ្យធ្វើនេសាទបានតែការនេសាទ២ ប្រភេទគឺ ការនេសាទជាលក្ខណៈគ្រួសារនិងការធ្វើនេសាទជាលក្ខណៈសិប្បកម្ម។ កន្លែងនេសាទបម្រុងរួមមាន ទន្លេ ស្ទឹង ព្រែក បឹង អាង-ធម្មជាតិ ឬត្រពាំង។ល។

-កន្លែងនេសាទសម្រាប់អភិវឌ្ឍវារីវប្បកម្ម

-ទំនាបលិចទឹកក្នុងរដូវដំឡើង។ ទំនាបលិចទឹកនៅរដូវដំឡើង សំដៅដល់ដីទំនាបដែលទទួលរបបទឹកទន្លេមេគង្គដែលមិនមែនជាទីតាំងឡូត៍នេសាទ ព្រៃលិចទឹក កន្លែងអភិរក្សជលផល កន្លែងនេសាទគ្រួសារ និងកន្លែងនេសាទបម្រុងរួមមាន វាលទំនាប វាលស្មៅ វាលស្រែចំការ និងដីដែលទឹកទន្លេមេគង្គឡើងដល់ ហើយដែលជាទីវាលទំនាបដ៏សំខាន់សម្រាប់មច្ឆជាតិធ្វើចរាចរណ៍រកកន្លែងពងកូននិងស្វែងរកចំណីនៅក្នុងរដូវបិទនេសាទ (មាត្រា១០ នៃនីតិជលផលឆ្នាំ២០០៦ និងឧបសម្ព័ន្ធ)។

ការបែងចែកដែននេសាទទឹកសាបខាងលើ ត្រូវបានចាត់ទុកថា <u>តំបន់គ្រប់គ្រងជលផល</u> (មាត្រា១០ នៃនីតិជលផលឆ្នាំ២០០៦។

ចំពោះតំបន់គ្រប់គ្រងជលផលទឹកសាប មានតំបន់គ្រប់គ្រងជលផលមួយចំនួនមានការកំណត់ព្រំប្រទល់និងផែនទីច្បាស់លាស់ជាអាទិ៍ ឡូត៍នេសាទ កន្លែងអភិរក្សជលផល កន្លែងនេសាទសហគមន៍ និងការកំណត់នាទី

ព្រៃលិចទឹកស្ថិតនៅក្នុងខេត្តទាំង៦ ជុំវិញបឹងទន្លេសាប។ ដោយឡែក ព្រំប្រទល់និងផែនទីឡូត៍នេសាទត្រូវតែលើកយកមកពិភាក្សាឱ្យបានហ្មត់ចត់និងស៊ីជម្រៅដោយហេតុថា ជាផ្នែកមួយនៃភស្តុតាងគតិយុត្តក្នុងការធ្វើអត្តសញ្ញាណដែននេសាទឡើងវិញ បន្ទាប់ពីការកំណត់ព្រំប្រទល់និងផែនទីនេះបានរៀបចំនិងធ្វើឡើងតាំងពីក្នុងទសវត្ស១៩២០មកម្ល៉េះ ហើយពុំធ្លាប់បានធ្វើបច្ចុប្បន្នភាពម្តងណាឡើយរួមទាំងការកាត់បន្ថយផ្នែកខ្លះនៃឡូត៍ឬលុបឡូត៍នេសាទមួយចំនួននៅឆ្នាំ២០០០ និងរំសាយឡូត៍នេសាទទាំងអស់ (ឡូត៍នេសាទបឹងព្រែក) នៅឆ្នាំ២០១២ នេះក៏ដោយ។ ចាប់ពីទសវត្ស១៩២០ មកដល់បច្ចុប្បន្ន គឺមានរយៈពេលជាង៨០ ឆ្នាំ ដូចនេះ ការប្រែប្រួលនៃធម្មជាតិពិតជាកើតមានឡើងជាសត្យានុម័ត។ ជាក់ស្តែង ក្នុងផ្ទៃឡូត៍នេសាទទាំងមូលមានផ្នែកខ្លះបានប្រែក្លាយជា ភូមិអ្នកស្រុក វត្តអារាម សាលារៀន មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក...។ល។និង។ល។ ប៉ុន្តែក៏មានផ្នែកខ្លះបាននិងកំពុងបម្រើវិស័យជលផលនៅឡើយដែរ។ ដូចនេះជាគោលការណ៍ ការដាក់ឱ្យប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋ គឺត្រូវប្រើប្រាស់ឱ្យបានចំទិសដៅនៃទ្រព្យជាដាច់ខាត ដើម្បីធានាការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។

បញ្ហាប្រឈមចំពោះមុខនោះគឺ ឡូត៍នេសាទដែលបានលុបទាំង២ លើកកន្លងមក រាជរដ្ឋាភិបាលសម្រេចឱ្យរៀបចំនិងបង្កើតសហគមន៍នេសាទ ដើម្បីគ្រប់គ្រងបន្ត ហើយតម្រូវឱ្យបង្កើតជាកន្លែងអភិរក្សជលផលនិងកន្លែងទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ ឬកន្លែងនេសាទបម្រុង។ ដូចនេះ ការផ្ទេរឡូត៍នេសាទពីអាជីវករឡូត៍នេសាទមកឱ្យសហគមន៍នេសាទគ្រប់គ្រងនោះ គឺត្រូវប្រគល់តាមព្រំប្រទល់និងផែនទីឡូត៍នេសាទទាំងអស់។ ប៉ុន្តែជាក់ស្តែង ឡូត៍នេសាទនោះមានផ្នែកខ្លះនៃផ្ទៃឡូត៍បានក្លាយជាភូមិអ្នកស្រុក វត្តអារាម សាលារៀន ឬមណ្ឌលសុខភាព...រួចទៅហើយ។ ដូច្នេះ ជាបញ្ហាមួយសម្រាប់ការកំណត់ព្រំប្រទល់និងផែនទីកន្លែងសហគមន៍នេសាទ និងកាន់តែស្មុគ្រស្មាញថែមទៀតនោះ គឺអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទឆ្នាំ២០០៧ បានកំណត់ថាកន្លែងនេសាទសហគមន៍គឺ ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។ ជាក់ស្តែង មាត្រា៣ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទបានបញ្ញត្តិថាៈ*"កន្លែងនេសាទសហគមន៍គឺ ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ"*។

ប៉ុន្តែទោះបីយ៉ាងនេះក៏ដោយ ស្មេរនឹងខិតខំស្រាវជ្រាវរិះរកនូវវិធីគតិយុត្តពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាឱ្យខាងតែបានដោយអនុលោមតាមនីតិវិធីជាធរមាន។

មុននឹងផ្តល់ដំណោះស្រាយដ៏លំបាកនិងស្មុគស្មាញនេះ គប្បីមានការស្រាវជ្រាវនិងស្វែងយល់អំពីប្រវត្តិនៃការបង្កើតនិងការវិវត្តិនៃឡូត៍នេសាទនៅក្នុងព្រះរាជាណាចក្រកម្ពុជាជាមុនសិនថា តើឡូត៍នេសាទបានចាប់កកើតពីពេលណាមក ហើយបានបញ្ចប់ទៅវិញយ៉ាងដូចម្តេច ?

### ខ.ប្រវត្តិសង្ខេបនៃឡូត៍នេសាទនៅកម្ពុជា

ការគ្រប់គ្រងជលផលនៅព្រះរាជាណាចក្រកម្ពុជា ជាពិសេសការគ្រប់គ្រងឡូត៍នេសាទមានការកែសម្រួល

ជាបន្តបន្ទាប់ពីសង្គមមួយទៅសង្គមមួយតាមរបត់នយោបាយនៃការគ្រប់គ្រងរដ្ឋ ដែលកម្ពុជាបានឆ្លងកាត់នៅក្នុងទំព័រប្រវត្តិសាស្ត្ររបស់ខ្លួន។ ការស្រាវជ្រាវនូវអតីតកាល គឺដើម្បីឆ្លុះបញ្ចាំងនូវអ្វីៗដែលបានកើតឡើងក្នុងអតីតកាលកន្លងមក ហើយបច្ចុប្បន្នកាលត្រូវឆ្លើយតបដោយធ្វើការកែសម្រួលឱ្យបានប្រសើរជាងជាដាច់ខាតដោយហេតុថា អ្វីៗទាំងអស់ពុំមែនសុទ្ធតែត្រូវបានកាយកប់ដោយប្រវត្តិសាស្ត្រនោះទេ។

ចំពោះលទ្ធផលនៃការស្រាវជ្រាវដ៏ស្តួចស្តើងនិងការអធិប្បាយនេះ គឺពុំបានលើកយកមកអធិប្បាយដោយក្បោះក្បាយលំអិតទាំងស្រុងនូវប្រវត្តិសាស្ត្រឡូត៍នេសាទនៅព្រះរាជាណាចក្រកម្ពុជាទេ ដោយហេតុថា កម្មវត្ថុនៃការស្រាវជ្រាវនេះ គឺពុំមានមហិច្ឆតាដល់ថ្នាក់នោះទេ។ ប៉ុន្តែអ្វីដែលស្មេរចង់បាននោះ គឺប្រវត្តិនិងការវិវឌ្ឍន៍សង្ខេបនៃការគ្រប់គ្រងឡូត៍នេសាទនៅព្រះរាជាណាចក្រកម្ពុជានៅក្នុងសម័យកាលនីមួយៗ ដើម្បីលើកយកមកលាតត្រដាងជូនដល់មន្ត្រីរដ្ឋបាលជលផលគ្រប់រូបនិងគ្រប់ជាន់ថ្នាក់ ព្រមទាំងពលរដ្ឋកម្ពុជាទាំងអស់ដែលមានបំណងស្វែងយល់អំពីប្រវត្តិនៃការគ្រប់គ្រងឡូត៍នេសាទនៅកម្ពុជាដោយហេតុថា ការគ្រប់គ្រងឡូត៍នេសាទនៅកម្ពុជា តែងបត់បែនទៅតាមរបត់នយោបាយនៃសង្គមដែលពុំមែនជាការគ្រប់គ្រងតាមលក្ខណៈបច្ចេកទេសសុទ្ធសាធនោះឡើយ។

តាមឯកសារប្រវត្តិនៃការគ្រប់គ្រងវិស័យជលផលនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ របស់ **ឯកឧត្តម ណៅ ធូក** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផលនិងលោក **ម៉ូ សេខឌី** អតីតប្រធានស្នាក់ការអធិការកិច្ចសមុទ្រដែលចូលនិវត្តន៍នោះ បានសង្ខេបអំពីដំណើរវិវត្តន៍នៃឡូត៍នេសាទនៅព្រះរាជាណាចក្រកម្ពុជា បង្រួមមកត្រឹម២ ដំណាក់កាលជាសំខាន់គឺៈ សម័យកាលអាណានិគមនិយមបារាំង(១)និងសម័យកាលកម្ពុជាទទួលបានឯករាជ្យ(២)។

(១)**សម័យកាលអាណានិគមនិយមបារាំង**(ថ្ងៃទី១១ សីហា ឆ្នាំ១៨៦៣ ដល់ឆ្នាំ១៩៥៣)

***-សម័យកាលចន្លោះឆ្នាំ១៨៦៣-១៨៧២***

ក្នុងសម័យកាលនេះ រាល់ទ្រព្យសម្បត្តិទាំងអស់ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលអាណានិគមបារាំងក្នុងនោះ មានឡូត៍នេសាទផងដែរដែលរដ្ឋបាលអាណានិគមបារាំងបានធ្វើការចាត់ចែងនិងអនុញ្ញាតឱ្យធ្វើអាជីវកម្មនេសាទជាលក្ខណៈឧស្សាហកម្មនិងពាណិជ្ជកម្មនូវធនធានជលផល ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជាតិតាមរយៈការបង្កើតពន្ធក្នុងមុខរបរនេសាទ។

នៅក្នុងកំឡុងឆ្នាំ១៨៦៤ រជ្ជកាលគ្រប់គ្រងដោយ**ព្រះបាទនរោត្តម** (១៨៥៩-១៩០៤) រដ្ឋបាលអាណានិគមបារាំងបានបែងចែកផ្ទៃទឹកនៅបឹងទន្លេសាបជាកន្លែង<u>សម្បទាន</u> ដើម្បីអនុញ្ញាតឱ្យធ្វើអាជីវកម្មនេសាទជាលក្ខណៈឧស្សាហកម្មក្នុងនោះរួមមាន ខេត្តកំពង់ធំចំនួន១ កន្លែង ខេត្តពោធិ៍សាត់ចំនួន២ កន្លែង និងខេត្តកំពង់ឆ្នាំងចំនួន២ កន្លែង។

ចំពោះកន្លែងសម្បទាននីមួយៗ រដ្ឋបាលអាណានិគមបារាំងបានជួលផ្តាច់មុខទៅឱ្យមេសង្វៀនធំ ដែលបច្ចុប្បន្នហៅថា អាជីវករឡូត៍នេសាទ។ ចំណែកមេសង្វៀនធំវិញ ភាគច្រើនជាជនជាតិចិនហើយមានសិទ្ធិគ្រប់គ្រងនិងធ្វើអាជីវកម្មនេសាទ។ ម្យ៉ាងទៀត មេសង្វៀនធំៗទាំងនោះគឺ ពុំបានធ្វើអាជីវកម្មនេសាទដោយផ្ទាល់ទេ ពីព្រោះពួកគេ មានសិទ្ធិធ្វើការបែងចែកកន្លែងសម្បទានធ្វើអាជីវកម្មនេសាទរបស់ខ្លួនដែលខ្លួនបានទទួលសិទ្ធិកាន់កាប់នោះ លក់បន្តទៅឱ្យមេសង្វៀនរងដែលបច្ចុប្បន្នហៅថា អ្នកជួលបន្តទៀតបាន ដើម្បីយកប្រាក់ចំណេញផ្ទាល់ខ្លួននិងមានសិទ្ធិកំណត់លើការប្រមូលប្រាក់ពន្ធ លើមុខរបរអំពីការធ្វើអាជីវកម្មនេសាទនៅកន្លែងសម្បទានដែលខ្លួនកាន់កាប់បានទៀត។ ក្រោយមក បន្ទាប់ពីទទួលបានបទពិសោធន៍និងប្រាក់ចំណូលអំពីការជួលកន្លែងសម្បទានផងនោះ រដ្ឋបាលអាណានិគមបារាំងក៏បានធ្វើការរៀបចំកន្លែងនេសាទសំខាន់ៗ មួយចំនួនទៀត ដើម្បីបង្កើតជាកន្លែងសម្បទានរកប្រាក់ចំណូលរដ្ឋ។ ដោយឡែក ខេត្តបាត់ដំបង និងខេត្តសៀមរាបវិញដែលជាខេត្តស្ថិតនៅជាប់នឹងបឹងទន្លេសាបដែរនោះ គឺគ្មានកន្លែងសម្បទាននោះទេ ដោយហេតុថា ក្នុងគ្រានោះខេត្តទាំង២បានស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រទេសថៃឡង់ដ៏ឬសៀមរហូតមកដល់ឆ្នាំ១៩០៧។ ប៉ុន្តែក្នុងគ្រានោះ ក៏មានការអនុញ្ញាតឱ្យធ្វើនេសាទដោយប្រើប្រាស់ឧបករណ៍នេសាទតូចតាចឬជាលក្ខណៈគ្រួសារផងដែរ ប៉ុន្តែតម្រូវឱ្យអ្នកនេសាទទាំងនោះបង់ពន្ធជូនភ្នាក់ងារប្រមូលពន្ធដែលស្ថិតនៅតាមប៉ុស្តិ៍ត្រួតពិនិត្យ។ តាមឯកសារស្រាវជ្រាវនិងការផ្តល់ព័ត៌មានរបស់ **លោក ហាម ម៉េត** អតីតប្រធានការិយាល័យអាជីវកម្មនេសាទនិងជាមន្ត្រីជលផលចូលនិវត្តន៍បានបញ្ជាក់ថា ប៉ុស្តិ៍ត្រួតពិនិត្យនេះមាននៅក្នុងខេត្តសៀមរាបចំនួន២ កន្លែង គឺ នៅកំពង់ឃ្លាំងនិងចុងឃ្នាស។ ខេត្តបាត់ដំបងមាន២ កន្លែងគឺ បាក់ព្រា និងព្រែកទាល់។ ឯខេត្តពោធិ៍សាត់មាន៣ កន្លែងគឺ ដីរនាត រាំងទិល និងកំពង់ហ្លួង។ ខេត្តកំពង់ធំមាន១ កន្លែងនៅផាត់សណ្តាយនិងខេត្តកំពង់ឆ្នាំងមាន២ កន្លែងគឺ ប្រឡាយមាសនិងចំណុចក្បាលព្រែកច្រឡៃ។

**-សម័យកាលចន្លោះឆ្នាំ១៨៧៣-១៨៨៩**

នៅក្នុងសម័យកាលនោះ គឺមានការបង្កើតកន្លែងសម្បទាននេសាទជាច្រើន។ រីឯការនេសាទ ក៏មានការប្រើប្រាស់នូវប្រភេទឧបករណ៍នេសាទធំៗ និងបច្ចេកវិទ្យាដែលមានការរីកចម្រើនគួរឱ្យចាប់អារម្មណ៍ជាអាទិ៍ ការបោះរបាំងធ្នស់ចាប់ត្រី ការធ្វើនេសាទដោយប្រើឧបករណ៍នេសាទលបណឬវ៉ារ ការធ្វើនេសាទដោយឧបករណ៍អួនធ្វើអំពីសរសៃធ្មៃ និងការធ្វើនេសាទដោយឧបករណ៍ដាយចាប់ត្រី។ ជាមួយគ្នានេះផងដែរ មានចំណុចមួយគួរឱ្យកត់សម្គាល់គឺ ការនាំចូលឧបករណ៍នេសាទ និងសម្ភារៈនេសាទអំពីប្រទេសចិនដែលពុំតម្រូវឱ្យបង់ពន្ធជូនរដ្ឋឡើយ។ ចំណែក ការនាំចេញផលិតផលនេសាទវិញក៏ពុំមានការបង់ពន្ធជូនរដ្ឋដែរ។ នៅក្នុងសម័យកាលនោះ គេសង្កេតឃើញមានជនជាតិខ្មែរបានចាប់ផ្តើមធ្វើនេសាទ ដោយប្រើប្រាស់ឧបករណ៍នេសាទដែលមានលក្ខណៈអាជីវកម្មតាមរយៈការជួលបន្តពីអ្នកមានសិទ្ធិកាន់កាប់ដែលរដ្ឋបាលអាណានិគមបារាំងទទួលស្គាល់។ តាមឯកសារស្រាវជ្រាវបានបញ្ជាក់ថា នៅខេត្តពោធិ៍សាត់ក្នុងពេលនោះមានអ្នកនេសាទជនជាតិខ្មែរចំនួន១០% ជនជាតិវៀតណាមចំនួន៦០%

និងជនជាតិចិនចំនួន៣០% បានទិញបន្តពីមេសង្វៀនធំៗ ដើម្បីធ្វើនេសាទជាលក្ខណៈអាជីវកម្ម។ រីឯការធ្វើនេសាទដោយប្រើប្រាស់ឧបករណ៍តូចតាចឬឧបករណ៍នេសាទគ្រួសារសម្រាប់ផ្គត់ផ្គង់គ្រួសារវិញ គឺអ្នកនេសាទមានសិទ្ធិធ្វើនេសាទដោយសេរី គ្រប់ទីកន្លែង និងគ្រប់រដូវ លើកលែងតែក្នុងកន្លែងសម្បទាននេសាទ។

ចំពោះការប្រមូលពន្ធលើវិស័យនេសាទ រដ្ឋបាលអាណានិគមបារាំងបានបង្កើតកន្លែងសម្បទាននេសាទជាច្រើនបន្ថែមទៀត ដើម្បីជួលតាមរយៈការដេញថ្លៃក្នុងគោលបំណងបង្កើនប្រាក់ចំណូលរដ្ឋ។ ប៉ុន្តែការប្រមូលពន្ធលើមុខរបរនេសាទ រដ្ឋបាលអាណានិគមបារាំងបានប្រគល់សិទ្ធិផ្តាច់មុខជូនមេសង្វៀនធំៗបន្ថែមទៀត ដើម្បីកំណត់និងទារប្រាក់ពន្ធជំនួស។ ចំណុចដែលគួរឱ្យកត់សម្គាល់មួយទៀតនោះគឺ មេសង្វៀនធំៗ ភាគច្រើនជាជនជាតិចិន។

មេសង្វៀនធំៗ បន្ទាប់ពីខ្លួនបានទទួលសិទ្ធិកាន់កាប់កន្លែងសម្បទាននេសាទពីរដ្ឋបាលអាណានិគមបារាំងរួច ហើយបានធ្វើការបែងចែកកន្លែងសម្បទាននេសាទដែលខ្លួនកាន់កាប់ប្រគល់ទៅឱ្យមេសង្វៀនរងបន្តទៀត តាមតម្លៃព្រមព្រៀងគ្នា។ ចំណែកទឹកប្រាក់មេសង្វៀនធំទទួលបានពីមេសង្វៀនរងវិញគឺ មានចំនួនទ្វេដងបើប្រៀបធៀបនឹងទឹកប្រាក់ដែលត្រូវបង់ចូលឃ្លាំងព្រះរាជទ្រព្យ (បេឡាព្រះមហាក្សត្រ)។ រីឯមេសង្វៀនរង បន្ទាប់ពីបានទទួលសិទ្ធិកាន់កាប់លើផ្នែកមួយឬទាំងស្រុងនៃកន្លែងសម្បទាននេសាទពីមេសង្វៀនធំ មេសង្វៀនរងក៏មានសិទ្ធិជួលបន្តទៅឱ្យមេសង្វៀនរងផ្សេងទៀតបានថែមទៀតដោយអនុវត្តតាមការព្រមព្រៀងគ្នា ប៉ុន្តែគេសង្កេតឃើញថា មេសង្វៀនរងក្រោយនេះភាគច្រើនគឺ ជាអ្នកពុំសូវមានធនធានឬប្រាក់កាសទេ។

កត្តានេះហើយ ទើបមានឈ្មួញកណ្តាលច្រើនចាប់ពី០៥ នាក់រហូតដល់០៧ នាក់ មុននឹងឈានទៅដល់អ្នកធ្វើអាជីវកម្មនេសាទពិតប្រាកដ។ ចំណែកមេសង្វៀនធំនិងមេសង្វៀនរងវិញ គឺទទួលបានប្រាក់ចំណេញខ្ពស់កប់ពពកដោយពុំបានធ្វើអាជីវកម្មនេសាទឬបំពេញកាតព្វកិច្ចអ្វីទាំងអស់។ ដោយឡែក ការធ្វើកិច្ចសន្យាវិញពួកគេបានធ្វើកិច្ចសន្យាបន្តបន្ទាប់រវាងឈ្មួញកណ្តាលនិងអ្នកធ្វើអាជីវកម្មនេសាទពិតប្រាក ហើយក្នុងកិច្ចសន្យានេះទៀតមានចែងសន្យាដែលមានលក្ខណៈស្មុគស្មាញនិងសាំញ៉ាំដែលជាប្រភពបង្កឱ្យមានទំនាស់កើតឡើងមិនឈប់ឈរពីព្រោះពុំមានគំរូកិច្ចសន្យាឬការណែនាំអំពីភាគីរដ្ឋនោះទេ។ បញ្ហានេះ ចន្លោះឆ្នាំ១៨៧២-១៨៨៦ ក្នុងខេត្តព្រៃវែងមានប្រជាពលរដ្ឋ និងអ្នកនេសាទច្រើននាក់បានងើបបះបោរដណ្តើមយកកន្លែងសម្បទាននេសាទផ្តាច់មុខពីមេសង្វៀនធំមកវិញ ដើម្បីធ្វើនេសាទផ្គត់ផ្គង់គ្រួសារ និងទាមទារផ្នែកន្លែងសម្បទាននេសាទចំនួន៧% រក្សាទុកជូនប្រជាពលរដ្ឋធ្វើនេសាទចិញ្ចឹមជីវិត។ បញ្ហានេះហើយ ទើបរដ្ឋបាលអាណានិគមបារាំងសម្រេចរៀបចំសៀវភៅបន្ទុកមួយឡើងដើម្បីដាក់ឱ្យប្រើប្រាស់ជាផ្លូវការដល់អ្នកកាន់កាប់

កន្លែងសម្បទាននេសាទ។ ខ្លឹមសារនិងកាតព្វកិច្ចក្នុងសៀវភៅបន្ទុករួមមានៈ

-ការធានាទុកចិត្តចំពោះរដ្ឋ ដោយមានអ្នកធានាចំនួន២ នាក់ថា បានបង់ប្រាក់ធានា

-សិទ្ធិប្តឹងតុលាការខេត្ត បើសិនមានជម្លោះណាមួយកើតឡើងអំពីកិច្ចសន្យានេសាទ

-ដកឧបករណ៍និងសម្ភារៈនេសាទពីទីតាំងធ្វើអាជីវកម្មនេសាទនៅថ្ងៃទី១៥ ខែមិថុនារៀងរាល់ឆ្នាំដើម្បីទុកឱ្យជលយានធ្វើចរាចរដោយសេរីក្នុងទន្លេឬព្រែក។

ក្រៅពីកន្លែងសម្បទាននេសាទដែលត្រូវជួលនោះ ត្រូវទុកឱ្យប្រជាពលរដ្ឋក្នុងភូមិធ្វើនេសាទតាមប្រពៃណីទំនៀមទម្លាប់របស់ពួកគេ។ ចំណែកកន្លែងសម្បទាននេសាទដែលកន្លងមកបានជួលនោះ ត្រូវបានកែសម្រួលមកជាការដាក់ឱ្យដេញថ្លៃវិញ។ ការដេញថ្លៃ ត្រូវបានធ្វើឡើងជាទៀងទាត់តាមវិធីលក់វាយសម្រាប់សម្បទានិក។ ចំណែករដ្ឋបាលអាណានិគមបារាំង គឺរង់ចាំតែទទួលយកតម្លៃណាដែលខ្ពស់ជាងគេប៉ុណ្ណោះ។ ឯអ្នកដេញថ្លៃ គឺជាមេសង្វៀនធំដែលមានឈ្មោះដូចមុនដដែល និងមានសិទ្ធិបែងចែកកន្លែងសម្បទាននេសាទដែលខ្លួនដេញថ្លៃបានជួលបន្តទៅឱ្យអ្នកផ្សេងឬរក្សាទុកផ្នែកណាមួយសម្រាប់ធ្វើអាជីវកម្មផ្ទាល់ខ្លួន។ ដូចគ្នាផងដែរ មេសង្វៀនរងក៏អាចប្រគល់កន្លែងសម្បទាននេសាទដែលខ្លួនកាន់កាប់ដោយធ្វើកិច្ចសន្យាដែលខ្លួនបានទទួលសិទ្ធិអំពីមេសង្វៀនធំទៅឱ្យអ្នកទី៣ ដែរដើម្បីទទួលបានផលចំណេញ។

សរុបមក ការរៀបចំដេញថ្លៃនិងការអនុវត្តជាក់ស្តែងក្រោយនេះ គឺគ្មានអ្វីខុសពីការជួលដូចមុនឡើយដោយហេតុថា មេសង្វៀនធំនិងឈ្មួញកណ្តាលនៅតែបន្តទទួលបានផលចំណេញដូចមុនដដែល។

ដោយសារបញ្ហានេះហើយ ទើបធ្វើឱ្យរដ្ឋបាលអាណានិគមបារាំងចាប់ផ្តើមធ្វើការសិក្សាស្រាវជ្រាវអំពីការនេសាទទឹកសាបជាបន្តបន្ទាប់ដើម្បីធ្វើការគ្រប់គ្រងឱ្យមានស្ថិរភាព ជាពិសេសការបង្កើនប្រាក់ចំណូលវិស័យនេសាទនៅកម្ពុជា។

ទន្ទឹមនឹងការសិក្សាស្រាវជ្រាវខាងលើ រដ្ឋបាលអាណានិគមបារាំងក៏បានដាក់ចេញនូវសារាចរមួយលេខ៤០ ចុះ ថ្ងៃទី០៤ ខែមេសា ឆ្នាំ១៨៨០ ស្តីពីការជំរឿននិងការចាត់ថ្នាក់កន្លែងនេសាទទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សារាចរនេះ មានគោលបំណងធ្វើការវាយតម្លៃឱ្យបានច្បាស់លាស់នូវតម្លៃនៃកន្លែងសម្បទាននេសាទនីមួយៗ និងកំណត់ព្រំប្រទល់នៃកន្លែងសម្បទាននេសាទ ដើម្បីចៀសវាងជម្លោះអចិន្ត្រៃយ៍រវាងមេសង្វៀននិងអ្នកជួលបន្តធ្វើអាជីវកម្មពិតប្រាកដដែលតែងកើតឡើងមិនឈប់ឈរកន្លងមក។ ក្រោយមកនៅឆ្នាំ១៩០៧ កន្លែងសម្បទាននេសាទទាំងអស់បានកែសម្រួលមកជាឡូត៍នេសាទវិញនិងមានការកំណត់ព្រំប្រទល់ច្បាស់លាស់ ព្រមទាំងមានការដាក់ឱ្យដេញថ្លៃជាសាធារណៈផងដែរ។

**-សម័យកាលចន្លោះឆ្នាំ១៨៩០-១៩២៩**

ក្នុងអំឡុងឆ្នាំ១៩០៨ នេះ ឡូត៍នេសាទទាំងអស់ត្រូវបានដាក់ឱ្យដេញថ្លៃនិងអនុញ្ញាតឱ្យធ្វើអាជីវកម្មនេសាទចំនួន៣ រដូវ។ បន្ទាប់មកទៀត រដ្ឋបាលអាណានិគមបារាំងក៏បានដាក់ចេញនូវព្រះរាជប្បញ្ញត្តិមួយទៀតលេខ៣៥ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩០៨ ស្តីពីការលុបចោលកន្លែងសម្បទាននេសាទ។ ព្រះរាជប្បញ្ញត្តិលេខ៣៥ នេះ ត្រូវបាន

ឡាយព្រះហស្តលេខាដោយ **ព្រះបាទស៊ីសុវត្ថិ** និងបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយសេចក្តីសម្រេចលេខ៦៧០ ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩០៨ ដោយទេសាភិបាលប្រចាំនៅកម្ពុជា (Resident Superieur)។ ខ្លឹមសារសំខាន់ៗ នៃព្រះរាជប្បញ្ញត្តិលេខ៣៥ រួមមានៈ

១-កន្លែងសម្បទាននេសាទទាំងអស់នៅព្រះរាជាណាចក្រកម្ពុជា ត្រូវបានលុបចោល។

២-បញ្ឈប់ការរឹបជាន់ដោយលុបបំបាត់អ្នកកណ្តាលចង្រៃ។

ប៉ុន្តែបញ្ហាខាងលើ រដ្ឋអាណានិគមបារាំងក៏បានផ្តល់សិទ្ធិទូលំទូលាយដល់ប្រជាពលរដ្ឋក្នុងការធ្វើនេសាទដោយសេរីនិងរៀបចំកន្លែងនេសាទជា២ ប្រភេទដូចខាងក្រោមៈ

-កន្លែងនេសាទផ្តាច់មុខរបស់រដ្ឋទុកសម្រាប់ជួលដែលទទួលស្គាល់ដោយរដ្ឋតាមរយៈកិច្ចសន្យាឬសៀវភៅបន្ទុកនិងការដេញថ្លៃ (ឡូត៍នេសាទ)

-កន្លែងអនុញ្ញាតឱ្យធ្វើនេសាទដោយសេរីទៅតាមប្រភេទឧបករណ៍នេសាទ ប៉ុន្តែអ្នកនេសាទមានកាតព្វកិច្ចបង់ពន្ធជូនរដ្ឋតាមការកំណត់។

៣-រដ្ឋកំណត់ចំនួនឧបករណ៍នេសាទ។

ក្នុងឆ្នាំ១៩០៨ ដដែលនេះដែរ រដ្ឋបាលអាណានិគមបារាំងក៏បានដាក់ចេញនូវព្រះរាជប្បញ្ញត្តិមួយទៀតលេខ៥៤ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩០៨ ស្តីពីការកំណត់ប្រាក់ពន្ធលើឧបករណ៍នេសាទ។ ព្រះរាជប្បញ្ញត្តិលេខ៥៤ ក្រោយនេះបានឡាយព្រះហស្តលេខាដោយ **ព្រះបាទស៊ីសុវត្ថិ** និងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការតាមសេចក្តីសម្រេចលេខ៨១១ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩០៨ ដោយទេសាភិបាលប្រចាំនៅកម្ពុជា។ បន្ទាប់មកទៀត នៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ១៩២០ មានព្រះរាជប្បញ្ញត្តិមួយទៀតបានបញ្ញត្តិអំពី **"សិទ្ធិនៃការគ្រប់គ្រងលើទ្រព្យសម្បត្តិ"** ហើយត្រូវបានឡាយព្រះហស្តលេខាដោយ **ព្រះបាទស៊ីសុវត្ថិ** និងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅខែមីនា ឆ្នាំ១៩២១។ ព្រះរាជប្បញ្ញត្តិចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ១៩២០ នេះ បានកំណត់រដូវនេសាទសម្រាប់ឡូត៍នេសាទថាការធ្វើអាជីវកម្មឡូត៍នេសាទនឹងត្រូវចាប់ផ្តើមពីថ្ងៃទី០១ ខែកញ្ញាទៅដល់ថ្ងៃទី១៥ ខែមិថុនា ហើយអនុញ្ញាតឱ្យប្រជាពលរដ្ឋក្នុងភូមិមានសិទ្ធិធ្វើនេសាទដោយប្រើឧបករណ៍នេសាទចល័តរយៈពេលខ្លីបានទៅតាមរដូវនេសាទ។

នៅក្នុងឆ្នាំ១៩២១ នេះផងដែរ រដ្ឋបាលអាណានិគមបារាំងបានរៀបចំកែសម្រួល ដើម្បីបង្កើតជាឡូត៍នេសាទដូចឡូត៍នេសាទនាបច្ចុប្បន្ន ដោយកំណត់ផ្ទៃក្រឡាតូចល្មមសមស្របតាមភូមិសាស្រ្តជាក់ស្តែងនិងស្របតាមសមត្ថភាពរបស់មេសង្វៀននីមួយៗ ប៉ុន្តែពុំទាន់មានលក្ខណៈច្បាស់លាស់នៅឡើយទេ។ ចំពោះឡូត៍នេសាទ រដ្ឋបាលអាណានិគមបារាំងក៏បានធ្វើការសាកល្បងដាក់ឱ្យដេញថ្លៃផងដែរ។ ទន្ទឹមនឹងនោះដែរ ក៏មានការសិក្សាស្រាវជ្រាវជាបន្តបន្ទាប់នៅតាមបណ្តាឡូត៍នេសាទនីមួយៗ អំពីលក្ខណៈជីវសាស្រ្ត បច្ចេកទេស និងសេដ្ឋកិច្ច ដើម្បីកំណត់ថ្លៃឈ្នួលឱ្យបានសមស្របនិងច្បាស់លាស់។ បន្ទាប់មកទៀត នៅឆ្នាំ១៩២៩ ក្នុងរជ្ជកាល **ព្រះបាទស៊ីសុវត្ថិ មុនីវង្ស**

(១៩២៧-១៩៤១)ឡូត៍នេសាទ នៅព្រះរាជាណាចក្រកម្ពុជាក៏បានធ្វើការកែសម្រួលជាថ្មីម្តងទៀត ដោយធ្វើការរៀបចំផែនទីឡូត៍នេសាទត្រឹមត្រូវនិងច្បាស់លាស់ប្រសើរជាងឡូត៍នេសាទមុន ព្រមទាំងកំណត់រក្សាទុកផ្ទៃឡូត៍ចំនួន៧% នៃផ្ទៃឡូត៍នេសាទសរុបទុកជូនប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ និងបានរៀបចំសៀវភៅបន្ទុកឡូត៍នេសាទផងដែរ។ ក្នុងសៀវភៅបន្ទុកបានកំណត់របាំងធ្នស់មានប្រវែង១/២ នៃទទឹងព្រែកឬស្ទឹង ដើម្បីឱ្យជលយានអាចធ្វើដំណើរបាននិងទំហំក្រឡាសាច់មង អួនមិនត្រូវតូចជាង២៥ មីល្លីម៉ែត្រឡើយ។ ចំណែកឧបករណ៍នេសាទវិញ ត្រូវធ្វើការរុះរើចេញឱ្យបានមុនថ្ងៃទី១៥ ខែមិថុនានិងតម្រូវឱ្យអាជីវករឡូត៍នេសាទទាំងអស់ដែលដេញថ្លៃបាន ត្រូវបង់ប្រាក់កក់មុនចំនួន១/៣ នៃថ្លៃឈ្នួលដេញបានសរុប ហើយតម្រូវឱ្យបង់ពន្ធផ្សេងទៀតផង។

**កំណត់សម្គាល់:**

គឺក្នុងសម័យកាលនោះ គេសង្កេតឃើញអាជីវករដេញថ្លៃឡូត៍នេសាទបានគឺ ភាគច្រើនជាជនជាតិចិននិងតិចតួចណាស់ដែលជាជនជាតិវៀតណាម។ រីឯជនជាតិខ្មែរ ភាគច្រើនជាអ្នកក្រគ្មានប្រាក់ចូលរួមដេញថ្លៃឡូត៍នេសាទទេ ហេតុនេះហើយ ទើបបង្ខំចិត្តជួលបន្តពីអ្នកមានសិទ្ធិកាន់កាប់ឡូត៍នេសាទប៉ុណ្ណោះ។

**-សម័យកាលចន្លោះឆ្នាំ១៩៣០-១៩៤៦**

នៅឆ្នាំ១៩៣២ លោក P CHEVEY ជនជាតិបារាំងនិងលោក F LEPOULAIN ជនជាតិបារាំងដូចគ្នា បានធ្វើការសិក្សាស្រាវជ្រាវអំពីលក្ខណៈជីវសាស្ត្រ ឥទ្ធិពលធម្មជាតិរបស់ព្រៃលិចទឹក ល្បឿននៃការលូតលាស់របស់ត្រី និងស្រាវជ្រាវអំពីឡូត៍នេសាទផងដែរអស់រយៈពេល១០ ឆ្នាំ គឺចាប់ពីឆ្នាំ១៩៣០ ដល់ឆ្នាំ១៩៤០។ កម្មវត្ថុនៃការសិក្សាស្រាវជ្រាវនោះរួមមាន៖

១-លក្ខណៈបច្ចេកទេសរួមមាន ឧបករណ៍នេសាទ កន្លែងធ្វើនេសាទ (តាមដងទន្លេនិងបឹងទន្លេសាប) និងវិធីសាស្ត្រនេសាទ។

២-លក្ខណៈសេដ្ឋកិច្ចរួមមាន ផលនេសាទស្រស់ កែច្នៃ អនុផលនេសាទ ដើមទុន និងការនាំចេញផលនេសាទ។

៣-កិច្ចការរដ្ឋបាលរួមមាន ការដេញថ្លៃឡូត៍នេសាទ ចរិតលក្ខណៈបណ្តាខេត្តដែលមានឡូត៍នេសាទ ការកាប់ឆ្ការព្រៃលិចទឹក និងបទល្មើសជលផល។

ដោយឡែក ពីឆ្នាំ១៩២៥ ដល់ឆ្នាំ១៩៣២ ក៏មានការស្រាវជ្រាវកន្លែងសំខាន់ៗ មួយចំនួននៅក្នុងបឹងទន្លេសាបដែរ។ ការស្រាវជ្រាវនេះគឺអនុវត្តដោយវិទ្យាស្ថានស្រាវជ្រាវសាគរសាស្ត្រប្រចាំតណ្ឌូចិនដែលបានប្រើប្រាស់កាណូតមួយឈ្មោះ DE LA NAISSAN ក្នុងគោលបំណងរៀបចំនិងកែប្រែឬធ្វើវិសោធនកម្មនូវព្រះរាជប្បញ្ញត្តិចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ១៩២០ ដើម្បីគ្រប់គ្រងការធ្វើអាជីវកម្មនេសាទឱ្យបានសមស្របទៅតាមភូមិសាស្ត្រជាក់ស្តែងនីមួយៗ នៅតាមតំបន់នៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសការធ្លាក់ចុះចំណូលលើវិស័យនេសាទ។ ជាក់ស្តែង

នៅចន្លោះឆ្នាំ១៩២៩ ដល់ឆ្នាំ១៩៣០ ចំណូលលើវិស័យនេសាទមានទឹកប្រាក់ចំនួន១.៣៥៥.៤៦១ រៀល ប៉ុន្តែចំនួនទឹកប្រាក់នេះត្រូវបានធ្លាក់ចុះមកត្រឹម២៧៤.៩៣៦ រៀលប៉ុណ្ណោះនៅឆ្នាំ១៩៣៨។

ចំពោះមូលហេតុនៃការធ្លាក់ចុះប្រាក់ចំណូលលើវិស័យនេសាទខាងលើ គឺបណ្តាលមកពីការថយចុះបរិមាណត្រីដោយសារការបំផ្លិចបំផ្លាញរបស់មេសង្វៀន ដែលបានចាប់ត្រីមេពូជដែលកំពុងពងកូនយ៉ាងច្រើនលើសលុបដោយប្រើឧបករណ៍នេសាទហាមឃាត់អស់ជាច្រើនឆ្នាំ។ ចំពោះបញ្ហានេះ ទេសាភិបាលប្រចាំនៅកម្ពុជាក៏បានសម្រេចឱ្យធ្វើវិសោធនកម្មព្រះរាជប្បញ្ញត្តិចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ១៩២០ តែម្តង ដើម្បីធ្វើការកែសម្រួលនូវភាពដ៏ស្មុគស្មាញទាំងឡាយក្នុងការអនុវត្តកិច្ចសន្យាសម្រាប់ធ្វើអាជីវកម្មឡូត៍នេសាទ។ បញ្ហានេះ សូមបញ្ជាក់ផងដែរថា រដ្ឋបាលអាណានិគមបារាំងមានបំណងធ្វើវិសោធនកម្មនេះតាំងពីឆ្នាំ១៩២៩ មកម្ល៉េះ។ ឯលទ្ធផលដែលទទួលបានពីការស្រាវជ្រាវរបស់វិទ្យាស្ថានស្រាវជ្រាវសាគរសាស្ត្រប្រចាំតណ្ឌូចិនដោយកាណូតឈ្មោះDE LA NAISSAN ខាងលើ គេសង្កេតឃើញរដ្ឋបាលអាណានិគមបារាំងបានរៀបចំនិងបង្កើតឡើងជាបន្តបន្ទាប់នូវឡូត៍នេសាទជាតិ ឡូត៍នេសាទខេត្តនិងឡូត៍នេសាទទុកជាអាករឃុំ។

ក្នុងអំឡុងឆ្នាំ១៩៣៦ គឺជាឆ្នាំដែលរដ្ឋបាលអាណានិគមបារាំងអនុញ្ញាតពិសេសមួយគឺ ការសម្រេចឱ្យរៀបចំនិងបង្កើតឡូត៍ដាយចាប់ត្រីនៅតាមដងទន្លេសាប ចាប់ពីចំណុចសាលាស្រុកពញាឮ (កំពង់ហ្លួង)ក្នុងភូមិសាស្ត្រខេត្តកណ្តាលរហូតមកដល់មុខព្រះបរមរាជវាំងក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ដើម្បីឆ្លើយតបទៅនឹងសំណូមពររបស់ប្រជាពលរដ្ឋច្រើននាក់ដែលរស់នៅតាមដងទន្លេសាប រាជធានីភ្នំពេញ និងតាមបណ្តាខេត្តផ្សេងទៀត ដើម្បីយកត្រីធ្វើប្រហុក ផ្អកទុកបរិភោគតាមប្រពៃណីជារៀងរាល់ឆ្នាំ។ សូមបញ្ជាក់ដែរថា រដ្ឋបាលអាណានិគមបារាំងដែលបានសម្រេចអនុញ្ញាតនេះ គឺសម្រេចតាមសំណូមរបស់ប្រជាពលរដ្ឋតាមរយៈព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ ហេតុដូច្នេះហើយ ទើបមានឡូត៍ដាយចាប់ត្រីរហូតមកដល់បច្ចុប្បន្ន។ ប៉ុន្តែឡូត៍ដាយចាប់ត្រី ត្រូវបានហាមឃាត់មិនឱ្យធ្វើអាជីវកម្មនៅកន្លែងនេសាទបម្រុង ឬពីមុនហៅថា កន្លែងនេសាទសាធារណៈឡើយ។

**-សម័យកាលចន្លោះឆ្នាំ១៩៤៧-១៩៥២**

ឆ្នាំ១៩៤៦ ក្នុងរជ្ជកាល **ព្រះបាទនរោត្តម សីហនុ** (១៩៤១-១៩៥៥)នេះ គេសង្កេតឃើញមានសកម្មភាពធ្វើនេសាទនិងអាជីវកម្មនេសាទខ្លាំងក្លា ជាពិសេសការប្រើប្រាស់ឧបករណ៍នេសាទថ្មីៗ ដែលទើបបង្កើតឡើង។ ការគ្រប់គ្រងត្រូវបានរឹតបណ្តឹងដោយមានការដាក់ចេញនូវវិធានបន្តបន្ទាប់ ដើម្បីការពារធនធានមច្ឆជាតិជាអាទិ៍ៈ

-ការកំណត់រដូវបិទនេសាទ

-ការបង្កើតកន្លែងនេសាទបម្រុងដែលបច្ចុប្បន្នហៅថា កន្លែងអភិរក្សជលផល

-ការរឹតបន្តឹងប្រភេទឧបករណ៍នេសាទនិងសម្ភារៈនេសាទ

-ការរក្សាទុកផ្ទៃឡូត៍ចំនួន៧% សម្រាប់ប្រជាពលរដ្ឋក្នុងភូមិធ្វើនេសាទជាលក្ខណៈគ្រួសារ

-ការបង្កើតវិទ្យាស្ថានស្រាវជ្រាវនេសាទទឹកសាប។ល។និង។ល។

មានព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រមួយក្នុងឆ្នាំ១៩៤៧ នេះ គឺការបង្កើត " **ក្រុមនេសាទជាតិ**" ដើម្បីធ្វើការគ្រប់គ្រងវិស័យនេសាទកម្ពុជាតាមរយៈព្រះរាជក្រមលេខ៣៨៦ នស ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៤៧។ បន្ទាប់មក **ក្រុមនេសាទជាតិ** ក៏បានបញ្ចូលជាមួយក្រុមមួយទៀតទទួលបន្ទុកគ្រប់គ្រងព្រៃឈើនិងសត្វព្រៃដែលហៅថា"**គង្គា-វុក្ខា និងនេសាទ**"។

នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៤៨ គឺមានព្រឹត្តិការណ៍មួយគួរឱ្យភ្ញាក់ផ្អើលនិងចាត់អាចទុកជាប្រវត្តិសាស្ត្រផងដែរសម្រាប់វិស័យនេសាទរបស់កម្ពុជាពោលគឺ **ឯកឧត្តម មៀច គន្ធ** ដែលជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុក្នុងជំនាន់នោះបានឃុបឃិតនិងអនុញ្ញាតឱ្យឈ្មោះ **គី ហេង** ដែលជាមេសង្វៀនធ្វើនេសាទដោយបោះរបាំងធ្នស់ចាប់ត្រីនៅចំណុចខ្លាគ្រហឹមស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ឆ្នាំងដោយពុំមានការដាក់ឱ្យដេញថ្លៃជាសាធារណៈ និងស្ថិតនៅក្រៅនាទីឡូត៍នេសាទ ព្រមទាំងពុំបានទុកច្រកសម្រាប់ហ្វូងមច្ឆជាតិនិងជលយានចេញ ចូលថែមទៀតផង។ ដោយសារការសម្រេចជាអត្តនោម័តនិងពុំមានការឆ្លង យោបល់អំពីជំនាញ"**ក្រុមនេសាទជាតិ**"បានបង្កឱ្យហ្វូងត្រីងាប់កកកុញយ៉ាងច្រើនក្នុងចម្ងាយប្រវែងប្រហែល១ គីឡូម៉ែត្រខាងមុខរបាំងធ្នស់។ បញ្ហានេះ បានធ្វើឱ្យប្រជាពលរដ្ឋរស់នៅផ្នែកខាងក្រោមរបាំងធ្នស់រាប់ពាន់គ្រួសារងើបបះបោរឡើងប្រឆាំងទៅនឹងការសម្រេចដ៏ខុសឆ្គងរបស់ **ឯកឧត្តម មៀច គន្ធ** ដែលជាអ្នកដើមហេតុនិងបង្កឱ្យប្រជាពលរដ្ឋគ្មានត្រីសម្រាប់បរិភោគប្រចាំថ្ងៃដូចសព្វមួយដង។

បញ្ហានេះ ក្រោយមក **ឯកឧត្តម មៀច គន្ធ** រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុរួមទាំង **សម្តេច ប៉ែន នុត** នាយករដ្ឋមន្ត្រីផងដែរ ត្រូវបានដកចេញពីដំណែង។ បន្ទាប់មកទៀត ដោយសារបញ្ហានេះ រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាក៏បានសម្រេចឱ្យក្រសួងហិរញ្ញវត្ថុ មានភារកិច្ចប្រមូលចំណូលសារពើពន្ធតែប៉ុណ្ណោះ។ រីឯចំណូលដែលមិនមែនជាសារពើពន្ធ គឺទុកជូនអង្គភាពជំនាញជាអ្នកអនុវត្តផ្ទាល់វិញ ហេតុនេះហើយ ទើបការប្រមូលថ្លៃឈ្នួលឡូត៍នេសាទត្រូវបានប្រគល់មកអង្គភាពនេសាទអនុវត្តរហូតមកទល់បច្ចុប្បន្ននេះ។

(២) **សម័យកាលកម្ពុជាទទួលបានឯករាជ្យ**(ឆ្នាំ១៩៥៣ មកដល់បច្ចុប្បន្ន)

ក្នុងសម័យកាលនេះ ការគ្រប់គ្រងវិស័យនេសាទនៅព្រះរាជាណាចក្រកម្ពុជាកាន់តែមានសន្ទុះនិងវិវឌ្ឍគួរឱ្យមោទនៈជាក់ស្តែងនោះគឺ ការរៀបចំនិងអនុម័តច្បាប់ចំនួន០២ សម្រាប់គ្រប់គ្រងវិស័យនេសាទនៅតំបន់ទឹកសាបនិងសមុទ្រ។

ច្បាប់នេសាទដំបូងនៅកម្ពុជា (Code des Peches) ត្រូវបានរៀបចំនិងអនុម័តនៅឆ្នាំ១៩៥៦ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការតាមរយៈព្រះរាជក្រមលេខ៨៧ នស ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៥៦ សម្រាប់គ្រប់គ្រងការនេសាទទឹកសាប។ ច្បាប់នេសាទទឹកសាប (Code des Peches) នេះ មាន១១ ជំពូក និង១៣៤ មាត្រា។ ចំណែកច្បាប់

នេសាទសមុទ្រ បានរៀបចំនិងអនុម័តនៅឆ្នាំ១៩៥៨ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការតាមរយៈព្រះរាជក្រមលេខ ២៤៩ នស ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៥៨។ ច្បាប់នេសាទសមុទ្រមាន ៦ ជំពូក និង៤៨ មាត្រា។

ច្បាប់នេសាទកម្ពុជាទាំង២ នេះ គឺ ជាក្រមដំបូងរបស់នីតិនិពន្ធខ្មែរសុទ្ធសាធដែលបានរៀបចំនិងតាក់តែងឡើងដោយខ្មែរ ដើម្បីខ្មែរនិងមានលក្ខណៈសមស្របទៅតាមទំនៀមទម្លាប់ប្រពៃណីខ្មែរ ហើយក៏ពុំមានការចម្លងចេញអំពីច្បាប់របស់បរទេសណាមួយដែរ។

ចំណុចកត់សម្គាល់គឺ ច្បាប់ស្តីពីការគ្រប់គ្រងការនេសាទទឹកសាបបានកែសម្រួលរយៈពេលនៃការកាន់កាប់ឡូត៍នេសាទ មកត្រឹម០២ រដូវនេសាទវិញ។

**-សម័យកាលចន្លោះឆ្នាំ១៩៦០-១៩៧៥**

ក្នុងឆ្នាំ១៩៦០ "ក្រុមនេសាទជាតិ" ត្រូវបានបំបែកចេញពីក្រុម"គង្គា-រុក្ខា និងនេសាទ"តាមរយៈការធ្វើវិសោធនកម្មមាត្រា៣ និងមាត្រា៤ នៃច្បាប់នេសាទទឹកសាបឆ្នាំ១៩៥៦ ដើម្បីបង្កើត "ក្រុមនេសាទជាតិ"មួយដោយឡែក ហើយច្បាប់វិសោធនកម្មនេះត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រមលេខ៣៩២ នស ចុះថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ១៩៦០។ បន្ទាប់មក នាយកដ្ឋាននេសាទក៏ត្រូវបានបង្កើតឡើងជាដំបូងសម្រាប់គ្រប់គ្រងវិស័យនេសាទនៅកម្ពុជាដែលមានរចនាសម្ព័ន្ធគ្រប់គ្រងជាខ្សែរយៈបណ្តោយបែងចែកជាថ្នាក់កណ្តាល អធិការដ្ឋាននេសាទ ខណ្ឌនេសាទ ផ្នែកនេសាទនិងសង្កាត់នេសាទជាជំនួយការ។ ចំពោះការងារគ្រប់គ្រងរួមមាន៖

-ការរៀបចំនិងគ្រប់គ្រងការធ្វើអាជីវកម្មនេសាទ

-ការងារកែលម្អដែននេសាទ

-ការងារផែនការនេសាទ

-ការងារនីតិកម្ម

-ការងារស្ថិតិនេសាទ

-ការងាររដ្ឋបាល

-ការងារចាត់តាំងនិងគណនេយ្យ និង

-ការងារទប់ស្កាត់បទល្មើសនេសាទ។

**-សម័យកាលចន្លោះឆ្នាំ១៩៧៥-១៩៧៩**

ដោយឡែក ក្នុងសម័យកាលនេះគឺ ជាសម័យកាលមួយដ៏អាប់អួរនិងខ្មៅងងឹតដែលពិភពលោកពុំធ្លាប់ជួបប្រទះ។ ជាក់ស្តែង រចនាសម្ព័ន្ធគ្រប់គ្រងដែលរដ្ឋបានរៀបចំកន្លងមក ត្រូវបានរដ្ឋបាលគ្រប់គ្រងក្រោមរបបនេះបំផ្លាញចោលដល់ឫសគល់និយាយរួម និយាយដោយឡែក វិស័យនេសាទដែលបុព្វបុរសយើងបានខិតខំរៀបចំបង្កើតឡើងតាំងឆ្នាំ១៩៦០ គឺត្រូវបានបំផ្លាញចោលទាំងស្រុង។ គេសង្កេតឃើញក្នុងសម័យកាលនោះគឺ មានប្រជាពលរដ្ឋ

មួយចំនួនបានធ្វើនេសាទ ដោយប្រើប្រាស់ឧបករណ៍នេសាទតូចតាចដែលមាននៅតាមមូលដ្ឋាននីមួយៗ ក្រោមបញ្ជារបស់អង្គការសម្រាប់យកមក ផ្គត់ផ្គង់ផ្ទះបាយរួមដែលហៅថា"សហករណ៍"។ ក្នុងកំឡុងឆ្នាំ១៩៧៥ ក្រោយជ័យជំនះភ្លាមអង្គការរដ្ឋបាលអាវខ្មៅ ក៏មានការធ្វើនេសាទដោយឧបករណ៍ដាយចាប់ត្រីដែរនៅតាមដងទន្លេសាប។ ប៉ុន្តែការធ្វើនេសាទនេះ គេក៏ពុំដឹងច្បាស់ដែរថា តើការធ្វើនេសាទដោយឧបករណ៍នេសាទដាយចាប់ត្រីនេះ គេធ្វើនេសាទរហូតដល់ឆ្នាំណានោះទេ។ ផ្ទុយទៅវិញ ករណីធ្វើនេសាទដោយគ្មានបទបញ្ជាអំពីអង្គការរដ្ឋបាលអាវខ្មៅទេ អ្នកនេសាទនោះ ត្រូវបានគេចាត់ទុកថា ជាជនក្បត់អង្គការឬសមូហភាព ហើយជននោះត្រូវតែទទួលរងទណ្ឌកម្មដោយគ្មានតុលាការវិនិច្ឆ័យឡើយ។

ចំពោះយន្តការគ្រប់គ្រងធនធាននេសាទវិញ គេពុំបានដឹងច្បាស់ថា តើមានរចនាសម្ព័ន្ធគ្រប់គ្រងនិងបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងយ៉ាងណានោះទេ។ ដោយឡែក ឡូត៍នេសាទគឺ អង្គការរដ្ឋបាលអាវខ្មៅបានរំសាយចោលទាំងស្រុង។

**-សម័យកាលឆ្នាំ១៩៧៩ ដល់ឆ្នាំ២០១២**

ក្នុងសម័យកាលនេះ វិស័យនេសាទកម្ពុជាត្រូវបានបើកទំព័រប្រវត្តិសាស្ត្រថ្មីរបស់ខ្លួន បន្ទាប់ពីការបំផ្លិចបំផ្លាញដល់ ឬសគល់ក្រោមរបបប្រល័យពូជសាស្ត្រសាសន៍ជាតិឯងមួយនេះ។ ជាក់ស្តែង ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៧៩ **"នាយកដ្ឋានជលផល"** ពីមុនមានឈ្មោះថា **"នាយកដ្ឋាននេសាទ"** ក៏ត្រូវបានបង្កើតឡើងជាបន្ទាន់ភ្លាមដែរ បន្ទាប់ពីបញ្ចប់សន្និបាតរបស់អង្គភាពនេសាទរដ្ឋនៅដើមខែកញ្ញា ឆ្នាំ១៩៧៩ នាសណ្ឋាគារអង្គរក្នុងខេត្តសៀមរាប។ **"នាយកដ្ឋានជលផល"** ដែលបានបង្កើតឡើងថ្មីនេះគឺ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងពាណិជ្ជកម្មរហូតដល់ថ្ងៃទី០១ ខែមករា ឆ្នាំ១៩៨០ ទើបផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទវិញរហូតមកដល់បច្ចុប្បន្ន។ គួរកត់សម្គាល់ផងដែរថា ក្រោយពីច្បាប់ស្តីពីជលផលត្រូវបានអនុម័តនិងដាក់ឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ មក នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៦ **នាយកដ្ឋានជលផល** បានប្តូរឈ្មោះទៅជា **រដ្ឋបាលជលផល** តាមរយៈអនុក្រឹត្យលេខ៧៨ អនក្រ.បក។ បន្ទាប់មកទៀត នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ រដ្ឋបាលជលផលក៏បានដំឡើងឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋានតាមរយៈអនុក្រឹត្យលេខ ១៨៨ អនក្រ.បកផងដែរ។ រីឯឡូត៍នេសាទដែលបានរំសាយក្រោមរបបប្រល័យពូសាសន៍ជាតិឯងនោះក៏ត្រូវបានរៀបចំនិងបង្កើតឡើងវិញជាបន្ទាន់ដែរតាមរយៈសេចក្តីសម្រេចលេខ១៤៩-៨០ កប ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៨០របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា។ ប្រការ៤ នៃសេចក្តីសម្រេចលេខ១៤៩-៨០ បានបញ្ញត្តិថា:"*ចាត់ចូលជាឡូត៍នេសាទ គឺកន្លែងនេសាទទាំងអស់ដែលអង្គភាពរដ្ឋ ឬក្រុមសាមគ្គីនេសាទបានទទួលសិទ្ធិដាច់តែឯងក្នុងការប្រកបអាជីវកម្មនៅចន្លោះរដូវនេសាទ។*

<u>*នៅចំពោះមុខ ព្រំប្រទល់និងនាទីឡូត៍នេសាទ ព្រមទាំងកន្លែងដាក់ដាយចាប់ត្រីនៅតាមដងទន្លេសាបនិង*</u>

*ដាយចាប់បង្កងនៅតាមដងទន្លេក្នុងសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវបានកំណត់ទទួលស្គាល់ជាផ្លូវការយកតាមព្រំប្រទល់នាទីឡូត៍នេសាទនិងកន្លែងដាក់ដាយដែលមានពីមុនមក* ហើយដែលមានចែងក្នុងតារាងរណប "ក" ភ្ជាប់ជាមួយនេះស្រាប់។ "ប្រការ៥ នៃសេចក្តីសម្រេចដដែលបានបញ្ញត្តិដែរថា:"*នាទីឡូត៍នេសាទទាំងអស់នៅក្នុងសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវបានបែងចែកជា២ ប្រភេទគឺះ*

*១-គឺឡូត៍នេសាទដែលត្រូវតាក់តែងឡើង ដើម្បីជាប្រយោជន៍ដល់ថវិកាជាតិ។*

*២-គឺឡូត៍នេសាទដែលត្រូវតាក់តែងឡើង ដើម្បីជាប្រយោជន៍ដល់ថវិកាខេត្ត។* " ចំណែកប្រការ៩ នៃសេចក្តីសម្រេចដដែលបានបញ្ញត្តិទៀតថា:"*នាយកដ្ឋានជលផលមជ្ឈិម ត្រូវទទួលសិទ្ធិនិងភារកិច្ចបែងចែក ចាត់តាំងឡូត៍នេសាទជាតិ ព្រមទាំងកន្លែងដាក់ដាយចាប់ត្រីនិងបង្កងតាមដងទន្លេ ឬព្រែកក្នុងសាធារណរដ្ឋប្រជាមានិតកម្ពុជា។*

*ចំពោះការចាត់ចែងឱ្យធ្វើអាជីវកម្មលើឡូត៍នេសាទខេត្ត ជាភារកិច្ចរបស់គណៈកម្មាធិការប្រជាជនបដិវត្តន៍និងការិយាល័យជលផលខេត្តដែលរួមគ្នាជាមួយគណៈកម្មការ ដើម្បីពិភាក្សាសម្រេច។"*

បានសេចក្តីថា ឡូត៍នេសាទដែលបានបង្កើតឡើងវិញនៅឆ្នាំ១៩៨០ នេះត្រូវបានកំណត់យកតាមលំនាំព្រំប្រទល់ឡូត៍នេសាទចាស់ដែលបានបង្កើតឡើងតាំងពីឆ្នាំ១៩២៩ មក។ ដោយឡែក ទីតាំងឡូត៍ដាយចាប់ត្រី ដាយចាប់បង្កងក៏បានកំណត់យកតាមទីតាំងចាស់ដែរ ប៉ុន្តែមានការកែសម្រួលទីតាំងថ្មីមួយចំនួនទៅតាមស្ថានភាពនិងជាក់ស្តែង។ ដោយឡែក ការរៀបចំផែនទីឡូត៍នេសាទក៏អនុវត្តទៅតាមព្រំប្រទល់ចាស់ឆ្នាំ១៩២៩ ដែរ។ ប៉ុន្តែមានចំណុចគួរឱ្យកត់សម្គាល់នោះគឺ ការគូរផែនទីដោយអនុវត្តវិធីកាល់តាមផែនទីរួមនិងជាទូទៅពុំបានចុះពិនិត្យជាក់ស្តែងដល់ទីតាំងទេ ពីព្រោះបញ្ហាសន្តិសុខ ធនធានមនុស្ស និងបច្ចេកទេស។

ចំពោះព្រំប្រទល់និងផែនទីឡូត៍នេសាទដែលបានរៀបចំថ្មីក្រោយឆ្នាំ១៩៧៩ ហើយបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការរហូតមកដល់ខែមីនា ឆ្នាំ២០១២ (រំសាយឡូត៍នេសាទ)កន្លងមកក៏ដោយក៏ពុំបានធ្វើបច្ចុប្បន្នភាពកែសម្រួលព្រំប្រទល់ឡូត៍នេសាទដែលឈប់បម្រើវិស័យជលផល ហើយទៅបម្រើវិស័យផ្សេងទៀតនោះទេ ទោះបីជារដ្ឋាភិបាលសម្រេចធ្វើការកែសម្រួលកាត់បន្ថយផ្ទៃឡូត៍នេសាទឬលុបឡូត៍នេសាទចំនួន២ លើកសំខាន់ៗ កន្លងមកក៏ដោយ (លើកទី១ នៅឆ្នាំ២០០០ និងលើកទី២ នៅឆ្នាំ២០១២)។ បញ្ហាដែលចោទគឺ ស្ថានភាពផ្ទៃឡូត៍នេសាទទាំងមូលបានប្រែប្រួលទៅតាមធម្មជាតិជា អាទិ៍ ផ្នែកខ្លះនៃឡូត៍នេសាទទាំងមូលបានក្លាយជាវត្តអារាម ភូមិអ្នកស្រុក សាលារៀន...។ល។និង។ល។ ប៉ុន្តែក៏មានផ្នែកខ្លះកំពុងស្ថិតនៅជាបឹងបួរ ព្រែក ស្ទឹង អូរ ប្រឡាយ និងនាទីព្រៃលិចទឹកដែលបាននិងកំពុងបម្រើវិស័យជលផលដែរ។

បញ្ហានេះជាគោលការណ រដ្ឋត្រូវធ្វើបច្ចុប្បន្នភាពអំពីព្រំប្រទល់និងផែនទីឡូត៍នេសាទ ដើម្បីប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋឬដែននេសាទឱ្យចំតាមទិសដៅនៃទ្រព្យនិងប្រកបដោយប្រសិទ្ធភាពផង(មាត្រា១៦ ច្បាប់ភូមិបាលឆ្នាំ២០០១)។

តាមឯកសារស្រាវជ្រាវបានបញ្ជាក់ថា ឡូត៍នេសាទនៅក្នុងសម័យអាណានិគមនិយមបារាំង សម័យសង្គមរាស្រ្តនិយមនិងសម័យលោកសេនាប្រមុខ លន់ នល់ ឡូត៍នេសាទមានចំនួន២៣៩ ដូចគ្នា។ រីឯសម័យក្រោយថ្ងៃរំដោះ៧ មករា ឆ្នាំ១៩៧៩ ឡូត៍នេសាទមានចំនួន២៧០ ឡូត៍។ បន្ទាប់មក នៅឆ្នាំ២០០០ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចកាត់ផ្ទៃឡូត៍នេសាទនិងលុបឡូត៍នេសាទចំនួន១០៨ ឡូត៍នៅសល់ជាក់ស្តែងចំនួន១៦២ ឡូត៍។ បន្ទាប់មកទៀតនៅខែមីនា ឆ្នាំ២០១២ រាជរដ្ឋាភិបាលបានសម្រេចលុបឡូត៍នេសាទលើកទី២ ម្តងទៀតចំនួន៧០ ឡូត៍នៅសល់ជាក់ស្តែងចំនួន៩២ ឡូត៍ ហើយប្រគល់ជូនប្រជាពលរដ្ឋទូទៅធ្វើនេសាទជាលក្ខណៈគ្រួសារ បង្កើតជាកន្លែងអភិរក្សជលផលចំនួន៥០ កន្លែងបន្ថែមទៀតនិងប្រគល់ជូនសហគមន៍នេសាទចំនួន៥១៦ សហគមន៍ក្នុងនោះរួមមានសហគមន៍នេសាទនៅតំបន់ទឹកសាបមានចំនួន៤៧៧ សហគមន៍និងសហគមន៍នៅតំបន់ឆ្នេរមានចំនួន៣៩ សហគមន៍។ សូមបញ្ជាក់ផងដែរថា នៅឆ្នាំ២០០០ នេះ ក៏ជាឆ្នាំដែលរាជរដ្ឋាភិបាលសម្រេចឱ្យបង្កើតសហគមន៍នេសាទ ដើម្បីគ្រប់គ្រងឡូត៍នេសាទដែលបានកាត់បន្ថយឬលុបផងនោះដែរ។

បច្ចុប្បន្ន សហគមន៍នេសាទដែលបានបង្កើតឡើងមានសរុបចំនួន៥១៦ សហគមន៍ ហើយសហគមន៍ទាំងនោះ បាននិងកំពុងពង្រឹងសមត្ថភាពរបស់ខ្លួនក្រោមការជួយឧបត្ថម្ភគាំទ្រអំពីរាជរដ្ឋាភិបាលដោយមានរដ្ឋបាលជលផលទទួលបន្ទុកផ្ទាល់។ ជាក់ស្តែង សហគមន៍នេសាទនៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាមចំនួន១០ ក្នុងនោះសហគមន៍នេសាទស្ថិតក្នុងភូមិសាស្ត្រខេត្តតាកែវចំនួន៣ ខេត្តកណ្តាលចំនួន៣ និងខេត្តព្រៃវែងចំនួន៤ ត្រូវបានរាជរដ្ឋាភិបាលសម្រេចឱ្យធ្វើអាជីវកម្មចាប់ត្រីដោយបោះរបាំងធ្នស់តាមរយៈមាត្រ៥ នៃអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ ២០១២ ដើម្បីមានប្រាក់ចំណូលសម្រាប់ទ្រទ្រង់និងអភិវឌ្ឍន៍សហគមន៍របស់ខ្លួន។

**កំណត់សម្គាល់:**

ឡូត៍នេសាទទាំងអស់នៅព្រះរាជាណាចក្រកម្ពុជាមានចំនួន៦ ប្រភេទក្នុងនោះរួមមាន ១-ឡូត៍នេសាទបឹងព្រែក ២-ឡូត៍ឆ្នេរខ្សាច់ ៣-ឡូត៍ដាយត្រី ៤-ឡូត៍ដាយត្រីលេញ ៥-ឡូត៍ដាយកូនត្រីប្រា និង៦-ឡូត៍ដាយបង្គង។ ប៉ុន្តែ ទោះបីជារំសាយឡូត៍នេសាទនៅឆ្នាំ២០១២ ក៏ដោយ ក៏រាជរដ្ឋាភិបាលនៅរក្សាទុកឡូត៍ដាយមួយចំនួនដែរ ដើម្បីផ្គត់ផ្គង់ត្រីជូនប្រជាពលរដ្ឋធ្វើប្រហុក ផ្អក ឬត្រីប្រឡាក់សម្រាប់ទុកបរិភោគតាមប្រពៃណី។ ឡូត៍នេសាទរក្សាទុកមាន៩២ ឡូត៍ក្នុងនោះ ខេត្តកណ្តាលដាយចាប់ត្រីចំនួន៤៩ មាត់ និងដាយត្រីលិញចំនួន០១ មាត់។ រាជធានីភ្នំពេញដាយចាប់ត្រីចំនួន២២ មាត់និងខេត្តព្រៃវែងដាយត្រីលិញចំនួន០៧ មាត់ និងដាយចាប់បង្គងចំនួន១៣ មាត់។

១-តារាងលំអិតឡូត៍នេសាទមុនឆ្នាំ២០០០

| ល.រ | ឈ្មោះខេត្ត រាជធានី | បឹងព្រែក | ដាយត្រី | ដាយត្រីលិញ | ដាយបង្កង | ដាយកូនត្រីប្រា | ឆ្នេរខ្សាច់ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ខេត្តកំពង់ចាម | ១២ | | | | | ១២ | ២៤ |
| ២ | ខេត្តក្រចេះ | ០៨ | | | | | ០៧ | ១៥ |
| ៣ | ខេត្តកណ្ដាល | ១៩ | ៣៨ | ០១ | | ២១ | ០១ | ៨០ |
| ៤ | ខេត្តព្រៃវែង | ១៩ | | ០៧ | ១៣ | ១០ | | ៤៩ |
| ៥ | រាជធានីភ្នំពេញ | ០១ | ២៥ | | | | | ២៦ |
| ៦ | ខេត្តតាកែវ | ២០ | | | | | | ២០ |
| ៧ | ខេត្តកំពង់ឆ្នាំង | ១៩ | | | | | | ១៩ |
| ៨ | ខេត្តពោធិ៍សាត់ | ០៧ | | | | | | ០៧ |
| ៩ | ខេត្តបាត់ដំបង | ១២ | | | | | | ១២ |
| ១០ | ខេត្តបន្ទាយមានជ័យ | ០៤ | | | | | | ០៤ |
| ១១ | ខេត្តសៀមរាប | ០៧ | | | | | | ០៧ |
| ១២ | ខេត្តកំពង់ធំ | ០៧ | | | | | | ០៧ |
| សរុប | | ១៣៥ | ៦៣ | ០៨ | ១៣ | ៣១ | ២០ | ២៧០ |

២-តារាងលំអិតឡូត៍នេសាទក្នុងចន្លោះឆ្នាំ២០០០ដល់ឆ្នាំ២០១២(ក្រោយកែទម្រង់លើកទី១)

| ល.រ | ឈ្មោះខេត្ត រាជធានី | បឹងព្រែក | ដាយត្រី | ដាយត្រីលិញ | ដាយបង្កង | ដាយកូនត្រីប្រា | ឆ្នេរខ្សាច់ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ខេត្តកំពង់ចាម | ០៧ | | | | | | ០៧ |
| ២ | ខេត្តក្រចេះ | | | | | | | |
| ៣ | ខេត្តកណ្ដាល | ១៤ | ៣៨ | ០១ | | | | ៥៣ |
| ៤ | ខេត្តព្រៃវែង | ១៤ | | ០៧ | ១៣ | | | ៣៤ |
| ៥ | រាជធានីភ្នំពេញ | | ២២ | | | | | ២២ |
| ៦ | ខេត្តតាកែវ | ០៨ | | | | | | ០៨ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៧ | ខេត្តកំពង់ឆ្នាំង | ១២ | | | | | | ១២ |
| ៨ | ខេត្តពោធិ៍សាត់ | ០៥ | | | | | | ០៥ |
| ៩ | ខេត្តបាត់ដំបង | ០៩ | | | | | | ០៩ |
| ១០ | ខេត្តបន្ទាយមានជ័យ | ០២ | | | | | | ០២ |
| ១១ | ខេត្តសៀមរាប | ០៣ | | | | | | ០៣ |
| ១២ | ខេត្តកំពង់ធំ | ០៧ | | | | | | ០៧ |
| សរុប | | ៨១ | ៦០ | ០៨ | ១៣ | | | ១៦២ |

២-តារាងលំអិតឡូត៍នេសាទក្រោយឆ្នាំ២០១២ មកដល់បច្ចុប្បន្ន(ក្រោយកែទម្រង់លើកទី២)

| ល.រ | ឈ្មោះខេត្ត រាជធានី | បឹងព្រែក | ដាយត្រី | ដាយត្រីលិញ | ដាយបង្កង | ដាយកូនត្រីប្រា | ឆ្នេរខ្សាច់ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ខេត្តកំពង់ចាម | | | | | | | |
| ២ | ខេត្តក្រចេះ | | | | | | | |
| ៣ | ខេត្តកណ្ដាល | | ៤៩ | ០១ | | | | ៥០ |
| ៤ | ខេត្តព្រៃវែង | | | ០៧ | ១៣ | | | ២០ |
| ៥ | រាជធានីភ្នំពេញ | | ២២ | | | | | ២២ |
| ៦ | ខេត្តតាកែវ | | | | | | | |
| ៧ | ខេត្តកំពង់ឆ្នាំង | | | | | | | |
| ៨ | ខេត្តពោធិ៍សាត់ | | | | | | | |
| ៩ | ខេត្តបាត់ដំបង | | | | | | | |
| ១០ | ខេត្តបន្ទាយមានជ័យ | | | | | | | |
| ១១ | ខេត្តសៀមរាប | | | | | | | |
| ១២ | ខេត្តកំពង់ធំ | | | | | | | |
| សរុប | | | ៧១ | ០៨ | ១៣ | | | ៩២ |

## ជំពូកទី២: នីតិវិធីធ្វើអត្តសញ្ញាណកម្មដែននេសាទ

### ១- គោលការណ៍គ្រឹះ

គោលការណ៍នៃការធ្វើអត្តសញ្ញាណកម្មដីរដ្ឋឬដែននេសាទគឺ ជាដំណើរការលម្អិតក្នុងការធ្វើអត្តសញ្ញាណកម្មដីរដ្ឋឬដែននេសាទដែលមានលក្ខណៈសម្របសម្រួល និងមានតម្លាភាពធ្វើឡើងដោយកិច្ចសហការរួមរវាងក្រសួងស្ថាប័ន អាជ្ញាធរដែនដី និងប្រជាពលរដ្ឋក្នុងមូលដ្ឋាន ហើយដែលអនុវត្តដោយក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌក្រោមការដឹកនាំរបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត (ប្រការ៣ នៃប្រកាសស្តីពីការធ្វើអត្តសញ្ញាណកម្មការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋឆ្នាំ២០០៥ និងមាត្រា៦ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋឆ្នាំ២០០៥)។

ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌផ្អែកតាមមាត្រា២៧ នៃអនុក្រឹត្យស្តីពីគ្រប់គ្រងដីរដ្ឋឆ្នាំ២០០៥ មានសមាសភាពដូចខាងក្រោមៈ

| | |
|---|---|
| -អភិបាលនៃគណៈអភិបាលស្រុក ខណ្ឌ | ជាប្រធាន |
| -ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ | ជាសមាជិកអចិន្ត្រៃយ៍ |
| -ប្រធានការិយាល័យជំនាញថ្នាក់ស្រុក ខណ្ឌពាក់ព័ន្ធ | ជាសមាជិក |
| -នាយផ្នែករដ្ឋបាលព្រៃឈើពាក់ព័ន្ធ | ជាសមាជិក |
| -មេឃុំ ចៅសង្កាត់ក្នុងស្រុក ខណ្ឌ | ជាសមាជិក |

ប្រធាននិងសមាជិកនៃក្រុមការងារដីរដ្ឋស្រុក ខណ្ឌ ត្រូវបានតែងតាំងដោយអភិបាលរាជធានី ខេត្ត។

ចំពោះសមាសភាពរបស់ក្រុមការងារដីរដ្ឋស្រុក ខណ្ឌ យើងសង្កេតឃើញថា ពុំមានសមាសសភាពផ្នែករដ្ឋបាលជលផលចូលរួមទេដោយហេតុថា ពេលនោះផ្នែករដ្ឋបាលជលផលពុំទាន់បានបង្កើតនៅឡើយ។ ប៉ុន្តែក្រោយមកនៅឆ្នាំ២០០៨ ទើបរដ្ឋបាលជលផលរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងចាត់តាំងមួយឯកភាពទូទាំងប្រទេសជាខ្សែរយៈបណ្តោយដោយបង្កើតជាថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋាន។ ថ្នាក់មូលដ្ឋានបានធ្វើការបែងចែកជា អធិការដ្ឋានរដ្ឋបាលជលផល ខណ្ឌរដ្ឋបាលជលផល ផ្នែករដ្ឋបាលជលផល និងសង្កាត់រដ្ឋបាលជលផល។ មានន័យថា នៅមុនឆ្នាំ២០០៨ រដ្ឋបាលជលផលនៅថ្នាក់មូលដ្ឋាន គឺមានតែការិយាល័យជលផលរាជធានី ខេត្ត ហើយស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរកសិកម្មរាជធានី ខេត្តប៉ុណ្ណោះ ប៉ុន្តែពុំទាន់បង្កើតជាអធិការដ្ឋានរដ្ឋបាលជលផលនិងផ្នែករដ្ឋបាលជលផលនៅឡើយទេ។ ដូចនេះ គួរធ្វើការកែសម្រួលបន្ថែមនូវសមាសភាពផ្នែករដ្ឋបាលជលផលទៅក្នុងសមាសភាពនៃក្រុមការងារដីរដ្ឋស្រុក ខណ្ឌ ដែលត្រូវបានតែងតាំងដោយអភិបាលរាជធានី ខេត្ត ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការធ្វើអត្តសញ្ញាណកម្មនិងផែនទីដីរដ្ឋ ឬដែននេសាទប្រកបដោយរលូន។

ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ត្រូវស្ថិតក្រោមការណែនាំផ្នែករដ្ឋបាលអំពីគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត និងក្រោមការណែនាំផ្នែកបច្ចេកទេសពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ចំពោះដីរដ្ឋដែលស្ថិតនៅតាមបណ្តោយព្រំដែនជាមួយប្រទេសជិតខាង ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវស្ថិតក្រោមការណែនាំលើផ្នែកបច្ចេកទេសបន្ថែមទៀតអំពីគណៈកម្មាធិការបច្ចេកទេស នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន។

មុខងារនិងភារកិច្ចរបស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ មានដូចខាងក្រោមៈ

-ប្រមូលនិងចងក្រងឯកសារព័ត៌មាន ដើម្បីធ្វើអត្តសញ្ញាណកម្មនិងផែនទីដីរដ្ឋ

-សម្របសម្រួលជាមួយស្ថាប័ន អាជ្ញាធរ ឬអ្នកកាន់កាប់ដីរដ្ឋអំពីអាណត្តិកាន់កាប់ដីរដ្ឋ

-ស្វែងរកការឯកភាពលើព្រំប្រទល់ប្រហាក់ប្រហែល ឋានៈ និងការប្រើប្រាស់បច្ចុប្បន្ននៃដីរដ្ឋ

-ធ្វើការបិទផ្សាយជាសាធារណៈនូវសំណៅព័ត៌មាននិងផែនទីដីរដ្ឋនៅតាមទីប្រជុំជន និងតាមឃុំ/សង្កាត់ពាក់ព័ន្ធនិងទទួលមតិយោបល់ពីសាធារណៈ តាមកាលបរិច្ឆេទនិងទីកន្លែងដែលបានកំណត់

-សង្ខេបមតិយោបល់សាធារណៈដែលបានទទួលនិងរៀបចំទិន្នន័យ និងឯកសារចាំបាច់ រួមទាំងផែនទីដីរដ្ឋដែលមានបញ្ជាក់ព័ត៌មានទាំងអស់ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត

-ចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លីនិងផ្តល់មតិយោបល់ក្នុងការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ

-រៀបចំពិគ្រោះយោបល់និងចូលរួមផ្តល់មតិយោបល់លើគម្រោងសម្បទានដីធ្លី ព្រមទាំងសហការតាមដានការអនុវត្តគម្រោងសម្បទានដីធ្លី និង

-បំពេញភារកិច្ចផ្សេងៗ ទៀតដូចមានចែងក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ (មាត្រា២៨ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋឆ្នាំ២០០៥)។

ចំណែក គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្តវិញ ផ្អែកតាមមាត្រា២៤ នៃអនុក្រឹត្យស្តីពីគ្រប់គ្រងដីរដ្ឋឆ្នាំ២០០៥ មានសមាសភាពដូចខាងក្រោមៈ

| | |
|---|---|
| -អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | ជាប្រធាន |
| -ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត | ជាសមាជិកអចិន្ត្រៃយ៍ |
| -មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងរាជធានី ខេត្ត | ជាសមាជិក |
| -ស្នងការនគរបាលរាជធានី ខេត្ត | ជាសមាជិក |
| -ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត | ជាសមាជិក |
| -ប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត | ជាសមាជិក |
| -ប្រធានមន្ទីរបរិស្ថានរាជធានី ខេត្ត | ជាសមាជិក |

-ប្រធានមន្ទីរធនធានទឹកនិងឧតុនិយមរាជធានី ខេត្ត ជាសមាជិក

-ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលរាជធានី ខេត្ត ជាសមាជិក

-ប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានី ខេត្ត ជាសមាជិក

-ប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត ជាសមាជិក

-ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត ជាសមាជិក

-ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត ជាសមាជិក

-នាយខណ្ឌរដ្ឋបាលព្រៃឈើដែលជាប់ពាក់ព័ន្ធ ជាសមាជិក

-អគ្គលេខាធិការសាលារាជធានី ខេត្ត ជាសមាជិក

សមាសភាពដែលមានចែងខាងលើ ត្រូវអញ្ជើញចូលរួមតាមការអញ្ជើញរបស់ប្រធាន។ ប្រធានគណៈកម្មាធិ-ការគ្រប់គ្រងដីរដ្ឋរាជធានី ខេត្ត អាចអញ្ជើញតំណាងមន្ទីរពាក់ព័ន្ធផ្សេងទៀតចូលរួមជាសមាជិកតាមតម្រូវការនៃករណីនីមួយៗ។

ដូចគ្នាដែរ សមាសភាពគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋរាជធានី ខេត្ត យើងសង្កេតឃើញថា ពុំមានសមាសអង្គភាពរដ្ឋបាលជលផលចូលរួមទេដោយហេតុថា ពេលនោះអតីតការិយាល័យជលផលរាជធានី ខេត្ត គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរកសិកម្មរាជធានីខេត្ត(ឆ្នាំ២០០៥) ហើយពុំទាន់មានការកែសម្រួលជាខ្សែរយៈបណ្តោយក្រោមការគ្រប់គ្រងរបស់រដ្ឋបាលជលផល។ ដូចនេះ ទើបគ្មានសមាសភាពខណ្ឌរដ្ឋបាលជលផលចូលរួមដូចខណ្ឌរដ្ឋបាលព្រៃឈើ។ បញ្ហានេះ ត្រូវធ្វើវិសោធនកម្មកែសម្រួលមាត្រា២៤ និងមាត្រា២៧ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋឆ្នាំ២០០៥ បញ្ចូលសមាសភាពខណ្ឌរដ្ឋបាលជលផលនៅក្នុងសមាសភាពគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋរាជធានីរាជធានី ខេត្តនិងផ្នែករដ្ឋបាលជលផលនៅក្នុងក្រុមការងារដីរដ្ឋស្រុក ខណ្ឌដូចអង្គភាពរដ្ឋបាលព្រៃឈើដែរ។

ចំពោះមុខងារនិងភារកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត មានដូចខាងក្រោមៈ

-ដឹកនាំក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌក្នុងការធ្វើអត្តសញ្ញាណកម្មនិងផែនទីដីរដ្ឋ

-សម្របសម្រួលជាមួយក្រសួង ស្ថាប័ន អាជ្ញាធរដែនដីអំពីអាណត្តិកាន់កាប់និងឋានៈ នៃដីរដ្ឋ

-ប្រមូលនិងចងក្រងឯកសារព័ត៌មានអំពីឋានៈនិងការប្រើប្រាស់បច្ចុប្បន្ន នៃដីរដ្ឋ

-ផ្តល់មតិយោបល់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬក្រុមប្រឹក្សាគោលនយោបាយដីធ្លីអំពីអាណត្តិកាន់កាប់និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ព្រមទាំងការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ

-ថែរក្សានិងធ្វើចរន្តការប្រមូលទិន្នន័យ និងផែនទីដីរដ្ឋប្រចាំរាជធានី ខេត្ត

-សម្រេចនិងត្រួតពិនិត្យលើការរៀបចំផែនការសកម្មភាពប្រើប្រាស់ដីថ្នាក់ឃុំ/សង្កាត់ដោយមានការចូលរួមផ្តល់មតិយោបល់លើគម្រោងសម្បទានដីធ្លីនិងសហការតាមដានការអនុវត្តគម្រោងទាំងនោះ

-សហការក្នុងការរៀបចំពិគ្រោះយោបល់ជាសាធារណៈលើគម្រោងសម្បទានដីធ្លី

-លើកគម្រោងថវិកាប្រចាំឆ្នាំ និង

-បំពេញភារកិច្ចផ្សេងៗ ទៀត ដូចមានចែងក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ ( មាត្រា២៥ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋឆ្នាំ២០០៥)។

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត មានលេខាធិការដ្ឋានមួយជាសេនាធិការ ដើម្បីជួយក្នុងកិច្ចការរដ្ឋបាលនិងកិច្ចការបច្ចេកទេសមានជាអាទិ៍ ការបញ្ចូលទិន្នន័យនិងព័ត៌មានពីក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ការថែរក្សានិងការធ្វើចរន្តការប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋ។

លេខាធិការដ្ឋានគ្រប់គ្រងដីរដ្ឋនេះ ដឹកនាំដោយប្រធានមួយរូបដែលជាអនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្តទទួលបន្ទុកការងារសុរិយោដីនិងសមាជិកមួយចំនួនទៀតតាមការចាំបាច់ដែលត្រូវបានតែងតាំងដោយអភិបាលរាជធានី ខេត្ត។

លេខាធិការដ្ឋាននេះ មានទីតាំងនៅក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត (មាត្រា២៦ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋឆ្នាំ២០០៥)។

ជាបន្ត មុននឹងពិភាក្សាអំពីនីតិវិធីនៃការធ្វើអត្តសញ្ញាណកម្មដីរដ្ឋឬដែននេសាទ យើងគប្បីស្វែងយល់អំពីអាជ្ញាធរកាន់កាប់ដីរដ្ឋជាមុនសិនដែរថា តើអ្វីទៅជាអាជ្ញាធរកាន់កាប់ដីរដ្ឋ ?

**ក- អាជ្ញាធរកាន់កាប់ដីរដ្ឋ(ដែននេសាទ)**

អាជ្ញាធរកាន់កាប់ដីរដ្ឋគឺ បណ្តាក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលរដ្ឋាភិបាលបានប្រគល់នូវសិទ្ធិប្រើប្រាស់ជាផ្លូវការនិងមានភារកិច្ចរក្សា ការពារដីសាធារណៈរបស់រដ្ឋឬដីឯកជនរបស់រដ្ឋ។ ជាក់ស្តែង មាត្រា១៨ ជំពូកទី៧ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋឆ្នាំ២០០៥ បានបញ្ញត្តិថាៈ"

*ក-រដ្ឋអាចប្រគល់ឱ្យក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីនូវសិទ្ធិប្រើប្រាស់ជាផ្លូវការនិងភារកិច្ចរក្សាការពារដីសាធារណៈរបស់រដ្ឋឬដីឯកជនរបស់រដ្ឋ។ ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលទទួលសិទ្ធិនោះហៅថា អាជ្ញាធរកាន់កាប់ដីរដ្ឋ។*

*ខ-អាណត្តិកាន់កាប់ដីរដ្ឋ ត្រូវប្រគល់ឱ្យតាមរយៈលិខិតគតិយុត្តជាកំណត់។ អាណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋត្រូវប្រគល់ឱ្យតាមនីតិវិធីដែលមានចែងក្នុងជំពូកទី៨ នៃអនុក្រឹត្យនេះ។ អាណត្តិនេះ អាចត្រូវដកហូតវិញនៅពេលណាក៏បាន។*

*គ-អាជ្ញាធរកាន់កាប់ដីរដ្ឋមានសិទ្ធិប្រើប្រាស់ដីនោះ ដើម្បីបម្រើបេសកម្មរបស់ស្ថាប័នខ្លួននិងមានភារកិច្ចការពារដីនោះពីការបំពាន ឬការចូលទន្ទ្រានកាន់កាប់នានា។*

*ឃ-អាជ្ញាធរកាន់កាប់ដីរដ្ឋ អាចធ្វើប្រតិភូកម្មសិទ្ធិប្រើប្រាស់ជាផ្លូវការនិងភារកិច្ចរក្សាការពារឱ្យទៅមន្ទីរឬការិ-*

*យាល័យខ្សែបណ្តោយរបស់ខ្លួនបានតាមរយៈការចេញលិខិតផ្លូវការដែលបញ្ជាក់ច្បាស់អំពីទីតាំងនិងទំហំដីជាក់លាក់ព្រមទាំងវិសាលភាពនៃការទទួលខុសត្រូវដែលត្រូវបានធ្វើប្រតិភូកម្ម។*

*ង-លើកលែងតែមានច្បាប់ចែងផ្ទុយពីនេះ ការប្តូរពីដីសាធារណៈរបស់រដ្ឋដែលបម្រើផលប្រយោជន៍សាធារណៈមួយជាក់លាក់ទៅបម្រើផលប្រយោជន៍សាធារណៈមួយផ្សេងទៀត ត្រូវកំណត់ដោយអនុក្រឹត្យ។*

*ច-អាជ្ញាធរកាន់កាប់ដីរដ្ឋ គ្មានសិទ្ធិជួល លក់ ផ្ទេរ ធ្វើអំណោយ ឬដោះដូរដីនោះបានឡើយ លើកលែងតែមានកំណត់ក្នុងអនុក្រឹត្យដោយឡែក។*

*ឆ-អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ត្រូវទទួលខុសត្រូវជាមួយអាជ្ញាធរកាន់កាប់ដីរដ្ឋក្នុងកិច្ចការពារដីសាធារណៈនិងដីឯកជនរបស់រដ្ឋ និងត្រូវមានវិធានការទប់ស្កាត់ការបំពានឬការចូលទន្ទ្រានកាន់កាប់ដីរដ្ឋ។"*

បានសេចក្តីថា អាជ្ញាធរកាន់កាប់ដីរដ្ឋ គឺក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលរដ្ឋបានប្រគល់ដីសាធារណៈឬដីឯកជនរបស់រដ្ឋឱ្យតាមរយៈលិខិតគតិយុត្តជាក់លាក់ ដើម្បីប្រើប្រាស់ ថែរក្សា និងការពារដោយមានវិធានការទប់ស្កាត់ រាល់ការចូលទន្ទ្រានកាន់កាប់ដីរដ្ឋ ប៉ុន្តែអាជ្ញាធរកាន់កាប់ដីរដ្ឋ គ្មានសិទ្ធិជួល លក់ ផ្ទេរ ធ្វើអំណោយ ឬដោះដូរដីនោះបានទេ លើកលែងតែមានការសម្រេចដោយរាជរដ្ឋាភិបាលតាមរយៈអនុក្រឹត្យ។

ចំពោះដែននេសាទវិញ មាត្រា៣ នៃនីតិជលផលឆ្នាំ២០០៦ បានបញ្ញត្តិថាៈ" *ការគ្រប់គ្រងជលផល ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។*" រីឯការប្រើប្រាស់ដែននេសាទវិញមាត្រា៩ នៃនីតិដដែលបានបញ្ញត្តិថាៈ"*ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិអនុញ្ញាតឱ្យប្រើប្រាស់ដែននេសាទទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះដល់រូបវន្តបុគ្គលឬនីតិបុគ្គល ដើម្បីធ្វើអាជីវកម្មនេសាទប្រមូលផលធនធានជលផល ស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផល ឬតម្រូវការចាំបាច់ផ្សេងទៀត។*" ផ្អែកតាមបទប្បញ្ញត្តិនេះ យើងសន្និដ្ឋានបានថា អាជ្ញាធរកាន់កាប់ដីរដ្ឋ(ដែននេសាទ)គឺ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ រីឯរដ្ឋបាលជលផល ជាអង្គភាពទទួលបន្ទុកអនុវត្តផ្ទាល់។ មាត្រា៦ នៃនីតិជលផលឆ្នាំ២០០៦ បានបញ្ញត្តិថាៈ"*រដ្ឋបាលជលផល គឺជាអាជ្ញាធររដ្ឋាភិបាលដែលចំណុះក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានភារកិច្ចគ្រប់គ្រងជលផលនិងធនធានជលផលស្របតាមគោលនយោបាយវិស័យជលផលជាតិ និងខ្លឹមសារនៃច្បាប់នេះ។...។*"

ដូចនេះ ផ្អែកតាមសម្មតិកម្មគតិយុត្តខាងលើ អាជ្ញាធរកាន់កាប់ដែននេសាទគឺ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ចំណែករដ្ឋបាលជលផល ជាអាជ្ញាធររដ្ឋាភិបាលទទួលបន្ទុកផ្ទាល់ដោយមានភារកិច្ចគ្រប់គ្រងជលផល និងធនធានជលផល។

### ខ- ការធ្វើអត្តសញ្ញាណកម្មដែននេសាទ

### ខ-១- គោលការណ៍ទូទៅ

គោលការណ៍ណែនាំទូទៅសម្រាប់ការធ្វើអត្តសញ្ញាណកម្មដែននេសាទ និងដែនទី អនុលោមតាមប្រការ៣

ប្រការ៤ និងប្រការ៥ នៃប្រកាសលេខ ៤២ ដនស.បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៦ ស្តីពីការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋបានធ្វើការណែនាំអំពីគោលការណ៍មួយចំនួនដូចខាងក្រោម៖

**-អំពីដំណើរការ**

ការធ្វើអត្តសញ្ញាណកម្មនិងការធ្វើផែនទីដីរដ្ឋ ឬដែននេសាទ ជាដំណើរការមួយដែលត្រូវតែមានការសម្របសម្រួលនិងតម្លាភាព ព្រមទាំងធ្វើឡើងដោយមានកិច្ចសហការរួមគ្នារវាងក្រសួង ស្ថាប័ន អាជ្ញាធរដែនដីនិងប្រជាពលរដ្ឋដែលរស់នៅក្នុងមូលដ្ឋាន។

ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ត្រូវដំណើរការធ្វើអត្តសញ្ញាណកម្មនិងការធ្វើផែនទីដីរដ្ឋ ឬដែននេសាទនៅតាមឃុំ/សង្កាត់នីមួយៗ ដោយចាប់ផ្តើមពីភូមិមួយទៅភូមិមួយដែលស្ថិតនៅក្នុងឃុំ/សង្កាត់នោះ។ បញ្ហានេះ រដ្ឋបាលជលផលដែលជាអង្គភាពទទួលបន្ទុកនិងអនុវត្តផ្ទាល់ (នាយកដ្ឋានកិច្ចការជលផល)នោះ ត្រូវសហការជាមួយក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌពាក់ព័ន្ធ ដើម្បីឱ្យដំណើរការនិងសកម្មភាពអនុវត្តទៅបានប្រកបដោយរលូន ជាពិសេសការប្រមូលព័ត៌មានផ្សេងៗ ដែលពាក់ព័ន្ធនឹងដីរដ្ឋឬដែននេសាទ។ ប៉ុន្តែព័ត៌មានដែលទទួលបាននេះ ជាគោលការណ៍ត្រូវបានចាត់ទុកថា ជាព័ត៌មានបឋមនិងមិនទាន់ចាត់ទុកជាផ្លូវការទេ ដរាបណាដីរដ្ឋឬដែននេសាទនោះពុំទាន់បានចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី។

**-ផែនទីនិងឧបករណ៍សម្រាប់ប្រមូលព័ត៌មាន**

មន្ទីររៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវផ្តល់ផែនទីអរតូហ្វូតូកម្រិតភូមិ ឃុំ/សង្កាត់ និងស្រុក/ខណ្ឌ ឬផែនទីរូបថតពីលើអាកាសក្នុងករណីមិនទាន់បានផលិតផែនទីអរតូហ្វូតូសម្រាប់តំបន់នោះ ក្រដាសកាល់ប្លង់ផែនទី ឧបករណ៍ GPS និងឧបករណ៍ចាំបាច់ផ្សេងទៀត ជូនក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋរាជធានី ខេត្តដែលសហការជាមួយអាជ្ញាធរកាន់កាប់ដីរដ្ឋ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)និងរដ្ឋបាលជលផលដែលទទួលបន្ទុកផ្ទាល់សម្រាប់ប្រើប្រាស់ក្នុងការបំពេញបេសកកម្មរបស់ខ្លួន។

**-ថវិកាសម្រាប់បម្រើការងារ**

ចំពោះថវិកាសម្រាប់ចំណាយលើការងារខាងលើ ប្រការ៦ នៃប្រកាសលេខ ៤២ ដនស.បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៦ ដដែលបានកំណត់ថា ប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ត្រូវរៀបចំផែនការសកម្មភាពលម្អិត និងសំណើថវិកាសម្រាប់ចំណាយលើការអនុវត្តសកម្មភាពក្នុងផែនការ ព្រមទាំងធ្វើការតាមដាននិងធ្វើរបាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត។

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវពិនិត្យជ្រើសរើសនិងបូកសរុបសំណើ ដើម្បីបញ្ជូនទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចេញសេចក្តីណែនាំអំពីការរៀបចំគម្រោងថវិកា សំណើ

ថវិកាសម្រាប់ចំណាយលើសកម្មភាពក្នុងផែនការទាក់ទងនឹងការគ្រប់គ្រងដីរដ្ឋឬដែននេសាទដល់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត និងក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ។

ចំពោះការរៀបចំដំណើរការសកម្មភាពការងារធ្វើអត្តសញ្ញាណកម្មដែននេសាទនិងផែនទី ចាំបាច់ត្រូវមានកិច្ចសហការរវាងរដ្ឋបាលជលផលដែលមាននាយកដ្ឋានកិច្ចការជលផលទទួលបន្ទុកផ្ទាល់ជាមួយគណៈកម្មាធិការគ្រប់-គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត និងក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌក្នុងការពិនិត្យជ្រើសរើសទីតាំងដើម្បីធ្វើអត្តសញ្ញាណកម្មដែននេសាទ និងត្រូវរៀបចំគម្រោងថវិកាសម្រាប់ចំណាយទៅលើសកម្មភាពទាំងនោះ។

ផ្អែកតាមប្រកាសលេខ ៤២ ដនស.បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៦ ខាងលើ គឺប្រគល់សិទ្ធិជូនប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ដើម្បីរៀបចំផែនការសកម្មភាពលម្អិតនិងសំណើថវិកាសម្រាប់ចំណាយលើសកម្ម-ភាពក្នុងផែនការ ហើយធ្វើការតាមដាននិងធ្វើរបាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ដើម្បីពិនិត្យជ្រើសរើសនិងបូកសរុបសំណើបញ្ជូនទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ផ្ទុយទៅវិញពាក់ព័ន្ធទៅនឹងការសិក្សាវាយតម្លៃធ្វើចំណាត់ថ្នាក់កំណត់ព្រំប្រទល់ដែននេសាទ និងការបង្កើតផែនទីដែននេសាទមាត្រា១៤ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ឆ្នាំ២០០៨ បានប្រគល់ជូនអង្គភាពរដ្ឋបាលជលផលទទួលបន្ទុក។

ដូចនេះ រដ្ឋបាលជលផលចាំបាច់ត្រូវរៀបចំផែនការសកម្មភាពលម្អិតនិងលើកសំណើស្នើសុំថវិកាសម្រាប់ការចំណាយទៅលើសកម្មភាពដែលពាក់ព័ន្ធទៅនឹងការសិក្សាវាយតម្លៃធ្វើចំណាត់ថ្នាក់កំណត់ព្រំប្រទល់ដែននេសាទនិងការបង្កើតផែនទីដែននេសាទដោយសហការជាមួយក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

### ខ-២- ការត្រៀមរៀបចំនិងការជូនដំណឹង

បញ្ហានេះ ប្រការ៧ នៃប្រកាសលេខ៤២ ដនស.បក ចុះថ្ងៃទី១០ ខែមីនាឆ្នាំ២០០៦ ស្តីពីការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋបានកំណត់ថា មុនចាប់ផ្តើមប្រមូលព័ត៌មានក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ត្រូវធ្វើកិច្ចការមួយចំនួនដូចខាងក្រោមៈ

-រៀបចំបញ្ជីឈ្មោះក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងអាជ្ញាធរទាំងអស់ដែលមាននៅក្នុងមូលដ្ឋានស្រុក ខណ្ឌ

-ស្នើសុំសេចក្តីចម្លងនូវផ្នែកពាក់ព័ន្ធនៃបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (ដីរដ្ឋក្នុងស្រុក ខណ្ឌ ទោះមានអគារឬគ្មានអគារ)ពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីពិនិត្យមើលឱ្យដឹងអំពីឈ្មោះក្រសួង ស្ថាប័នអង្គភាពរដ្ឋ និងអាជ្ញាធរដែលកាន់កាប់ដីរដ្ឋនៅក្នុងស្រុក ខណ្ឌនោះ

-រៀបចំនិងផ្តល់សេចក្តីជូនដំណឹងដោយប្រើទម្រង់ដូចក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសលេខ៤២ដនស.បកដដែលខាងលើនិងសេចក្តីពន្យល់អំពីគោលបំណងដំណើរការនិងភារកិច្ចទាក់ទងនឹងការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទីនិងការធ្វើចំណាត់ថ្នាក់ដីរដ្ឋដល់ក្រសួង ស្ថាប័នអង្គភាពរដ្ឋ និងអាជ្ញាធរក្នុងឃុំ សង្កាត់នោះ។ ក្នុងសេចក្តីជូនដំណឹង

ត្រូវមានបញ្ជាក់ពីពេលវេលាដែលបានកំណត់សម្រាប់ចុះជួបប្រមូលព័ត៌មាននិងមានសេចក្តីស្នើឱ្យតំណាងប្រចាំមូលដ្ឋានរបស់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងអាជ្ញាធរពាក់ព័ន្ធរៀបចំប្រមូលឯកសារពាក់ព័ន្ធដីរដ្ឋទុកជាស្រេចមុនការចុះជួបប្រមូលព័ត៌មាន

-រៀបចំនិងផ្តល់សេចក្តីជូនដំណឹងដល់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ដើម្បីត្រៀមលក្ខណៈចូលរួមផ្តល់មតិយោបល់លើផែនទីនិងព័ត៌មានអំពីដីរដ្ឋដែលនឹងប្រមូលបានពីភូមិ និងឃុំ/សង្កាត់ ដោយប្រើប្រាស់ទម្រង់ដូចមានក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសលេខ៤២ ដនស.បកដដែល។

**-ការជូនដំណឹងដល់ប្រជាពលរដ្ឋ**

ចំពោះការជូនដំណឹងដល់ប្រជាពលរដ្ឋវិញ ប្រការ៨ នៃប្រកាសលេខ៤២ ដនស.បកដដែលបានកំណត់ថាប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ត្រូវចាត់ចែងបញ្ជូនលិខិតជូនដំណឹងអំពីការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋដល់ប្រជាពលរដ្ឋទៅគ្រប់មេភូមិនិងមេឃុំ/ចៅសង្កាត់ពាក់ព័ន្ធ ដើម្បីបិទផ្សាយនៅសាលាឃុំ សង្កាត់ នៅទីសាធារណៈដូចជាៈ សាលារៀន វត្តអារាម ទីផ្សារ រោងជំនុំ សាលាឆទាន និងនៅមុខផ្ទះរបស់មេភូមិ។ ក្នុងមួយភូមិៗ ត្រូវផ្តល់លិខិតជូនដំណឹងយ៉ាងតិចចំនួន១០ ច្បាប់ ដើម្បីយកទៅបិទផ្សាយជាសាធារណៈនិងរក្សាទុក ១ ច្បាប់ដោយមេភូមិ និង១ ច្បាប់ទៀតរក្សាទុកនៅសាលាឃុំ/សង្កាត់។

មេភូមិ ចៅសង្កាត់ ឬមេឃុំ ត្រូវចាត់ឱ្យមេភូមិពាក់ព័ន្ធអានប្រកាសសេចក្តីជូនដំណឹងនេះតាមឧគ្ឃោសនសព្ទផងដែរ។ ក្នុងករណីដែលក្នុងភូមិ ឃុំ/សង្កាត់មានជនជាតិដើមភាគតិចរស់នៅ ត្រូវបកប្រែលិខិតជូនដំណឹងជាភាសាជនជាតិដើមនិងត្រូវពន្យល់អំពីខ្លឹមសារនៃលិខិតជូនដំណឹងនោះដល់អាជ្ញាធរប្រពៃណីរបស់ក្រុមជនជាតិដើមភាគតិចនីមួយៗ។

**-ការប្រមូលព័ត៌មានពីសមាជិកក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ**

សមាជិកនីមួយៗ នៃក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ត្រូវបំពេញតារាងទិន្នន័យស្តីពីការប្រកាសអះអាងដីរដ្ឋដោយប្រើទម្រង់ដូចក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសលេខ៤២ ដនស.បកដដែល និងត្រូវរៀបចំឯកសារបង្ហាញមតិអះ-អាងដែលត្រូវបានបញ្ចប់ក្នុងរយៈពេល៣០ ថ្ងៃ គិតពីថ្ងៃចែកតារាងទិន្នន័យ។

ប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ត្រូវរៀបចំប្រជុំជាមួយសមាជិកក្នុងក្រុម ដើម្បីធ្វើការគូសបង្ហាញដីរដ្ឋដែលសមាជិកនីមួយៗ បានប្រកាសអះអាងនៅលើក្រដាសកាល់ផែនទីកម្រិតភូមិ។

សមាជិកនីមួយៗ នៃក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ជាអ្នកគូសបង្ហាញដីដែលខ្លួនប្រកាសអះអាងថា ជាដីរដ្ឋនៅលើក្រដាសកាល់ផែនទីនោះដោយផ្ទាល់ម្នាក់ម្តងៗ ដោយមិនគិតថា ដីនេះជាន់លើដីដែលប្រកាសអះអាងដោយតំណាងក្រសួង ស្ថាប័ន អង្គភាពរដ្ឋ ឬអាជ្ញាធរផ្សេងទៀតឡើយ។

នៅពេលប្រជុំ សមាជិកណាម្នាក់នៃក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ អាចបង្ហាញការប្រកាសអះអាងនិង

ភស្តុតាងថ្មីៗ ទៀតដែលខ្លួនទើបរកឃើញ។

ប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ត្រូវចាត់ចែងឱ្យមានបញ្ជីវត្តមានដែលមានចុះហត្ថលេខារបស់អ្នកចូលរួមទាំងអស់ដោយប្រើទម្រង់ដូចក្នុងក្នុងឧបសម្ព័ន្ធទី៨ នៃប្រកាសលេខ៤២ ដនស.បកដដែល។

ចំពោះបញ្ហានេះ បន្ទាប់ពីការកែសម្រួលបញ្ចូលសមាសភាពផ្នែករដ្ឋបាលជលផលទៅក្នុងក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌរួចហើយ សមាជិកនៃអង្គភាពរដ្ឋបាលជលផលត្រូវបង្ហាញភស្តុតាងគតិយុត្តដែលមានឬឯកសារផ្សេងៗ (មានបញ្ជាក់នៅក្នុងសេចក្តីសន្និដ្ឋាន) ដើម្បីបញ្ជាក់អះអាងថា ដីនេះពិតជាដែននេសាទនិងជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋប្រាកដមែន។

**-តួនាទី ភារកិច្ចក្រុមការងារវាល**

តើអ្វីទៅក្រុមការងារវាល ? ក្រុមការងារវាលអនុលោមតាមប្រការ១០ នៃប្រកាសលេខ៤២ ដនស.បកដដែលបានបញ្ជាក់ថា គឺជាមនុស្ស១ ក្រុមដែលបានជ្រើសរើសចេញពីសមាជិកយ៉ាងតិចចំនួន៣ នាក់ក្នុងចំណោមសមាជិកនៃក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌទាំងមូល ហើយចាត់តាំងដោយប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ឱ្យចូលរួមធ្វើការជាមួយមេឃុំឬចៅសង្កាត់ពាក់ព័ន្ធ ដើម្បីចុះជួបតំណាងក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងអាជ្ញាធរផ្សេងទៀតដែលមិនមែនជាសមាជិកក្រុមក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ក្នុងការប្រមូលព័ត៌មាននិងការប្រកាសអះអាងអំពីដីរដ្ឋ ព្រមទាំងឯកសារភស្តុតាងនានាដែលគាំទ្រដល់ការប្រកាសអះអាងនេះ។

ដូចគ្នាដែរ សមាជិកក្នុងក្រុមការងារវាលដាច់ខាតត្រូវមានសមាសភាពផ្នែករដ្ឋបាលជលផលចូលរួម ដើម្បីបង្ងាយស្រួលក្នុងការផ្តល់ភស្តុតាងឬឯកសារគតិយុត្តសម្រាប់ធ្វើអត្តសញ្ញាណកម្មដែននេសាទបានច្បាស់លាស់។

**-ការគូសបង្ហាញព្រំប្រទល់ដីនៅលើក្រដាសកាល់ផែនទីកម្រិតភូមិ**

ក្រុមការងារវាល មានភារកិច្ចស្នើឱ្យតំណាងក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងអាជ្ញាធរដែលមិនមែនជាសមាជិកក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ គូសបង្ហាញឬណែនាំអំពីការគូសដែលបានប្រកាសអះអាងនោះនៅលើក្រដាសកាល់ផែនទីកម្រិតភូមិដោយផ្ទាល់ម្នាក់ម្តងៗ ដោយមិនគិតថា គងឬជាន់លើដីដែលប្រកាសអះអាងដោយតំណាងក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងអាជ្ញាធរផ្សេងទៀតទេ (ប្រការ១១ នៃប្រកាសលេខ៤២ ដនស.បកដដែល)។

**-ការចុះទៅអង្កេតទីតាំងក្បាលដី**

ក្រុមការងារវាល ត្រូវចុះទៅវាលជាមួយតំណាងក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងអាជ្ញាធរដែលបានប្រកាសអះអាងអំពីដីរដ្ឋនៅក្នុងឃុំ/សង្កាត់នោះ ដើម្បីទទួលបានការចង្អុលបង្ហាញទីតាំងជាក់ស្តែងនិងព្រំប្រទល់ប្រហាក់ប្រហែលដីនោះសម្រាប់ធ្វើការផ្ទៀងផ្ទាត់ជាមួយគំនូសនៅលើក្រដាសកាល់ផែនទីកម្រិតភូមិ។ ក្នុងករណីដែលអាចធ្វើទៅបាន ក្រុមការងារវាលត្រូវដើរពិនិត្យមើលស្ថានភាពជុំវិញក្បាលដីនីមួយៗនិងធ្វើការកត់ត្រាទុកជាកំណត់ហេតុនូវរាល់ការសង្កេតឃើញនានាអំពីស្ថានភាពប្រើប្រាស់ដី។

ប្រសិនជាការគូសនៅលើប្លង់ផែនទីមុនពេលចុះវាលខុសពីភាពជាក់ស្តែងដែលសង្កេតឃើញនៅវាល ក្រុមការងារវាល ត្រូវស្នើការឯកភាពពីតំណាងក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងអាជ្ញាធរដែលបានប្រកាសអះអាងដើម្បីធ្វើការកែសម្រួលនៅលើក្រដាសកាល់ផែនទីនោះ។ ប្រសិនបើតំណាងក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងអាជ្ញាធរដែលនោះមិនយល់ព្រមចំពោះសំណើកែតម្រូវទេ ក្រុមការងារវាលត្រូវរក្សាទុកតាមមតិរបស់តំណាងនោះ ប៉ុន្តែត្រូវសរសេរកំណត់ហេតុអំពីភាពខុសគ្នារវាងការប្រកាសអះអាងនិងភាពមើលឃើញជាក់ស្តែងសម្រាប់បញ្ចូលទៅក្នុងរបាយការណ៍របស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌនិងត្រូវធ្វើកំណត់សម្គាល់នៅលើក្រដាសកាល់ផែនទីត្រង់ចំណុចនៃទីតាំងមានបញ្ហានោះ។

សមាជិកក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌណាម្នាក់ដែលអះអាងថា ក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងអាជ្ញាធរដែលខ្លួនជាតំណាងមានដីរដ្ឋ ហើយឋិតនៅក្រោមអាណត្តិកាន់កាប់និងគ្រប់គ្រងរបស់ខ្លួន ឬដឹងនិងប្រកាសថា មានដីរដ្ឋនៅក្នុងភូមិនិងឃុំ/សង្កាត់គោលដៅ ចាំបាច់ត្រូវចុះទៅវាលជាមួយក្រុមការងារវាល ដើម្បីចង្អុលបង្ហាញទីតាំងជាក់ស្តែងនិងព្រំប្រទល់ប្រហាក់ប្រហែលនៃដីនោះ និងផ្ទៀងផ្ទាត់គំនូរលើក្រដាសកាល់ផែនទីកម្រិតភូមិ (ប្រការ១២ នៃប្រកាសលេខ៤២ ដនស.បកដដែល)។

**-ការបង្ហាញការប្រើប្រាស់ដីដោយបុគ្គលឯកជន**

ក្នុងករណីក្រុមការងារវាលសង្កេតឃើញមានការកាន់កាប់ឬការប្រើប្រាស់ដោយបុគ្គលឯកជន ឬដោយប្រជាជនចំពោះក្បាលដីទាំងមូលឬចំណែកណាមួយនៃក្បាលដីដែលតំណាងក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងអាជ្ញាធរណាមួយបានប្រកាសអះអាងថាជាដីរដ្ឋ ក្រុមការងារវាលត្រូវធ្វើរបាយការណ៍សង្ខេបអំពីស្ថានភាពនៃការកាន់កាប់ឬការប្រើប្រាស់ និងធ្វើសញ្ញាសម្គាល់នៅលើក្រដាសកាល់ផែនទីភូមិនោះ (ប្រការ១៣ នៃប្រកាសលេខ៤២ ដនស.បកដដែល)។

បញ្ហានេះ យើងសង្កេតឃើញមានការចូលកាន់កាប់ដីធ្លីក្នុងដែននេសាទជាច្រើនរហូតដល់មានការផ្តល់កម្មសិទ្ធិថែមទៀតផង។ ដូចនេះ នាយផ្នែករដ្ឋបាលជលផលដែលជាសមាជិកក្រុមការងារវាល ត្រូវធ្វើរបាយការណ៍សង្ខេបអំពីស្ថានភាពនៃការកាន់កាប់ឬការប្រើប្រាស់ និងធ្វើសញ្ញាសម្គាល់នៅលើក្រដាសកាល់ផែនទីភូមិនោះ ដើម្បីផ្ញើជូនក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌចាត់ការបន្ត។

**-ការប្រកាសដីរដ្ឋដោយក្រុមប្រឹក្សាឃុំ/សង្កាត់ក្នុងនាមរដ្ឋ**

នៅក្នុងដំណើរការសកម្មភាពនេះ ទោះបីកំពុងធ្វើការងារវាលឬក្រោយពេលបញ្ចប់ការងារវាល ក្នុងករណីសង្កេតឃើញមានដីទំនេរដោយគ្មានបុគ្គលឯកជនកាន់កាប់ជាភោគៈស្របច្បាប់ឬជាកម្មសិទ្ធិ ហើយគ្មានក្រសួង ស្ថាប័ន អង្គភាពរដ្ឋ ឬអាជ្ញាធរណាមួយបានប្រកាសអះអាងថាជាដីរដ្ឋទេ ក្រុមប្រឹក្សាឃុំ/សង្កាត់ដែលពាក់ព័ន្ធមានភារកិច្ចរាយការណ៍និងពិពណ៌នាអំពីស្ថានភាព និងលក្ខណៈដីនោះឱ្យច្បាស់លាស់ជូនដល់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក

ខណ្ឌ ឬក្រុមការងារវាល។ ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ឬក្រុមការងារវាល ត្រូវចាត់ទុកសេចក្តីរាយការណ៍ជូនដំណឹងនោះថា ជាការប្រកាសដីរដ្ឋដោយក្រុមប្រឹក្សាឃុំ/សង្កាត់ក្នុងនាមរដ្ឋ (ប្រការ១៤ នៃប្រកាសលេខ៤២ ដនស.បកដដែល)។ ផ្ទុយទៅវិញ បញ្ហានេះមានមេភូមិ មេឃុំ ឬចៅសង្កាត់មួយចំនួនបែរជាឃុបឃិតជាមួយអ្នកកាន់កាប់ដីជាក់ស្តែងធ្វើការរៀបចំសំណុំឯកសារសុរិយោដី ដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីនៅក្នុងដែននេសាទដែលជាប្រការផ្ទុយទៅនឹងនីតិភូមិបាលឆ្នាំ២០០១ និងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ទៅវិញដោយហេតុថា ការទទួលបានកម្មសិទ្ធិដីធ្លីក្នុងដែននេសាទគឺ ពុំអាចទទួលបានតាមលទ្ធកម្មនៃកម្មសិទ្ធិបានទេ (មាត្រា១៦ និងមាត្រា៤៣ នៃនីតិភូមិបាលឆ្នាំ២០០១ និងមាត្រា១៧៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧)។ ផ្ទុយទៅវិញ ការផ្តល់កម្មសិទ្ធិដីធ្លីក្នុងដែននេសាទ ហើយត្រូវបានចាត់ទុកថាស្របច្បាប់នោះ គឺការអនុវត្តតាមកម្មវិធីសម្បទានដីសង្គមកិច្ច(មាត្រា១៧ មាត្រា៤៩ មាត្រា៥១ និងមាត្រា៥៨ នៃនីតិភូមិបាលឆ្នាំ២០០១)។

**-ការធ្វើសមាហរណកម្មផែនទីដីរដ្ឋ**

នៅពេលធ្វើការងារវាលចប់សម្រាប់ដីមួយភូមិៗ ក្រុមការងារវាលត្រូវសម្រេចបាននូវប្លង់ផែនទីដីរដ្ឋសម្រាប់ភូមិនោះដែលនឹងត្រូវធ្វើសមាហរណកម្មទៅក្នុងផែនទីដីរដ្ឋសរុបសម្រាប់ឃុំ/សង្កាត់នីមួយៗ និងបន្ទាប់មកទៀត ត្រូវធ្វើសមាហរណកម្មទៅក្នុងផែនទីដីរដ្ឋសរុបសម្រាប់ស្រុក ខណ្ឌទាំងមូល។ ផែនទីទាំងនោះ បង្ហាញឱ្យឃើញនូវរាល់ការអះអាងនិងការប្រកាសដីរដ្ឋរបស់ក្រសួង ស្ថាប័ន អង្គភាព និងអាជ្ញាធរទាំងអស់ដែលមាននៅក្នុងស្រុក ខណ្ឌនោះ។ ផែនទីដីរដ្ឋដែលបានធ្វើសមាហរណកម្មរួចហើយនោះ ត្រូវមានបញ្ចូលទាំងការអះអាងស្របគ្នា ការអះអាងមិនស្របគ្នា ការអង្កេតឃើញលើដីជាក់ស្តែងខុសពីការអះអាងនិងការកាន់កាប់ ឬប្រើប្រាស់ដោយបុគ្គលឯកជនឬប្រជាពលរដ្ឋដែលក្រុមការងារវាលបានសង្កេតឃើញ។

ក្រុមការងារវាល ត្រូវដាក់ជូនប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌនូវផែនទីបង្ហាញការអះអាងឬការប្រកាសដីរដ្ឋកម្រិតភូមិ ឃុំ/សង្កាត់ និងស្រុក ខណ្ឌ ព្រមទាំងរបាយការណ៍និងកំណត់ហេតុនានាទាក់ទងនឹងការងារវាលដោយមានចុះហត្ថលេខារបស់សមាជិកទាំងអស់នៃក្រុមការងារវាលនៅពេលបញ្ចប់ការងារវាលសម្រាប់កម្រិតនីមួយៗ (ប្រការ១៥ នៃប្រកាសលេខ៤២ ដនស.បកដដែល)។

**២- នីតិវិធីធ្វើផែនទីដីរដ្ឋឬដែននេសាទ**

**ក- ការឯកភាពមតិគ្នារបស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ**

**ក-១- ការប្រជុំស្វែងរកការឯកភាពមតិគ្នាលើផែនទី**

ក្នុងរយៈពេល១៥ ថ្ងៃបន្ទាប់ពីទទួលបានរបាយការណ៍និងឯកសារពាក់ព័ន្ធពីក្រុមការងារវាល ប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ត្រូវរៀបចំការប្រជុំ ដើម្បីព្យាយាមរកការឯកភាពមតិគ្នាចំពោះដីរដ្ឋទាក់ទងនឹងអាណត្តិកាន់-កាប់ដីរដ្ឋនិងចំណាត់ថ្នាក់ដីរដ្ឋទាំងអស់ដែលមានក្នុងឃុំ/សង្កាត់នោះ មុននឹងបិទផ្សាយលទ្ធផលជាសាធារណៈ។

ប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ត្រូវអញ្ជើញតំណាងក្រសួង ស្ថាប័ន អង្គភាព និងអាជ្ញាធរផ្សេងទៀត ដែលមិនមែនជាសមាជិកក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ប៉ុន្តែបានអះអាងថា ក្រសួង ស្ថាប័ន អង្គភាព និងអាជ្ញាធររបស់ខ្លួនមានអាណត្តិកាន់កាប់ក្បាលដីណាមួយឬប្រកាសក្បាលដីណាមួយក្នុងឃុំ/សង្កាត់ថា ជាដីរដ្ឋឱ្យចូលរួមក្នុងកិច្ចប្រជុំសម្របសម្រួលនោះផងដែរ។

ប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ត្រូវជូនដំណឹងនិងផ្ដល់ឯកសារជូនសមាជិកខ្លួនយ៉ាងតិច៧ ថ្ងៃ មុនកាលបរិច្ឆេទប្រជុំ។ រាល់សមាជិកនៃក្រុមការងារ ប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ត្រូវតែចូលរួមក្នុងកិច្ចប្រជុំពិភាក្សា ដើម្បីស្វែងរកមតិឯកភាពទៅលើផែនទី។ សមាជិកឬតំណាងក្រសួង ស្ថាប័ន អង្គភាព និងអាជ្ញាធរណាមួយដែលមិនចូលរួមក្នុងការប្រជុំដោយគ្មានមូលហេតុអាចទទួលយកបាន ត្រូវចាត់ទុកថាឯកភាពតាមសេចក្ដីសម្រេចរបស់អង្គប្រជុំនោះ ទោះបីជាយ៉ាងណាក៏ដោយការឯកភាពគ្នានេះមិនផ្ទុយនឹងច្បាប់និងបទប្បញ្ញត្តិជាធរមានឡើយ។

ចំពោះដីរដ្ឋដែលមិនទាន់បានប្រគល់ជូនទៅក្រសួង ស្ថាប័ន អង្គភាព ឬអាជ្ញាធរណាមួយជាក់លាក់កាន់កាប់ទេនោះ ដីនេះត្រូវបានដាក់ឱ្យឋិតនៅក្នុងអាណត្តិកាន់កាប់របស់ជាតិដែលជាកម្មវត្ថុនៃការធ្វើផែនការបែងចែក (ប្រការ១៦នៃប្រកាសលេខ៤២ ដនស.បកដដែល)។

**ក-២- ការចូលរួមជាសាធារណៈ**

បន្ទាប់ពីការប្រជុំសម្របសម្រួលនិងបានកែសម្រួលផែនទីដីរដ្ឋតាមលទ្ធផលនៃការប្រជុំរួចហើយ ប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ត្រូវរៀបចំនិងបិទផ្សាយជាសាធារណៈរយៈពេល៣០ ថ្ងៃ នូវឯកសារដូចខាងក្រោមៈ

-សេចក្ដីសង្ខេបអំពីការអះអាងឬការប្រកាសដីរដ្ឋ

-ផែនទីកម្រិតភូមិនិងឃុំ/សង្កាត់ដែលបង្ហាញការអះអាង ឬប្រកាសដីរដ្ឋ។

មេឃុំ/ចៅសង្កាត់ ត្រូវចាត់ចែងឱ្យមេភូមិធ្វើការបិទផ្សាយសេចក្ដីជូនដំណឹងនិងប្រកាសជូនដំណឹងដល់ប្រជាពលរដ្ឋតាមឧគ្ឃោសនសព្ទឱ្យមកពិនិត្យមើលលទ្ធផលនិងបញ្ចេញមតិដោយបញ្ជាក់ទីតាំង និងពេលវេលាបិទផ្សាយឯកសារលទ្ធផលនោះឱ្យបានច្បាស់លាស់យ៉ាងហោចណាស់មួយកន្លែងក្នុងមួយភូមិ។

ប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ត្រូវចាត់ឱ្យមានអ្នកចាំទទួលឬកត់ត្រានៅសាលាឃុំ/សង្កាត់ និង/ឬនៅទីសាធារណៈណាមួយសមស្របនូវមតិយោបល់របស់ប្រជាពលរដ្ឋដោយបង្ហាញឈ្មោះឬមិនបាច់បង្ហាញឈ្មោះអ្នកផ្ដល់មតិឡើយ។ ប៉ុន្តែបើមតិបញ្ចេញនោះ ជាមតិក្នុងនាមអាជ្ញាធរ ត្រូវបញ្ជាក់ឈ្មោះនិងតួនាទីរបស់មន្ត្រីនោះផង។

ចំពោះអ្នកចាំទទួលឬអ្នកកត់ត្រាមតិយោបល់ អាចជាមន្ត្រីឬជាប្រជាពលរដ្ឋនៅក្នុងឃុំ/សង្កាត់ដែលមានចំណេះដឹង រួសរាយរាក់ទាក់ និងចេះសរសេរអក្សរខ្មែរបានច្បាស់លាស់។

ក្នុងករណីដែលមានជនជាតិដើមភាគតិចរស់នៅក្នុងភូមិ/ឃុំនោះ ប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ត្រូវរក

អ្នកចេះស្តាប់និងនិយាយភាសាជនជាតិដើមភាគតិចនោះ ដើម្បីជួយបកប្រែជូនអ្នកចាំទទួលឬអ្នកកត់ត្រា។

ប្រសិនបើមានការផ្តល់មតិយោបល់ជាលាយលក្ខណ៍អក្សរដោយអង្គការសង្គមស៊ីវិលឬអង្គការក្រៅរដ្ឋាភិបាល ដែលមានភ្នាក់ងារប្រចាំមូលដ្ឋានភូមិ ឃុំ/សង្កាត់នោះ អ្នកចាំទទួលឬកត់ត្រាមតិសាធារណៈនោះ ត្រូវទទួលយកមតិនោះជូនទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ដើម្បីធ្វើការពិចារណា (ប្រការ១៧ នៃប្រកាសលេខ ៤២ ដនស.បកដដែល)។

**-ការប្រមូលនិងសង្ខេបមតិសាធារណៈ**

ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈ៣០ ថ្ងៃ ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ត្រូវប្រមូលមតិយោបល់សាធារណៈទាំងអស់ ទោះជាធ្វើដោយផ្ទាល់មាត់ឬជាលាយលក្ខណ៍អក្សរ ហើយត្រូវធ្វើសេចក្តីសង្ខេបមតិយោបល់ជាសាធារណៈដែលបានទទួលក្នុងរយៈពេលមិនលើសពី១៥ ថ្ងៃ ក្រោយពីការបញ្ចប់ការបិទផ្សាយជាសាធារណៈដោយប្រើទម្រង់ដូចមានក្នុងឧបសម្ព័ន្ធទី៦ នៃប្រកាសលេខ៤២ ដនស.បក (ប្រការ១៨ នៃប្រកាសលេខ៤២ ដនស.បកដដែល)។

**-ការទាមទារសិទ្ធិឯកជនលើក្បាលដី**

ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ គ្មានសិទ្ធិនិងភារកិច្ចដោះស្រាយ ឬសម្រេចលើការតវ៉ាទាមទារសិទ្ធិឯកជនលើក្បាលដីដោយបុគ្គលឬប្រជាជនណាមួយឡើយតែត្រូវបញ្ជាក់ថា ព័ត៌មានដែលប្រមូលបាននោះ ត្រូវចាត់ទុកជាព័ត៌មានបឋមនិងមិនទាន់មានការបញ្ជាក់ច្បាស់លាស់ជាផ្លូវការរហូតដល់ដីនោះ ត្រូវបានចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី (ប្រការ១៩ នៃប្រកាសលេខ៤២ ដនស.បកដដែល)។

**-ការរាយការណ៍អំពីការទន្ទ្រានកាន់កាប់ដីរដ្ឋ**

ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ត្រូវយកចិត្តទុកដាក់ខ្ពស់ចំពោះមតិយោបល់ដែលទាក់ទងនឹងប្រយោជន៍សាធារណៈដែលមានចំពោះក្បាលដីណាមួយឬការទន្ទ្រានកាន់កាប់ដីរដ្ឋដោយខុសច្បាប់តាមមធ្យោបាយផ្សេងៗ និងត្រូវចាត់វិធានការរក្សាអនាមិកភាព និងការពារសុវត្ថិភាពតាមករណីចាំបាច់ដល់អ្នកផ្តល់ព័ត៌មាននោះ (ប្រការ២០ នៃប្រកាសលេខ៤២ ដនស.បកដដែល)។

**ខ- របាយការណ៍របស់ក្រុមការងារដីរដ្ឋថ្នាក់រាជធានី ខេត្ត**

**ខ-១- ឯកសារដែលត្រូវបញ្ចូលក្នុងរបាយការណ៍**

ក្នុងរយៈពេលមិនលើសពី៣០ ថ្ងៃ បន្ទាប់ពីបញ្ចប់សេចក្តីសង្ខេបមតិសាធារណៈសម្រាប់ឃុំ/សង្កាត់នីមួយៗ មកក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ត្រូវបញ្ជូនរបាយការណ៍ដោយប្រើទម្រង់ដូចមានក្នុងឧបសម្ព័ន្ធទី៩ នៃប្រកាសលេខ៤២ដនស.បក និងឯកសារពាក់ព័ន្ធទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត តាមរយៈលេខាធិការដ្ឋាន។

ចំពោះឯកសារពាក់ព័ន្ធមានដូចខាងក្រោមៈ

-បញ្ជីរាយឈ្មោះឯកសារដែលបានបញ្ចូលនៅក្នុងសំណុំឯកសាររបាយការណ៍ស្ដីពីការធ្វើអត្តសញ្ញាណកម្មការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ

-តារាងទិន្នន័យស្ដីពីការអះអាងចំពោះការកាន់កាប់ដីរដ្ឋដោយសមាជិកនីមួយៗ នៃក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌនិងដោយតំណាងក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងអាជ្ញាធរផ្សេងៗ ទៀតនៅក្នុងភូមិ ឃុំ/សង្កាត់ និងស្រុក ខណ្ឌពាក់ព័ន្ធដោយប្រើទម្រង់ដូចមានក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសលេខ៤២ ដនស.បក

-តារាងសង្ខេបទិន្នន័យស្ដីពីការអះអាងនិងការប្រកាសដីរដ្ឋទាំងអស់ដែលមាននៅក្នុងភូមិ ឃុំ/សង្កាត់ និងស្រុក ខណ្ឌពាក់ព័ន្ធដោយប្រើទម្រង់ដូចមានក្នុងឧបសម្ព័ន្ធទី៤ នៃប្រកាសលេខ៤២ដ នស.បក

-គ្រប់ផែនទីទាំងអស់ដែលបានគូរនៅថ្នាក់ភូមិ ឃុំ/សង្កាត់ និងស្រុក ខណ្ឌ

-រាល់ឯកសារព័ត៌មាននិងភស្តុតាងស្ដីពីការអះអាងទាំងឡាយដែលប្រមូលបាន

-រាល់ព័ត៌មានឯកសារនិងភស្តុតាងទាំងឡាយដែលអាចកំណត់បានថា ជាដីសាធារណៈរបស់រដ្ឋឬដីឯកជនរបស់រដ្ឋ

-បញ្ជីវត្តមានដែលមានចុះហត្ថលេខារបស់អ្នកចូលរួមក្នុងរាល់កិច្ចប្រជុំរបស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌដោយប្រើទម្រង់ដូចមានក្នុងឧបសម្ព័ន្ធទី៨ នៃប្រកាសលេខ៤២ ដនស.បក

-ឯកសារបង្ហាញពីការមិនឯកភាពគ្នាដោយមានមូលហេតុជាក់លាក់ ហើយត្រូវចុះហត្ថលេខាដោយសមាជិកពាក់ព័ន្ធនៃក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ឬតំណាងក្រសួង ស្ថាប័ន អង្គភាពរដ្ឋ អាជ្ញាធរផ្សេងៗ ទៀតដែលបានអះអាងឬប្រកាសដីរដ្ឋដោយប្រើទម្រង់ដូចមានក្នុងឧបសម្ព័ន្ធទី៥ នៃប្រកាសលេខ៤២ ដនស.បក

-សេចក្ដីសង្ខេបមតិយោបល់សាធារណៈដោយប្រើទម្រង់ដូចមានក្នុងឧបសម្ព័ន្ធទី៦ នៃប្រកាសលេខ៤២ ដនស.បកនិងព័ត៌មានពាក់ព័ន្ធផ្សេងៗ ទៀតប្រសិនបើមាន។

របាយការណ៍របស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុកខណ្ឌ ត្រូវមានសេចក្ដីបញ្ជាក់ចំពោះក្បាលដីនីមួយៗ ថា មានតំណាងក្រសួង ស្ថាប័ន អង្គភាពរដ្ឋ អាជ្ញាធរណាខ្លះដែលឯកភាពលើអាណត្តិកាន់កាប់ដីនោះ និង/ឬ លើចំណាត់ថ្នាក់ដីនោះ និងតំណាងណាខ្លះដែលមិនឯកភាព ហើយត្រូវចុះហត្ថលេខាដោយប្រធានក្រុមការងារនិងត្រូវចម្លងចែកជូនដល់រាល់សមាជិកនិងតំណាងក្រសួង ស្ថាប័ន អង្គភាពរដ្ឋ អាជ្ញាធរពាក់ព័ន្ធទាំងអស់ ដើម្បីពិនិត្យមើលក្នុងរយៈពេល៣ ថ្ងៃនៃថ្ងៃធ្វើការ មុននឹងបញ្ជូនរបាយការណ៍នេះទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត។

ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ត្រូវធ្វើការបិទផ្សាយជាសាធារណៈនូវសេចក្ដីសង្ខេបមតិយោបល់សាធារណៈ (ប្រការ២១ នៃប្រកាសលេខ៤២ ដនស.បកដដែល)។

### ខ-២- ការសម្របសម្រួលដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត

**-ការប្រជុំសម្របសម្រួល**

ក្នុងរយៈពេលយ៉ាងយូរ៣០ ថ្ងៃបន្ទាប់ពីទទួលបានរបាយការណ៍ពីក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវរៀបចំការប្រជុំ ដើម្បីពិនិត្យមើលរបាយការណ៍នោះ។ ក្នុងករណីមានការប្រកាសអះអាងស្របគ្នាឬមានការឯកភាពមតិគ្នានៅថ្នាក់ស្រុក ខណ្ឌលើក្បាលដីណាមួយ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត អាចទទួលយកតាមមតិនោះឬអាចត្រួតពិនិត្យឡើងវិញ មុននឹងបញ្ចូលព័ត៌មានអំពីក្បាលដីនោះនិងផែនទីដីរដ្ឋ។ ផ្ទុយទៅវិញ ប្រសិនបើមានការអះអាងមិនស្របគ្នាលើក្បាលដីណាមួយ ជាពិសេសជាមួយមតិរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានភូមិ ឃុំ/សង្កាត់ ត្រូវព្យាយាមស្វែងរកការឯកភាពមតិគ្នាលើករណីមិនស្របគ្នានោះ។ ប៉ុន្តែប្រសិនមានការឯកភាពគ្នាវិញ ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវចាត់ឱ្យមានមន្ត្រីម្នាក់ឬច្រើននាក់ដែលជាសមាជិកនៃគណៈកម្មាធិការ និង/ឬលេខាធិការដ្ឋាន ដើម្បីចុះទៅធ្វើការស៊ើបអង្កេតដល់ទីកន្លែងនិងធ្វើសម្ភាសន៍ជាមួយបុគ្គលពាក់ព័ន្ធ។ មន្ត្រីឬក្រុមមន្ត្រីស៊ើបអង្កេត ត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីការរកឃើញរបស់ខ្លួន ដើម្បីដាក់ជូនគណៈកម្មាធិការពិនិត្យពិចារណា ( ប្រការ២២ នៃប្រកាសលេ៤២ ជនស.បកដដែល)។

**-រយៈពេលស៊ើបអង្កេត**

ជាទូទៅ មន្ត្រីឬក្រុមមន្ត្រីស៊ើបអង្កេត ត្រូវបញ្ចប់ការស្រាវជ្រាវស៊ើបអង្កេតនិងធ្វើរបាយការណ៍ជូនប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្តក្នុងរយៈពេល៣០ ថ្ងៃ គិតពីថ្ងៃចាត់តាំង។ ក្នុងករណីស្មុគស្មាញ ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត អាចអនុញ្ញាតឱ្យមន្ត្រីឬក្រុមមន្ត្រីស៊ើបអង្កេតបន្តរយៈពេលស៊ើបអង្កេតរហូតដល់៣០ ថ្ងៃបន្ថែមទៀតសម្រាប់ក្បាលដីដែលមានបញ្ហានីមួយៗ ( ប្រការ២៣ នៃប្រកាសលេខ៤២ជនស.បកដដែល)។

**-ការបញ្ចប់ការគូរប្លង់ផែនទី**

ក្នុងរយៈពេលមិនលើសពី១៥ ថ្ងៃ បន្ទាប់ពីទទួលបានរបាយការណ៍ស៊ើបអង្កេត ប្រធានគណៈកម្មាធិការគ្រប់-គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវកោះប្រជុំគណៈកម្មាធិការនេះ ដើម្បីស្វែងរកការឯកភាពមតិគ្នារវាងសមាជិកទាំងអស់នៃគណៈកម្មាធិការ។ ផ្ទុយទៅវិញ ក្នុងករណីមិនមានការឯកភាពមតិគ្នាទេ ត្រូវធ្វើឯកសារដោយប្រើទម្រង់ដូចមានក្នុងឧសម្ព័ន្ធទី៥ នៃប្រកាសលេខ៤២ ជនស.បក។ នៅដំណាក់ការនេះ ការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ (ដែននេសាទ) នៅក្នុងឃុំ/សង្កាត់នោះត្រូវបានសន្មតថា បានបញ្ចប់ការងាររបស់ខ្លួនហើយ (ប្រការ២៤ នៃប្រកាសលេខ៤២ ជនស.បកដដែល)។

### គ- ការបញ្ចូលលទ្ធផលក្នុងប្រព័ន្ធទិន្នន័យ តាមដាន និងរាយការណ៍

### គ-១- ការបញ្ចូលលទ្ធផលក្នុងប្រព័ន្ធទិន្នន័យ

លេខាធិការដ្ឋាន ត្រូវបញ្ចូលលទ្ធផលទៅក្នុងប្រព័ន្ធទិន្នន័យនិងផែនទីដីរដ្ឋថ្នាក់រាជធានី ខេត្តដែលត្រូវបង្កើតឡើង ដើម្បីថែរក្សានិងធ្វើចរន្តការស្របតាមខ្លឹមសារនៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋ។

លេខាធិការដ្ឋាន ត្រូវរៀបចំចម្លងព័ត៌មានទិន្នន័យដីរដ្ឋនិងផែនទីដីរដ្ឋ ដើម្បីផ្តល់ជូនក្រសួង ស្ថាប័ន អង្គភាពរដ្ឋអាជ្ញាធរនៅថ្នាក់រាជធានី ខេត្ត ក្រុង/ ស្រុក/ខណ្ឌ ឃុំ/សង្កាត់ និងសាធារណជនដូចមានចែងក្នុងប្រការ៣៦ និងប្រការ៣៨ នៃប្រកាសលេខ៤២ ដនស.បកដដែលនិងបទប្បញ្ញត្តិទាក់ទងនឹងការបង្កើត ការថែរក្សា និងការធ្វើចរន្តការប្រព័ន្ធទិន្នន័យនិងផែនទីដីរដ្ឋសម្រាប់សម្រួលដល់ការចូលរួមតាមដានការប្រើប្រាស់ ឬការគ្រប់គ្រងដីរដ្ឋនៅក្នុងមូលដ្ឋាន (ប្រការ២៥ នៃប្រកាសលេខ៤២ ដនស.បកដដែល)។

### គ-២- ការងារតាមដាននិងរាយការណ៍

ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ មានភារកិច្ចតាមដាននិងរាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្តរៀងរាល់៦ ខែម្តង (ក្នុងករណីចាំបាច់ ត្រូវរាយការបន្ទាន់) អំពីការវិវត្តប្រែប្រួលលើលក្ខណៈស្ថានភាពនិងការប្រើប្រាស់ដីរដ្ឋទាំងឡាយក្នុងស្រុក ខណ្ឌដែលត្រូវធ្វើអត្តសញ្ញាណកម្មនិងផែនទី ព្រមទាំងរាយការណ៍និងផ្តល់ព័ត៌មានច្បាស់លាស់អំពីការរកឃើញដីរដ្ឋថ្មីៗ ទៀតដែលមាននៅក្នុងស្រុក ខណ្ឌ ប្រសិនបើមាន។

ក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងអាជ្ញាធរ មានភារកិច្ចសហការណ៍ផ្តល់ព័ត៌មានអំពីការប្រើប្រាស់ដីរដ្ឋក្នុងស្រុក ខណ្ឌដែលឋិតនៅក្រោមអាណត្តិកាន់កាប់របស់ខ្លួនដល់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ តាមការស្នើសុំរបស់ប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ស្របតាមមាត្រា៦ នៃអនុក្រឹត្រលេខ១១៨ អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋ (ប្រការ២៦ នៃប្រកាសលេខ៤២ ដនស.បកដដែល)។

### ៣- ការធ្វើចំណាត់ថ្នាក់ដែនសេទនិងឯកសារ

### ក- នីតិវិធីធ្វើចំណាត់ថ្នាក់ដែនសេទ

នីតិវិធីនៃការធ្វើចំណាត់ថ្នាក់ដែនសេទ ផ្អែកតាមបញ្ញត្តិនៃប្រកាសលេខ៤២ ដនស.បក ចុះថ្ងៃទី១០ខែមីនាឆ្នាំ២០០៦ បានតម្រូវឱ្យអនុវត្តតាមជំហានដូចខាងក្រោមៈ

**-ពេលទទួលបានសំណើឱ្យលើកអនុសាសន៍**

នៅពេលទទួលបានសំណើជាលាយលក្ខណ៍អក្សរស្តីពីការស្នើសុំធ្វើចំណាត់ថ្នាក់ដីរដ្ឋណាមួយពីក្រុមការងារចុះបញ្ជីដីរដ្ឋឬពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬពីរាជរដ្ឋាភិបាលសម្រាប់គោលបំណងនៃការចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវកោះប្រជុំសមាជិកទាំងអស់ នៃគណៈកម្មាធិការនេះ ដើម្បីពិភាក្សាសម្រេចលើអនុសាសន៍អំពីចំណាត់ថ្នាក់ នៃដីនោះ ដើម្បីជូនទៅក្រសួង

រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្របតាមប្រការ៣០ ប្រការ៣១ និងប្រការ៣២ នៃប្រកាសលេខ៤២ ដនស.បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៦ (ប្រការ២៩ នៃប្រកាសលេខ៤២ ដនស.បកដដែល)។

**-ករណីធ្វើអត្តសញ្ញាណកម្មដែននេសាទនិងផែនទី**

ករណីដែលបានធ្វើអត្តសញ្ញាណកម្មដែននេសាទនិងផែនទីរួច ប៉ុន្តែមិនទាន់មានការឯកភាពមតិគ្នាអំពីចំណាត់ថ្នាក់ក្បាលដី គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្តត្រូវធ្វើការៈ

-ពិនិត្យពិចារណាលើរបាយការណ៍របស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌនិងមតិយោបល់សាធារណៈទាំងឡាយដែលបានសង្ខេបបញ្ចូលជាផ្នែកមួយ នៃរបាយការណ៍

-កំណត់បទប្បញ្ញត្តិជាក់លាក់ នៃច្បាប់ភូមិបាលនិង/ឬ នៃច្បាប់ផ្សេងៗ ទៀតដែលត្រូវយកមកអនុវត្តក្នុងការធ្វើចំណាត់ថ្នាក់ដីរដ្ឋនោះ

-បញ្ចប់ការពិនិត្យពិចារណាក្នុងរយៈពេល៤៥ ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលសំណើ

-លើកអនុសាសន៍ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី បើមានការឯកភាពមតិគ្នាលើចំណាត់ថ្នាក់ដីនោះ

-ធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដើម្បីពិនិត្យពិចារណាបន្ត បើមិនមានការឯកភាពមតិគ្នាលើចំណាត់ថ្នាក់ដីនោះ (ប្រការ៣០ នៃប្រកាសលេខ៤២ ដនស.បក ដដែល)។

**-ករណីមិនទាន់ធ្វើអត្តសញ្ញាណកម្មដែននេសាទនិងផែនទី**

ក្នុងករណីដែលមិនទាន់បានធ្វើអត្តសញ្ញាណកម្មដែននេសាទនិងផែនទីទេ ចំណាត់ការត្រូវអនុវត្តដូចតទៅៈ

ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវចាត់តាំងឱ្យមានក្រុមស៊ើបអង្កេតលើការអះអាងដែលមិនស្របគ្នា (ប្រសិនបើមាន)របស់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋ ឬអាជ្ញាធរ និងរៀបចំដំណើរការផ្តល់ឱកាសឱ្យសាធារណជនចូលរួមមតិលើការធ្វើចំណាត់ការលើដីនោះ។

ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវផ្តល់លិខិតជូនដំណឹងអំពីការធ្វើចំណាត់ថ្នាក់ដីរដ្ឋលើក្បាលដីជាក់លាក់ទៅឱ្យមេភូមិនិងមេឃុំ/ចៅសង្កាត់ តាមរយៈប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ដើម្បីបិទផ្សាយរយៈពេល១៥ថ្ងៃជូនប្រជាពលរដ្ឋនៅទីតាំងក្បាលដីនោះនៅសាលាឃុំ/សង្កាត់ និងនៅមុខផ្ទះរបស់មេភូមិ។ ក្នុងករណីដែលក្នុងភូមិ ឃុំ/សង្កាត់ មានជនជាតិដើមភាគតិចរស់នៅ ត្រូវបកប្រែលិខិតជូនដំណឹងជាភាសាជនជាតិនោះ និងពន្យល់ខ្លឹមសារ នៃលិខិតជូនដំណឹងដល់អាជ្ញាធរប្រពៃណីរបស់ក្រុមជនជាតិដើមភាគតិចនីមួយៗ។

ដោយអនុវត្តតាមការចែងក្នុងវាក្យខណ្ឌទី៣ និងទី៤ ប្រការ១៧ នៃប្រកាសលេខ៤២ ដនស.បកដដែលបានកំណត់រយៈពេលសម្រាប់បិទផ្សាយជាសាធារណៈ ប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ត្រូវចាត់ឱ្យមានអ្នកចាំទទួលឬកត់ត្រានូវមតិយោបល់សាធារណៈទាំងអស់ ទោះបីជាធ្វើដោយផ្ទាល់មាត់ក្តីឬជាលាយលក្ខណ៍អក្សរក្តី ត្រូវធ្វើ

សេចក្តីសង្ខេបមតិយោបល់សាធារណៈដែលបានទទួលនោះដោយប្រើទម្រង់ដូចក្នុងឧបសម្ព័ន្ធទី៦ នៃប្រកាសលេខ ៤២ ដនស.បកដដែល ដើម្បីប្រគល់ឱ្យក្រុមស៊ើបអង្កេត។

ប្រសិនបើមានការផ្តល់មតិយោបល់ជាលាយលក្ខណ៍អក្សរដោយអង្គការសង្គមស៊ីវិលឬអង្គការក្រៅរដ្ឋាភិបាល ដែលមានភ្នាក់ងារប្រចាំមូលដ្ឋានភូមិ ឃុំ/សង្កាត់ អ្នកចាំទទួលឬកត់ត្រាមតិសាធារណៈត្រូវទទួលយកមតិនោះផ្តល់ជូនក្រុមស៊ើបអង្កេត ដើម្បីដាក់ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្តពិចារណា។

ក្រុមស៊ើបអង្កេត ត្រូវអង្កេតលើស្ថានភាពប្រើប្រាស់ដីបច្ចុប្បន្ននិងពិនិត្យពិចារណាលើមតិយោបល់របស់ប្រជាពលរដ្ឋ និងមតិរបស់អាជ្ញាធរដែនដីក្នុងមូលដ្ឋាន។

ក្រុមស៊ើបអង្កេត ត្រូវបញ្ចប់ការស៊ើបអង្កេតរបស់ខ្លួននិងធ្វើរបាយការណ៍ដែលមានបញ្ចូលទាំងសេចក្តីសង្ខេបមតិរបស់ប្រជាពលរដ្ឋ និងមតិរបស់អាជ្ញាធរដែនដីជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ក្នុងរយៈពេលមិនលើសពី៤៥ ថ្ងៃគិតចាប់ពីថ្ងៃចាត់តាំង។

បន្ទាប់ពីបានទទួលរបាយការណ៍ស៊ើបអង្កេត គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវពិនិត្យពិចារណាលើរបាយការណ៍និងមតិយោបល់ទាំងឡាយ ព្រមទាំងកំណត់បទប្បញ្ញត្តិជាក់លាក់ដែលមានចែងក្នុងច្បាប់ភូមិបាលនិង/ឬច្បាប់ផ្សេងៗ ទៀតដែលត្រូវយកមកអនុវត្តក្នុងការធ្វើចំណាត់ថ្នាក់ដីរដ្ឋនោះ។

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវបញ្ចប់ការពិនិត្យពិចារណាខាងលើនេះ ក្នុងរយៈពេលមិនលើស៤៥ ថ្ងៃគិតពីថ្ងៃបានទទួលរបាយការណ៍ស៊ើបអង្កេតនោះ។

មុននឹងបញ្ជូនអនុសាសន៍ទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្តត្រូវបញ្ជូនខ្លឹមសារនៃអនុសាសន៍របស់ខ្លួនទៅឱ្យប្រធានក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ដើម្បីបិទផ្សាយជាសាធារណៈនៅទីតាំងក្បាលដីនៅសាលាឃុំ/សង្កាត់និងនៅមុខផ្ទះមេភូមិដោយមានសេចក្តីបញ្ជាក់ជាខ្លឹមសារអនុសាសន៍នេះមិនមែនជាសេចក្តីសម្រេចផ្លូវការ និងមិនទាន់អាចយកទៅអនុវត្តបានឡើយ (ប្រការ៣១ នៃប្រកាសលេខ៤២ ដនស.បក ដដែល)។

**-ការពិចារណានិងរបាយការណ៍**

ក្នុងការពិនិត្យពិចារណាលើរបាយការណ៍របស់ក្រុមស៊ើបអង្កេត គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវខិតខំស្វែងរកការឯកភាពមតិគ្នាក្នុងចំណោមសមាជិកទាំងអស់លើចំណាត់ថ្នាក់ដីនោះដោយអនុលោមតាមច្បាប់ភូមិបាល ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ ទៀតដែលពាក់ព័ន្ធ។

ក្រោយពីបានពិចារណាសម្រេចៈ

-ប្រសិនបើគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត អាចសម្រេចបានការឯកភាពមតិគ្នាលើការធ្វើចំណាត់ថ្នាក់ដីនោះ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវលើកអនុសាសន៍ជាលាយលក្ខណ៍អក្សរជូន

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្នុងរយៈពេល៤៥ ថ្ងៃ

-ប្រសិនបើគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្តមិនអាចសម្រេចបានការឯកភាពមតិគ្នាអំពីចំណាត់ថ្នាក់នៃដីនោះទេ ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដើម្បីពិចារណាបន្តនិងត្រូវជូនដំណឹងដល់អ្នកដែលស្នើសុំអនុសាសន៍ផងដែរ។

របាយការណ៍របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវមានបញ្ជាក់អំពីសមាជិកដែលឯកភាព ឬមិនឯកភាពលើចំណាត់ថ្នាក់ដីនោះ ហើយត្រូវចុះហត្ថលេខាដោយប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត និងត្រូវចែកជូនដល់សមាជិកទាំងអស់យ៉ាងតិច៣ ថ្ងៃធ្វើការ ដើម្បីពិនិត្យមុននឹងបញ្ជូនមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឬក្រុមប្រឹក្សាគោលនយោបាយដីធ្លី។ សមាជិកនៃគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្តដែលមិនឯកភាព ត្រូវផ្តល់ជូនប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្តនូវមតិសង្ខេបរបស់ខ្លួនដែលទាក់ទងនឹងក្បាលដីជាក់លាក់នោះដោយប្រើទម្រង់ដូចក្នុងឧបសម្ព័ន្ធទី៥ នៃប្រកាសលេខ៤២ ដនស.បកដដែល សម្រាប់ភ្ជាប់ជាមួយរបាយការណ៍ (ប្រការ៣២ នៃប្រកាសលេខ៤២ ដនស.បកដដែល)។

**-ការពិនិត្យអនុសាសន៍ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

ប្រសិនបើក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់យល់ព្រមតាមអនុសាសន៍របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចុះបញ្ជីចំណាត់ថ្នាក់ដីក្នុងសៀវភៅគោលបញ្ជីដីធ្លីស្របតាមអនុសាសន៍នោះ។ ប្រសិនបើក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មិនយល់ស្របតាមអនុសាសន៍នោះទេ ដោយឈរលើមូលដ្ឋានអង្គហេតុឬអង្គច្បាប់ច្បាស់លាស់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបញ្ជូនករណីនេះទៅក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដើម្បីបន្តស្វែងរកការឯកភាពមតិគ្នាមួយកម្រិតទៀត (ប្រការ៣៣ នៃប្រកាសលេខ៤២ ដនស.បកដដែល)។

**-ការពិនិត្យដោយក្រុមប្រឹក្សាគោលនយោបាយដីធ្លី**

ក្នុងករណីទទួលបានការឯកសារស្តីពីការធ្វើចំណាត់ថ្នាក់ដីរដ្ឋៈ

-ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវធ្វើការប្រជុំ ដើម្បីពិនិត្យពិចារណានិងសម្រេចលើសំណើសុំធ្វើចំណាត់ថ្នាក់ដីរដ្ឋ និងរបាយការណ៍ពាក់ព័ន្ធក្នុងរយៈពេលមិនលើសពី៦០ ថ្ងៃបន្ទាប់ពីបានទទួលរបាយការណ៍

-ប្រសិនបើក្រុមប្រឹក្សាគោលនយោបាយដីធ្លី អាចសម្រេចបានការឯកភាពមតិគ្នាក្នុងចំណោមសមាជិកក្រុម-ប្រឹក្សាអំពីចំណាត់ថ្នាក់នៃដីនោះថា ជាដីសាធារណៈរបស់រដ្ឋឬជាដីឯកជនរបស់រដ្ឋផ្អែកលើមូលដ្ឋានច្បាប់ភូមិបាលព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ទៀតដែលពាក់ព័ន្ធ។ ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវផ្តល់អនុសាសន៍ជាលាយលក្ខណ៍អក្សរជូនទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីធ្វើការចុះបញ្ជីដីរដ្ឋនោះ ស្របតាមអនុសាសន៍

-ប្រសិនបើក្រុមប្រឹក្សាគោលនយោបាយដីធ្លី មិនអាចសម្រេចបានការឯកភាពមតិគ្នាអំពីឋានៈនិងចំណាត់ថ្នាក់នៃដីនោះទេ ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវបញ្ជូនសំណុំឯកសារនៃករណីនេះទៅគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យសម្រេចលើការធ្វើចំណាត់ថ្នាក់ដីនោះនិងជូនដំណឹងដល់អ្នកស្នើសុំអនុសាសន៍ (ប្រការ៣៤ នៃប្រកាសលេខ ៤២ ដនស.បកដដែល)។

**-ការសម្រេចរបស់គណៈរដ្ឋមន្ត្រី**

ក្រោយពេលបានទទួលឯកសារនៃសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រីអំពីចំណាត់ថ្នាក់នៃដីឬដែននេសាទនោះថា ជាដីសាធារណៈរបស់រដ្ឋឬជាដីឯកជនរបស់រដ្ឋ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចុះបញ្ជីចំណាត់ថ្នាក់ដីនោះនៅក្នុងសៀវភៅគោលបញ្ជីដីធ្លីស្របតាមការសម្រេចរបស់គណៈរដ្ឋមន្ត្រី (ប្រការ៣៥ នៃប្រកាសលេខ ៤២ដនស.បកដដែល)។

**ខ- អំពីឯកសារ**

**-ការរក្សាទុកឯកសារ**

ឯកសារព័ត៌មាននិងផែនទីដី (ដែននេសាទ) របាយការណ៍របស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ របាយការណ៍ស៊ើបអង្កេតរបស់មន្ត្រីឬមន្ត្រីស៊ើបអង្កេត និងអនុសាសន៍របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្តនិងរាល់ព័ត៌មានដែលទាក់ទងនឹងដីរដ្ឋទាំងអស់ ត្រូវបានចាត់ទុកជាឯកសារសាធារណៈនិងត្រូវរក្សាទុកនៅលេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត (ប្រការ៣៦ នៃប្រកាសលេខ៤២ នៃដនស.បកដដែល)។

**-ការផ្តល់ឯកសារថតចម្លងដោយឥតគិតថ្លៃ**

ក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងអាជ្ញាធរថ្នាក់ស្រុក/ខណ្ឌ ឃុំ/សង្កាត់ ត្រូវទទួលបានយ៉ាងហោចណាស់នូវផែនទីដីរដ្ឋប្រចាំមូលដ្ឋានមួយច្បាប់ដោយឥតគិតថ្លៃ (ប្រសិនបើមាន)ដែលជាលទ្ធផលសម្រេចនៃការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋឬដែលបានធ្វើបច្ចុប្បន្នភាពនៅថ្នាក់រាជធានី ខេត្តរៀងរាល់៦ ខែម្តង និងសេចក្តីសង្ខេបព័ត៌មានអំពីក្បាលដីរដ្ឋនីមួយៗ ដែលបង្ហាញឱ្យដឹងអំពីចំណាត់ថ្នាក់ដី បន្ទុកលើដី និងអាជ្ញាធរកាន់កាប់ដីរដ្ឋនោះ ដើម្បីរក្សាទុកនៅការិយាល័យជាឯកសារសាធារណៈ (ប្រការ៣៧ នៃប្រកាសលេខ៤២ ដនស.បកដដែល)។

**-ការផ្តល់ឯកសារថតចម្លងតាមការស្នើសុំដោយឥតគិតថ្លៃ**

សាធារណជនឬស្ថាប័នរដ្ឋនានាដែលមានបំណងចង់បានឯកសារថតចម្លងអំពីព័ត៌មានដីរដ្ឋនិង/ឬផែនទីដីរដ្ឋ អាចចុះឈ្មោះស្នើសុំចម្លងឯកសារជាក់លាក់បាននៅសាលាស្រុក/ខណ្ឌ ឬនៅលេខាធិការដ្ឋាន នៃគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ស្រុក ខណ្ឌដោយត្រូវបង់ថ្លៃសេវាជាមុនដែលជាថ្លៃថតចម្លងឬថ្លៃបោះពុម្ពឯកសារនិងថ្លៃសេវាបញ្ជូនឯកសារតាមតម្លៃជាក់ស្តែង (ប្រការ៣៨ នៃប្រកាសលេខ៤២ ដនស.បកដដែល)។

**-រយៈពេលទទួលឯកសារថតចម្លងតាមការស្នើសុំ**

ដោយពិគ្រោះយោបល់ជាមួយនឹងអ្នកផលិតឯកសារ អភិបាល នៃគណៈអភិបាលស្រុក ខណ្ឌ ត្រូវកំណត់និងត្រួតពិនិត្យជាប្រចាំអំពីរយៈពេល ដើម្បីទទួលបានឯកសារនោះ ប៉ុន្តែយ៉ាងណាក៏ដោយក៏រយៈពេលនេះមិនអាចលើស ២០ ថ្ងៃឡើយ គិតចាប់ពីថ្ងៃបានទទួលប្រាក់ថ្លៃសេវា (ប្រការ៣៩ នៃប្រកាសលេខ៤២ ដនស.បកដដែល)។

## សន្និដ្ឋាន

ការកំណត់ព្រំប្រទល់ដែននេសាទឬការធ្វើអត្តសញ្ញាណកម្មដែននេសាទ និងផែនទី គឺជាដំណើរការសកម្មភាពមួយដែលមានលក្ខណៈលម្អិត សម្របសម្រួល និងតម្លាភាព ហើយត្រូវធ្វើឡើងដោយមានកិច្ចសហការរួមរវាងក្រសួង ស្ថាប័ន អាជ្ញាធរដែនដី និងប្រជាពលរដ្ឋក្នុងមូលដ្ឋានពាក់ព័ន្ធ ព្រមទាំងអនុវត្តដោយក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ហើយដែលក្រុមនេះត្រូវបានដឹកនាំដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត។ តាមនីតិវិធី ជំហានដំបូងគឺអនុញ្ញាតឱ្យក្រុមការងារដីរដ្ឋថ្នាក់ស្រុកខណ្ឌ ចាត់តាំងក្រុមការងារវាលមួយដែលមានសមាជិកយ៉ាងតិចចំនួន៣ នាក់ក្នុងចំណោមសមាជិករបស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ហើយក្រុមការងារវាលនេះក៏ត្រូវមានសមាសភាពមេឃុំឬចៅសង្កាត់ពាក់ព័ន្ធចូលរួមផងដែរ។ ចំពោះលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការធ្វើអត្តសញ្ញាណកម្មនិងផែនទីដីរដ្ឋដែលកំពុងស្ថិតនៅជាធរមាននាបច្ចុប្បន្នយើងសង្កេតឃើញថា ពុំមានសមាសភាពអង្គភាពរដ្ឋបាលជលផលនៅក្នុងក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្តឡើយ ជាពិសេសនៅក្នុងក្រុមការងារវាល។ ដូចនេះ ដើម្បីធ្វើអត្តសញ្ញាណកម្មកំណត់ព្រំប្រទល់ដែននេសាទ និងធ្វើផែនទីបាន លុះត្រាធ្វើវិសោធនកម្មលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធបញ្ចូលសមាសភាពអង្គភាពរដ្ឋបាលជលផលទៅក្នុងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានីខេត្ត ក្រុមការងារដីរដ្ឋថ្នាក់ស្រុកខណ្ឌ និងក្នុងក្រុមការងារវាល។ ចំណែក ឯតួនាទីភារកិច្ចរបស់មន្ត្រីរដ្ឋបាលជលផលដែលត្រូវបញ្ចូលក្នុងក្រុមទាំង៣ ខាងលើ ត្រូវផ្តល់ឯកសារឬភស្តុតាងគតិយុត្តពាក់ព័ន្ធនានាដែលទាក់ទងទៅនឹងដែននេសាទ ដើម្បីបញ្ជាក់ថា ដីនេះពិតជាដែននេសាទដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋប្រាកដមែន។

បញ្ហានេះ មាត្រា៦ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋឆ្នាំ២០០៥ បានបញ្ញត្តិថាៈ"

*គ.តំណាងរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ មានភារកិច្ចផ្តល់ព័ត៌មាននិងឯកសារទាក់ទងនឹងដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋទាំងអស់ដែលឋិតនៅក្រោមអាណត្តិកាន់កាប់របស់ក្រសួង ស្ថាប័ននោះ។ អាជ្ញាធរដែនដី មានភារកិច្ចផ្តល់ព័ត៌មានទាក់ទងនឹងដីសាធារណៈរបស់រដ្ឋនិងដីឯកជនរបស់រដ្ឋទាំងអស់ដែលឋិតនៅក្នុងដែនដីរបស់ខ្លួន ទោះបីដីនោះឋិតឬមិនឋិតនៅក្រោមអាណត្តិកាន់កាប់របស់ខ្លួនក៏ដោយ។*

*ឃ.តំណាងរបស់ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីណាមួយដែលអះអាងអំពីអាណត្តិកាន់កាប់លើក្បាលដីណាមួយជាក់លាក់របស់រដ្ឋឬអះអាងថា ជាដីសាធារណៈរបស់រដ្ឋ ត្រូវផ្តល់ព័ត៌មាននិងឯកសារគាំទ្រ។ "*

ចំពោះ ឯកសារគតិយុត្តពាក់ព័ន្ធនឹងការធ្វើអត្តសញ្ញាណកម្មកំណត់ព្រំប្រទល់ដែននេសាទនិងដែនទីកំពុងស្ថិតនៅជាធរមាននាបច្ចុប្បន្នរួមមានៈ

- ច្បាប់ស្តីពីជលផល
- ផែនទីឡូត៍នេសាទ
- ផែនទីភ្ជាប់ឧបសម្ព័ន្ធអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ ស្តីពីការកំណត់នាទីព្រៃលិចទឹកចំនួន៦៤៧.៤០៦ ហិកតា ស្ថិតនៅក្នុងខេត្តទាំង៦ ជុំវិញបឹងទន្លេសាប (ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ)
- ផែនទីភ្ជាប់ឧបសម្ព័ន្ធអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ ស្តីពីការលុបឡូត៍-នេសាទជុំវិញបឹងទន្លេសាបក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប ពោធិ៍សាត់ កំពង់ឆ្នាំង និងខេត្តកំពង់ធំ ទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារនិងជាកន្លែងអភិរក្សជលផល
- ផែនទីភ្ជាប់ឧបសម្ព័ន្ធអនុក្រឹត្យលេខ៥៣ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១២ ស្តីពីការបង្កើតកន្លែងអភិរក្សជលផលក្នុងខេត្តកណ្តាល កំពង់ចាម ព្រៃវែង និងខេត្តតាកែវ
- ផែនទីសហគមន៍នេសាទ(មាត្រា៣ នៃអនុក្រឹត្យលេខ២៥ អនក្រ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ
- ប្រកាសលេខ០០៤ ប្រក.កសក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០០ ស្តីពីការកំណត់នាទីព្រៃលិចទឹកក្នុងខេត្តតាកែវ និង
- សារាចរណែនាំលេខ០២ សរណន ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៣ ស្តីពីការផ្តល់បណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋដែលបានកាន់កាប់ និងប្រើប្រាស់ជាក់ស្តែងនៅតំបន់វាលទំនាបដែលលិចទឹកក្នុងរដូវជំនោរឡើងនៃដែនដីដែលទទួលរបបទឹកទន្លេមេគង្គ។

ចំពោះតំបន់គ្រប់គ្រងជលផលដែលជា <u>ទំនាបលិចទឹកក្នុងរដូវជំនោរឡើង</u> និង<u>នាទីព្រៃកោងកាង</u> គឺនៅពុំទាន់មានការកំណត់ផែនទីច្បាស់លាស់នៅឡើយ។ ដូចនេះ តម្រូវឱ្យមន្ត្រីរដ្ឋបាលជលផលមានភារកិច្ចត្រូវស្វែងរកសាក្សីដឹងឮបន្ថែមទៀតមានជាអាទិ៍ មន្ត្រីរាជការចូលនិវត្តន៍ អតីតអាជីវករឡូត៍នេសាទ អ្នកនេសាទ អ្នកចាស់ទុំឬព្រឹទ្ធាចារ្យ និងប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋាន ដើម្បីផ្តល់ព័ត៌មាន ហើយឈានទៅកំណត់ធ្វើផែនទីតំបន់គ្រប់គ្រងជលផលទាំងនោះ។ ជាមួយគ្នាផងដែរ មាត្រា៨ នៃនីតិជលផលឆ្នាំ២០០៦ បានកំណត់អត្តសញ្ញាណដែននេសាទថាៈ"

*ដែននេសាទរួមមាន ដែនដីលិចទឹកអចិន្ត្រៃយ៍ ដែនដីដែលទទួលរបបទឹកទន្លេមេគង្គនិងដែនដីដែលទទួលរបបទឹកជោរនាចនៃសមុទ្រដែលមានតួនាទីសំខាន់បម្រើឱ្យការនេសាទគ្រប់ប្រភេទនិងការការពារប្រព័ន្ធអេកូឡូស៊ីជលផល។*

*ដែនដីលិចទឹកអចិន្ត្រៃយ៍មានជាអាទិ៍ សមុទ្រ ទន្លេ ដៃទន្លេ បឹង ព្រែក ស្ទឹង អូរ អាងទឹក និងប្រឡាយ។*

*ដែនដីដែលទទួលរបបទឹកទន្លេមេគង្គមានជាអាទិ៍ ត្រពាំង រណ្ដៅ វាលកក់ល្បាប់ វាលទំនាបដែលលិចទឹកក្នុងរដូវទឹកជំនន់ឡើងនិងនាទីព្រៃលិចទឹក។*

*ដែនដីដែលទទួលរបបទឹកជោរ នាចនៃសមុទ្រមានជាអាទិ៍ នាទីព្រៃកោងកាង។"*

ដូចនេះ ផ្អែកតាមសញ្ញាណមាត្រា៨ នៃនីតិជលផលឆ្នាំ២០០៦ និងបណ្ដាសាក្សីខាងលើ រដ្ឋបាលជលផលមានសមត្ថកិច្ចអាចកំណត់ផែនទីទំនាបលិចទឹកក្នុងរដូវជំនន់ឡើង និងនាទីព្រៃកោងកាង បាន។ ម្យ៉ាងទៀត បញ្ហានេះរាជរដ្ឋាភិបាលបានដាក់ចេញនូវសារាចរណែនាំលេខ០២ សរណនមួយ កាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣ ដើម្បីធ្វើការណែនាំដល់ការផ្ដល់បណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋដែលបានកាន់កាប់និងប្រើប្រាស់ជាក់ស្ដែងនៅតំបន់វាលទំនាបលិចទឹកក្នុងរដូវជំនន់ឡើងនៃដែនដីទទួលរបបទឹកទន្លេមេគង្គដែលមានខ្លឹមសារដូចខាងក្រោមៈ

*ក្នុងគោលដៅធានាសិទ្ធិលើដីធ្លីរបស់ប្រជាពលរដ្ឋរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ការជម្រុញផលិតកម្មកសិកម្ម និងការធានាសន្តិសុខស្បៀង រាជរដ្ឋាភិបាលធ្វើការណែនាំដល់ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់ផ្នែក គ្រប់ថ្នាក់ដូចតទៅៈ*

*១-ត្រូវចុះបញ្ជីនិងផ្ដល់បណ្ណកម្មសិទ្ធិលើដីធ្លីដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានជូនពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្ដែងនារដូវសម្រកនៅតំបន់វាលទំនាបដែលលិចទឹកក្នុងរដូវជំនន់ឡើងនៃដែនដីដែលទទួលរបបទឹកទន្លេមេគង្គ។ ប៉ុន្តែករណីនេះ មិនអនុវត្តចំពោះតំបន់ទំនាបនៅជុំវិញបឹងទន្លេសាបរហូតមកដល់ព្រំប្រទល់ខេត្តកណ្ដាល។*

*២-ប្រជាពលរដ្ឋក្នុងតំបន់វាលទំនាបលិចទឹកក្នុងរដូវជំនន់ឡើងដែលបានទទួលបណ្ណកម្មសិទ្ធិ ត្រូវប្រើប្រាស់ អាស្រ័យផល និងចាត់ចែងដីជាកម្មសិទ្ធិរបស់ខ្លួនឱ្យស្របតាមវិធានដីក្នុងទំហំដែលច្បាប់បានកម្រិត។*

បានសេចក្ដីថា តំបន់វាលទំនាបលិចទឹកក្នុងរដូវជំនន់ឡើងនៃដែនដីទទួលរបបទឹកទន្លេមេគង្គ ត្រូវបានរាជរដ្ឋាភិបាលសម្រេចប្រគល់ជូនប្រជាពលរដ្ឋដែលបានកាន់កាប់ជាក់ស្ដែងហើយ។ ដូចនេះ ការកំណត់ទំនាបលិចទឹកក្នុងរដូវជំនន់ឡើងតាមដងទន្លេមេគង្គ រដ្ឋបាលជលផលអាចធ្វើការរៀបចំផែនទីបាន បន្ទាប់ពីតំបន់វាលទំនាបនេះត្រូវបានបែងចែកជាកម្មសិទ្ធិជូនប្រជាពលរដ្ឋរួច។ ប៉ុន្តែវាលទំនាបលិចទឹកនៅជុំវិញបឹងទន្លេសាបសារាចរណែនាំដែលបានហាមឃាត់មិនឱ្យផ្ដល់ដីធ្លីនោះធ្វើជាកម្មសិទ្ធិទេ។

ផ្អែកតាមគោលការណ៍ណែនាំនៃប្រកាសលេខ ៤២ ដនស.បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៦ ស្ដីពីការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋបានកំណត់ថា ការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ត្រូវអនុវត្តដោយផ្ទាល់ដោយក្រុមការងារវាល ហើយសកម្មភាពនេះត្រូវចាប់ផ្ដើមនៅមូលដ្ឋានជាក់ស្ដែងក្នុងភូមិសាស្ត្ររាជធានី ខេត្តដោយអនុវត្តទៅតាមនីតិវិធីនិងជំហានដូចស្មេរនិពន្ធលើកឡើងក្នុងជំពូកទី២ នៃឯកសារនេះ។ ការធ្វើអត្តសញ្ញាណកម្ម(ដែននេសាទ) និងការធ្វើផែនទីដែលបានឯកភាពក្នុងក្រុមការងារវាលនិងក្រុមប្រឹក្សាឃុំ/សង្កាត់ពាក់ព័ន្ធរួចរាល់ ត្រូវដាក់ជូនក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌនិងគណៈកម្មាធិការគ្រប់

គ្រងដីរដ្ឋ ថ្នាក់រាជធានី ខេត្តពាក់ព័ន្ធ ដើម្បីពិនិត្យ។ ប្រសិនបើគ្មានការជំទាស់ទេ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្តពាក់ព័ន្ធ ត្រូវបញ្ជូនឯកសារនោះទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យនិងសម្រេច។ ករណីយល់ព្រមតាមឯកសាររបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ត្រូវចុះបញ្ជីចំណាត់ថ្នាក់ដីរដ្ឋ (ដែននេសាទ) និងផែនទីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី។ ផ្ទុយទៅវិញ ករណីមិនយល់ស្របតាមការសម្រេចរបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្តទេ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ត្រូវបញ្ជូនសំណុំឯកសារទាំងនោះ ទៅក្រុមប្រឹក្សាគោលនយោបាយដីធ្លីដើម្បីស្វែងរកការគាំទ្រ និងឯកភាព។ ចំពោះក្រុមប្រឹក្សាគោលនយោបាយដីធ្លី បន្ទាប់ពីទទួលបានឯកសាររួចហើយ ត្រូវធ្វើការកោះប្រជុំ ពិនិត្យពិចារណានិងសម្រេចលើសំណើនិងរបាយការណ៍ក្នុងរយៈពេលមិនឱ្យលើសពី៦០ ថ្ងៃបន្ទាប់ពីទទួលបានរបាយការណ៍នោះ។ ក្នុងករណីក្រុមប្រឹក្សាគោលនយោបាយដីធ្លីសម្រេចឯកភាពមតិគ្នាក្នុងចំណោមសមាជិកក្រុមប្រឹក្សាថាដីនោះ ពិតជាដែននេសាទដែលជាទ្រព្យសម្បត្តិរបស់រដ្ឋដោយផ្អែកលើមូលដ្ឋានច្បាប់និងលិខិតបទដ្ឋានគតិយុត្តប្រាកដមែន ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវផ្តល់អនុសាសន៍ជាលាយលក្ខណ៍អក្សរទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់វិញ ដើម្បីចុះក្នុងសៀវភៅគោលបញ្ជីដីធ្លី។ ផ្ទុយទៅវិញ ករណីក្រុមប្រឹក្សាគោលនយោបាយដីធ្លីមិនអាចសម្រេចតាមសំណើអំពីឋានៈនិងចំណាត់ថ្នាក់ដែននេសាទនោះទេ ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវបញ្ជូនសំណុំឯកសារនោះទៅគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យនិងសម្រេចលើសំណើ។ ចំណែកគណៈរដ្ឋមន្ត្រី ក្នុងករណីឯកភាព និងយល់ព្រមតាមសំណើ ត្រូវបញ្ជូនសំណើនេះទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់វិញ ដើម្បីចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីបញ្ចប់។

ប៉ុន្តែការធ្វើអត្តសញ្ញាណកម្មដីរដ្ឋឬដែននេសាទ និងផែនទី ផ្អែកតាមខ្លឹមសារនៃអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ឆ្នាំ២០០៨ គឺបានផ្តល់តួនាទី ភារកិច្ចជូនអង្គភាពរដ្ឋបាលជលផលក្នុងការសិក្សាវាយតម្លៃ ការធ្វើចំណាត់ថ្នាក់កំណត់ព្រំប្រទល់ដែននេសាទ និងការបង្កើតផែនទីដែននេសាទ។ រីឯនាយកដ្ឋានកិច្ចការជលផល ជាសមត្ថកិច្ចទទួលបន្ទុកអនុវត្តផ្ទាល់។ ជាក់ស្តែង មាត្រា១៤ នៃអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ឆ្នាំ២០០៨ បានបញ្ញត្តិថា:"*រដ្ឋបាលជលផលមានតួនាទីភារកិច្ចធ្វើជាសេនាឱ្យក្រសួងលើការងារដូចតទៅ៖*

*-សិក្សាវាយតម្លៃ ធ្វើចំណាត់ថ្នាក់ កំណត់ព្រំប្រទល់ដែននេសាទ បង្កើតផែនទីដែននេសាទ*។ " ចំណែកមាត្រា១៩ នៃអនុក្រឹត្យដដែលបានបញ្ញត្តិទៀតថា:"*នាយកដ្ឋានកិច្ចការជលផលមានភារកិច្ចដូចខាងក្រោម៖*

*-សិក្សាកសាងផែនទីនិងកំណត់ព្រំប្រទល់ដែននេសាទ*។" ដូចនេះ ការរៀបចំធ្វើអត្តសញ្ញាណកម្មដែននេសាទ និងផែនទី គឺជាភារកិច្ចរបស់អង្គភាពរដ្ឋបាលជលផល។ ដូច្នេះ រដ្ឋបាលជលផលត្រូវលើកគម្រោងស្នើសុំថវិកាជាតិឬថវិកាឧបត្ថម្ភពីបណ្តាអង្គការមិនមែនរដ្ឋាភិបាល ដើម្បីចំណាយលើការងារនោះ។ ចំពោះការកំណត់ព្រំប្រទល់ដែន-នេសាទ នីតិជលផលឆ្នាំ២០០៦ បានកំណត់ថា ត្រូវកំណត់ដោយអនុក្រឹត្យ។ ជាក់ស្តែង មាត្រា៦ នៃនីតិជលផលឆ្នាំ២០០៦ បានបញ្ញត្តិថា:"*ដែននេសាទជាទ្រព្យសម្បត្តិរបស់រដ្ឋ។ ព្រំប្រទល់នៃដែននេសាទ ត្រូវកំណត់ដោយអនុក្រឹត្យ*"

ដូចនេះ ការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់ព្រំប្រទល់ដែននេសាទ ជាកិច្ចចាប់ផ្តើមដំបូងត្រូវអនុវត្តតាមនីតិវិធីដូចមានកំណត់ក្នុងប្រកាសលេខ ៤២ ដនស.បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៦ ស្តីពីការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ។ បន្ទាប់មក ត្រូវបញ្ជូនទៅក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្តពាក់ព័ន្ធ ដើម្បីពិនិត្យនិងឯកភាព។ ករណីឯកភាពនឹងការធ្វើអត្ត

សញ្ញាណកម្មដីរដ្ឋឬដែននេសាទនិងផែនទីរបស់អង្គភាពរដ្ឋបាលជលផលហើយ អង្គភាពរដ្ឋបាលជលផលត្រូវរៀបចំសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការកំណត់ព្រំប្រទល់ដែននេសាទមួយដោយមានភ្ជាប់ផែនទីជាឧបសម្ព័ន្ធ ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីប្រជុំពិភាក្សាសម្រេច។ បន្ទាប់មកទៀត ត្រូវយកអនុក្រឹត្យដែលបានអនុម័តហើយនេះ ទៅចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី ដើម្បីទទួលបានបណ្ណកម្មសិទ្ធិជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋតែម្ដងដោយពុំចាំបាច់ដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬក្រុមប្រឹក្សាគោលនយោបាយដីធ្លីទៀតទេ ដោយហេតុថាអង្គភាពទាំងពីរបានចូលរួមនៅក្នុងកិច្ចប្រជុំពិភាក្សាគណៈរដ្ឋមន្ត្រីរួចហើយ មុនពេលអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការនេះ។

**ឯកសារយោងៈ**

**ក-ផ្នែកឯកសារ**

-ប្រវត្តិនៃការគ្រប់គ្រងវិស័យជលផលនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ របស់ឯកឧត្តម ណៅ ធួក ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផលនិងលោក ប៉ូ សេងជឺ អតីតប្រធានស្នាក់ការអធិការកិច្ចនេសាទសមុទ្រ

-និនានុលេខន៍ឆ្នាំ២០១២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ស្ថិតិឡូត៍នេសាទឆ្នាំ២០១០ របស់នាយកដ្ឋានកិច្ចការជលផលនៃរដ្ឋបាលជលផល

**ខ-ផ្នែកបទដ្ឋានគតិយុត្ត**

-រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣

-ច្បាប់ស្ដីពីជលផល ឆ្នាំ២០០៦

-អនុក្រឹត្យលេខ ១១៨ អនក្រ ស្ដីពីការគ្រប់គ្រងដីរដ្ឋ ឆ្នាំ២០០៥

-ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ស្ដីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ ឆ្នាំ២០០៦

-អនុក្រឹត្យលេខ ២៥ អនក្រ ស្ដីពីការគ្រប់គ្រងសហគមន៍នេសាទ ឆ្នាំ២០០៧

-អនុក្រឹត្យលេខ១៩៧ អនក្រ.បក ស្ដីពីការកំណត់ដែនព្រៃលិចទឹកចំនួន៦៤៧.៤០៦ ហិកតា ស្ថិតនៅក្នុងខេត្តទាំង៦ ជុំវិញបឹងទន្លេសាប(ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ) ឆ្នាំ២០១១

-អនុក្រឹត្យលេខ៥៣ អនក្រ.បក ស្ដីពីការបង្កើតកន្លែងអភិរក្សជលផលក្នុងខេត្តកណ្ដាល កំពង់ចាម ព្រៃវែង និងខេត្តតាកែវឆ្នាំ២០១២

-អនុក្រឹត្យលេខ៣៧ អនក្រ.បក ស្ដីពីការលុបឡូត៍នេសាទជុំវិញបឹងទន្លេសាបក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប ពោធិ៍សាត់ កំពង់ឆ្នាំង និងខេត្តកំពង់ធំ ទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ និងជាកន្លែងអភិរក្សជលផលឆ្នាំ២០១២

-សេចក្តីសម្រេចលេខ ១៤៩-៨០ កប របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជាឆ្នាំ១៩៨០
-ប្រកាសលេខ០០៤ ប្រក.កសក ស្តីពីការកំណត់នាទីព្រៃលិចទឹកក្នុងខេត្តតាកែវឆ្នាំ ២០០០
-ប្រកាសលេខ៤២ ដនស.បក ស្តីពីការធ្វើអត្តសញ្ញាណកម្មការធ្វើផែនទីនិងការធ្វើចំណាត់ថ្នាក់ដីរដ្ឋឆ្នាំ២០០៦
-សារាចរណែនាំលេខ០២ សរណន ស្តីពីការផ្តល់បណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋដែលបានកាន់កាប់និងប្រើប្រាស់ជាក់ស្តែងនៅតំបន់វាលទំនាបដែលលិចទឹកក្នុងរដូវជំនើង នៃដែនដីដែលទទួលរបបទឹកទន្លេមេគង្គ ឆ្នាំ២០១៣។

បោះពុម្ពលើកទី២ ចំនួន៨០០ ច្បាប់
ឧបត្ថម្ភដោយៈ កម្មវិធីជំនួយខ្នាតតូចនៃមូលនិធិបរិស្ថានពិភពលោក
របស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ( UNDP GEF/SGP )

រក្សាសិទ្ធិគ្រប់យ៉ាង